

World Bank អនុម័តថវិកា ២០លានដុល្លារ អាមេរិក លុបបំបាត់ការបំពុលដោយប្លាស្ទិក

<ទំព័រ៖ ៧

ព្រះសហគមន៍ភូមិភាគភ្នំពេញ៖ ធ្វើដំណើររួមគ្នាជាផ្លូវតែមួយ ចូលរួមប្រកាសដំណឹងល្អ

<ទំព័រ៖ ១៦


កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ

ខែ ឧសភា | ឆ្នាំ ២០២២ | លេខទី ១៥១

# the messenger

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

May, 2022 | #151


## អបអរសាទរពិធីតែងតាំងលោកបូជាចារ្យថ្មី
# លោកយ៉ូហាន បាទីស្ត ប្រាក់ ប៊ុនហុង
## នៅព្រះវិហារប៊ូស្រា ខេត្តមណ្ឌលគីរី



អភិបូជាអគ្គសញ្ញាតែងតាំងលោកឧបដ្ឋាកយ៉ូហាន បាទីស្ត ប្រាក់ ប៊ុនហុង ទៅជាបូជាចារ្យនៅព្រះវិហារសន្តយ៉ូហាន បាទីស្ត ប៊ូស្រា ខេត្តមណ្ឌលគីរី នាព្រឹកថ្ងៃពុធ ទី២៩ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង៖ ៩:០០ ព្រឹក ដោយលោកអភិបាលអូលីវីយេ ជ្មឹតហស្លេ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងមានការចូលរួមពីសំណាក់លោកអភិបាលអេនរីគេ ហ្វិការេដូ អភិបាលភូមិភាគបាត់ដំបង លោកបូជាចារ្យជាតំណាងពេញសិទ្ធិលោកភិបាលភូមិភាគកំពង់ចាម អស់លោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្តបរិស័ទអន្តរភូមិភាគយ៉ាងច្រើនកុះករ ប្រមាណជិត២០០០នាក់។

កម្ពុជាមិនមែនកូនបំណុលតែចិនទេ សំខាន់គឺកម្ពុជាក៏មិនចេះតែខ្ចីគេដែរ

ទំព័រ-៤




ដូនជីបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់រំលឹកពាក្យសច្ចានៅមុខកូនសិស្សទាំងអស់

ទំព័រ-១៥

កុមារជួបជុំគ្នាបោះជំរំនិងរៀនពីការរស់នៅក្នុងព្រះសហគមន៍និងសង្គម

ទំព័រ-១៩



# មនុស្សចាស់



បងប្អូនជាទីស្រឡាញ់រាប់អាន អ្នកនាំសារក្នុងលេខនេះ សូមនាំអារម្មណ៍លោកអ្នក មកចាប់អារម្មណ៍នឹងមនុស្សចាស់បន្តិច។ លោកទាំងអស់ជា ចាស់ទុំជាគ្រូ ជាមាតាបិតា និងជាអ្នករួមដំណើរជាមួយនឹងយើងសព្វថ្ងៃនេះក្នុងការកសាងសង្គមមួយប្រកបដោយសន្តិភាព និងវឌ្ឍនភាព ។

ពីមួយថ្ងៃទៅមួយថ្ងៃ ម្នាក់ៗបានខិតខំអស់ពីកំលាំងកាយចិត្ត ក្នុងការចិញ្ចឹមជីវិត ដោយបំពេញកិច្ចការងារផ្សេងៗតាមជំនាញ និងទេពកោសល្យរៀងៗខ្លួន។ កំលាំងដែលប្រកបដោយសក្តានុពល គឺក្រុមមនុស្សវ័យកណ្តាល ដែលបានបញ្ចេញថាមពលយ៉ាងខ្លាំង សម្រាប់អនាគតរបស់ខ្លួន និងអ្នកបន្តវេន គឺកូនចៅជំនាន់ក្រោយ ព្រមទាំងសង្គមជាតិទាំងមូល។

ប៉ុន្មានឆ្នាំកន្លងទៅ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក្នុងទិវាប្រព័ន្ធសារគមនាគមន៍ពិភពលោក បានលើកឡើងប្រធានបទ រឿងរ៉ាវនៃដំណើរជីវិត ក្លាយទៅជាប្រវត្តិសាស្ត្រ។ កាលឆ្នាំ២០២១កន្លងទៅ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក៏បានបង្កើតឱ្យមានទិវាពិភពលោកសម្រាប់លោកយាយលោកតា នឹងប្រារព្ធនៅថ្ងៃអាទិត្យសប្តាហ៍ទី៤ ក្នុងខែកក្កដា។

វដ្តនៃជីវិត ក្នុងលោក មានការប្រែប្រួល និងវិវឌ្ឍនៃការយកចិត្តទុកដាក់ថែរក្សា ចំពោះគ្នាទៅវិញទៅមកប្រកបដោយសេចក្តីស្រឡាញ់ និងដួងចិត្តដ៏ទូលំទូលាយ។

តើលោកអ្នកបានយកចិត្តទុក ប្រតិបត្តិចំពោះចាស់ទុំ ព្រឹទ្ធាចារ្យ យាយ តា របស់ខ្លួនយ៉ាងម្តេចខ្លះ? តើលោកអ្នកធ្លាប់បានស្តាប់ការទូន្មានរបស់អ្នកទាំងនោះយ៉ាងដូចម្តេចខ្លះ?

ក្រោយប្រទេសចាកផុតពីសង្គ្រាម មានឪពុក ម្តាយ បងប្រុស បងស្រី ជាច្រើននាក់ក្នុងប្រទេសកម្ពុជា ដែលមិនបានចូលសាលារៀន ឬបោះបង់ចោលសាលារៀន ក្នុងវ័យក្មេង មិនទាន់ទទួលការអប់រំចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីខិតខំជួយជ្រោមជ្រែងគ្រួសារឱ្យប្រសើរ ទុកឱកាសសម្រាប់ប្អូនៗ ដើម្បីឱ្យបានទទួលការសិក្សាខ្ពង់ខ្ពស់។ ពួកគាត់ភាគច្រើនប្រើកម្លាំងកាយសុទ្ធសាធ ដើម្បីរកចំណូលសម្រាប់គ្រួសារ និងបម្រើសង្គមជាតិ។ តើលោកអ្នកបានតបស្នងចំពោះអ្នកទាំងអស់នោះដោយរបៀបណា?

មនុស្សចាស់ក្នុងប្រទេសកម្ពុជាយើង កូនចៅមានតួនាទីមើលថែរក្សា យកចិត្តទុកដាក់គ្រប់យ៉ាងចំពោះមាតា បិតារបស់ខ្លួន។ ចាស់ទុំទាំងឡាយនៅតែជាបង្គោលដ៏មាំសម្រាប់ជាទីពឹង និង សេចក្តីសុខរបស់កូនចៅ។ យោបល់ ការទូន្មាន តាមចំណេះដឹង និងបទពិសោធ លោកយាយ លោកតា នៅតែជាប្រភពដ៏វិសេសវិសាល នៃធនធានសម្រាប់អ្នកបន្តវេន និងកូនចៅរហូត។

ជាពិសេស ការពង្រឹង សេចក្តីថ្លៃថ្នូរ ការបង្រួបបង្រួម ការថែរក្សា ឱ្យកូនចៅទាំងអស់មានសេចក្តីសុខ ក្នុងគ្រាដែលកូនចៅទាំងឡាយ បានយកចិត្តទុកដាក់ និងស្តាប់តាម ដោយការគោរព និងពិចារណាយ៉ាងច្បាស់លាស់នោះ។

បើនិយាយអំពីជំនឿកាតូលិកវិញ លោកយាយ លោកតា នៅជាតែជាគំរូដ៏ល្អសម្រាប់ការអនុវត្តជំនឿ លើព្រះយេស៊ូដល់កូនចៅគ្រប់ជំនាន់។

ការមិនបានអើពើចំពោះ លោកយាយ លោកតា និងព្រឹទ្ធាចារ្យរបស់ខ្លួន កូនចៅសិស្សគណ ភាគច្រើនគឺ មិនបានចម្រើនឡើងនោះទេ បាត់គុណធម៌ មនុស្ស ទាំងឡាយទាំងពួង និងមិនមានការគោរពចំពោះបុគ្គលបែបនោះឡើយ។

សរុបមកវិញ ការយកចិត្តទុកដាក់ ចំពោះមនុស្សចាស់ លោកយាយ លោកតា ព្រឹទ្ធាចារ្យរបស់ខ្លួន ឬបុព្វបុរស នៃជាតិសាសន៍ គឺនឹងទទួលព្រះពរយ៉ាងបរិបូរណ៍ ក្នុងជីវិតរស់នៅរបស់ខ្លួន។

ពាក្យខ្មែរបុរាណតែងពោលថា ធ្វើបុណ្យទាន់ខែភ្លឺ។ សូមយកចិត្តទុកដាក់ថែរក្សា មាតា បិតា លោកយាយ លោកតាចាស់ជរា ទាន់ពួកគាត់នៅមានជីវិតអាចទទួលយកសេចក្តីគោរពទាំងនោះបាន៕



Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.វ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# ករណីជំងឺគ្រុនឈាមនៅកម្ពុជា ពីខែមករាដល់ឧសភា ឆ្នាំ២០២២ កើនឡើងជាង១០០%ធៀបនឹងឆ្នាំមុន

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងសុខាភិបាលនៅថ្ងៃទី១០ ខែមិថុនានេះ បានឱ្យដឹងថា ជំងឺគ្រុនឈាមក្នុងអំឡុង២២សប្តាហ៍ ដើមឆ្នាំ២០២២នេះ មានចំនួន១,៣៥៤ករណី ក្នុង នោះស្លាប់ចំនួន៣ករណី។ ករណីគ្រុនឈាមបាន កើនឡើងជាង១០០% បើធៀបនឹងឆ្នាំ២០២១ក្នុង រយៈពេលដូចគ្នា។



យោងតាមលទ្ធផលការអង្កេតបាណកសាស្ត្រ រួមផ្សំនឹងកត្តាអាកាសធាតុដែលកំណើនទឹកភ្លៀង ក្នុង អំឡុងពេលដើមឆ្នាំនេះ អាចសន្និដ្ឋានបានថា ចំនួនជំងឺគ្រុនឈាមនឹងប្រឈមការកើនឡើង កាន់ខ្លាំងក្នុងរដូវវស្សា នេះនៅតាម ភូមិ ឃុំ និង ទីប្រជុំជននៃបណ្តាខេត្តមួយចំនួន ជាពិសេសខេត្ត ដែលមានកំណើនការសាងសង់អគារ (ការដ្ឋាន សំណង់) និងមានប្រជាជនរស់នៅច្រើនកុះករ។

យោងតាមសេចក្តីជូនព័ត៌មានរបស់ក្រសួង សុខាភិបាលបានឱ្យដឹងថា ជំងឺគ្រុនឈាមអាចកើត លើមនុស្សគ្រប់វ័យ វាបង្កឡើងដោយសត្វមូសខ្លា ញីខាំបឺតឈាមចម្លងមេរោគ គ្រុនឈាម ពីមនុស្ស ម្នាក់ទៅម្នាក់ទៀត។ សត្វមូសខ្លាបង្កបង្កើតកូន ចៅនៅក្នុងទឹកថ្លា ស្អាត និងចូលចិត្តរស់នៅ ជិត មនុស្ស វាហើរបានចម្ងាយមិនលើសពី១៥០ម៉ែត្រ ពីទីកន្លែងកកើត។

លោកម៉មប៊ុនហេងរដ្ឋមន្ត្រីក្រសួងសុខាភិបាល បានអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប និងអាជ្ញាធរ មូលដ្ឋាន ត្រូវចូលរួមចលនាកាត់បន្ថយនិង ទប់ស្កាត់ការកកើតសត្វ មូស ដោយប្រកាន់ខ្ជាប់ នូវគោលជំហរជាប្រជាជនគម្រមួយរូប ស្របនឹង ពាក្យស្លោក «ខ្ញុំនិងគ្រួសារខ្ញុំ ជាគ្រួសារគំរូ ព្រោះ ផ្ទះខ្ញុំនិងលំនៅដ្ឋានរបស់ខ្ញុំ គ្មានដង្កូវទឹក»។

លោកបានបន្តថា ៖ «អាណាព្យាបាល មាតាបិតា កុមារា កុមារី គ្រប់រូប រួមទាំងអាជ្ញាធរ មូលដ្ឋាន ត្រូវសកម្មចូលរួមកម្ចាត់ដង្កូវទឹកនៅតាម ទីកន្លែងដែលមានទឹកដក់ ដូចជា ពាង អាងទឹក ថូផ្កា ចានទ្រជើងតុទូ ក្រឡ ធុង ខាប់ ជាដើម ហើយនៅក្នុងបរិវេណការដ្ឋាន សំណង់ត្រូវលុប បំបាត់វត្ថុដក់ទឹក និងផ្លូកដក់ទឹក ដើម្បីការពារកុំ ឲ្យដក់ទឹក លុបបំបាត់ប្រភព និងជម្រកមូសខ្លា»។

យោងតាមការស្រាវជ្រាវផ្នែកបាណកសាស្ត្រ របស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នៃ មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ (ម.គ.ច) រួមសហការជាមួយមន្ទីរសុខាភិបាល រាជធានី-ខេត្ត បានបញ្ជាក់ឲ្យឃើញថា សត្វមូសខ្លាចូលចិត្តពង បង្កបង្កើតកូនចៅ នៅក្នុងសំបកកង់ឡាន និង សំបកកង់ម៉ូតូចាស់ៗ ១១ដង ច្រើនជាង វត្ថុដាក់ ទឹកសំរាប់ប្រើប្រាស់ផ្សេង។

ការសិក្សារបស់កម្មវិធីជាតិប្រយុទ្ធ នឹងជំងឺ គ្រុនឈាម នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ កន្លងមក នេះ បានបង្ហាញថា ជំងឺគ្រុនឈាមក្នុង រដូវវស្សាកើនឡើងច្រើនជាង២ដង បើធៀបនឹង ចំនួនករណីក្នុងរដូវប្រាំង ហើយមានទំនាក់ទំនង យ៉ាងខ្លាំងជាមួយនឹងកត្តាអាកាសធាតុដូចជា កំដៅ ចំនួនទឹកភ្លៀង និងសំណើម។

ជាមួយគ្នានេះដែរ លោករដ្ឋមន្ត្រីក៏បានអំពាវនាវ ឱ្យអាជីវករ និងម្ចាស់អាជីវកម្មទាំងឡាយ ដែល ប្រកបរបរពាក់ព័ន្ធនឹងសំបកកង់ឡានម៉ូតូ ធ្វើការ គ្រប់គ្រងសំបកកង់ទាំងនោះ ឲ្យមានសុវត្ថិភាព ជៀសផុតពីការដក់ទឹក ដោយមិនត្រូវទុកចោល ពាស វាលពាសកាល បង្កើតបានជាប្រភពកកើត និងជម្រកមូសខ្លាដ៏គ្រោះថ្នាក់បំផុត។

លោក ម៉ម ប៊ុនហេង បានបញ្ជាក់ថា ៖ «ត្រូវ ប្រកាន់ខ្ជាប់នូវទម្លាប់រស់នៅស្អាត ធ្វើអនាម័យផ្ទះ សម្បែង ផ្ទះមានពន្លឺចេញចូល ទុកដាក់របស់របរ សំលៀកបំពាក់ក្នុងក្រៅផ្ទះឲ្យមានសណ្តាប់ធ្នាប់ លុបបំបាត់ព្រៃស៊ុបទ្រុបជុំវិញផ្ទះ ដើម្បីកាត់បន្ថយ ជម្រកសត្វមូសមកតោងជ្រកទុំជិតខ្លួនយើង»។

លោកថា អំឡុងពេលថ្ងៃ គឺចាំបាច់ត្រូវស្លៀក សំលៀកបំពាក់មានដៃវែងជើងវែង សម្រាន្តក្នុងមុង ជាប្រចាំ ទាំងថ្ងៃទាំងយប់ និងមិនត្រូវអង្គុយលេង នៅជិតទីកន្លែងងងឹតៗនោះទេ។

ករណីមានរោគសញ្ញាក្តៅខ្លួនខ្លាំងភ្លាមៗ ត្រូវប្រញាប់នាំអ្នកជំងឺទៅរកសេវាពិនិត្យ និង ព្យាបាលរបស់រដ្ឋដូចជាមណ្ឌលសុខភាព និង មន្ទីរពេទ្យ ដែលនៅជិតបំជាបន្ទាន់ (មិនឲ្យ យឺត ជាង៧២ម៉ោង បន្ទាប់ពីក្តៅខ្លួន) ហើយសូមកុំ សាកល្បងព្យាបាលអ្នកដែលមានគ្រុនក្តៅខ្លាំង ដោយខ្លួនឯង ឬពន្យារពេលតាមដានព្យាបាល ជំងឺក្នុងសេវាឯកជនដែលគ្មានសមត្ថភាពផ្នែក ជំងឺគ្រុនឈាមនេះឲ្យសោះ ។

លោក ម៉ម ប៊ុនហេង បានសង្កត់ធ្ងន់ថា ៖ «ជំងឺគ្រុនឈាម អាចនឹងសម្លាប់អ្នកជំងឺបាន គ្រប់ពេល ប្រសិនបើមិនបានទៅទទួលការព្យាបាល នៅសេវាសាធារណៈ ដែលមានការបណ្តុះបណ្តាល ត្រឹមត្រូវ ឲ្យបានទាន់ពេលវេលាឬក៏សាកល្បង ព្យាបាលនៅសេវាឯកជន ដែលមិន មានចំណេះ ជំនាញខាងជំងឺគ្រុនឈាម ឬបើអ្នកជំងឺមានការ ប្រើប្រាស់ប្រភេទថ្នាំអាស្ពីរីន»។

ជាមួយគ្នានេះដែរ គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ ត្រូវបន្តផ្តល់ការបណ្តុះបណ្តាលដល់ គ្រូ ពេទ្យព្យាបាលទាំងសេវារដ្ឋ និងសេវាឯកជន អំពីរបៀបធ្វើរោគវិនិច្ឆ័យ-ព្យាបាល-ថែទាំអ្នកជំងឺ គ្រុនឈាម មុន និងអំឡុងរដូវភ្លៀង។ សម្រាប់ សេវាឯកជន ដែលមិនមានចំណេះជំនាញ សម្ភារ និងឧបករណ៍ត្រឹមត្រូវ សម្រាប់ធ្វើរោគ វិនិច្ឆ័យ-ព្យាបាល-ថែទាំជំងឺគ្រុនឈាម គឺក្រសួងសុខាភិបាល មិនអនុញ្ញាតឲ្យទទួលការព្យាបាលជំងឺគ្រុនឈាម នេះ ឡើយ ហើយត្រូវតែបញ្ជូនជាបន្ទាន់មកមន្ទីរ ពេទ្យរដ្ឋ ដែលនៅជិតបំផុត៕

# ក្រសួងសុខាភិបាលបានដាក់ឱ្យប្រើប្រាស់ឱសថមួយថ្មីទៀត សម្រាប់ព្យាបាលជំងឺកូវីដ-១៩




*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងសុខាភិបាល និងគណៈកម្មការជាតិ ប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានប្រកាសឱ្យប្រើឱសថ ផាកឡូវីដ (PAXL0VID) សម្រាប់ព្យាបាលជំងឺ កូវីដ-១៩ ចំពោះមនុស្ស ចាប់ពីអាយុ ១២ឆ្នាំ ឡើងទៅ ខណៈដែលក្រសួងបាននិងកំពុងដាក់ឱ្យ ប្រើប្រាស់ឱសថម៉ូលណាទ្រីស (MOLNATRIS) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ចំពោះមនុស្ស ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។

ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹង ជំងឺកូវីដ-១៩ នៃគណៈកម្មការជាតិប្រយុទ្ធនឹង ជំងឺកូវីដ-១៩ បានឱ្យដឹងថា ដើម្បីបន្តចូលរួម ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង បង្កើតបានភាពស៊ាំសហគមន៍រឹងមាំទប់ទល់នឹង ជំងឺរាតត្បាតសកលកូវីដ-១៩ ក្រុមការងារបាន នាំចូលបន្ថែមឱសថ ផាកឡូវីដ (PAXL0VID) សម្រាប់ ព្យាបាលជំងឺកូវីដ-១៩ ចំពោះមនុស្ស ចាប់ពីអាយុ ១២ឆ្នាំឡើងទៅ។

ប្រជាពលរដ្ឋអាចទិញឱសថផាកឡូវីដ (PAXL0VID) នេះនៅក្រសួងប្រៃសនីយនិងទូរគម នាគន៍តម្លៃ ៩៥ ដុល្លារអាម៉េរិក ដែលបុគ្គលម្នាក់ មានសិទ្ធិបញ្ជាទិញពី១ ដល់៥ដូស ហើយមន្ទីរ ពេទ្យឯកជន គ្លីនិក ឱសថស្ថាន និងឱសថស្ថានរង មានសិទ្ធិបញ្ជាទិញពី១០ ដល់៥០ដូស ប៉ុន្តែត្រូវ មានលិខិតអនុញ្ញាតបើកអាជីវកម្ម។

គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានបញ្ជាក់ថា មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន និងឱសថស្ថានរង អាចលក់បន្តមិនលើសពី ១០៥ ដុល្លារអាម៉េរិក ក្នុង១ដូស ហើយមន្ទីរពេទ្យ ឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និង សាធារណជន អាចបញ្ជាទិញសារជាថ្មីយ៉ាងតិច ១សប្តាហ៍ក្រោយបញ្ជាទិញលើកចុងក្រោយ។

គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានបញ្ជាក់ថា ៖ «ករណីមន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ឬអ្នកលក់ យកទៅ លក់បន្តលើសពីតម្លៃ កំណត់ខាងលើ ក្រុមការងារ នឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បី ចាត់វិធានការ តាមនីតិវិធីជាធរមាន»។

មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន អាចបញ្ជាទិញឱសថទាំងពីរ ប្រភេទ ដោយផ្ទាល់នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសាខាប្រៃសណីយ៍ កម្ពុជាខេត្ត៕

# កម្ពុជាមិនមែនកូនបំណុលតែចិនទេ សំខាន់គឺកម្ពុជាក៏មិនបេះតែខ្ចីគេដែរ

*អត្ថបទ៖ អរិយបុត្រ*

សម្តេច ហ៊ុន សែន នៅព្រឹកថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០២២ បានថ្លែងថា កម្ពុជាមិនមែនជាកូនបំណុលតែមួយរបស់ចិននោះទេ,ហើយចិនក៏គ្មានបំណងដាក់អន្ទាក់កម្ពុជានោះដែរ ក្រៅពីចិនកម្ពុជាក៏ខ្ចីប្រទេសផ្សេងៗដោយរួមទាំងជប៉ុន និងស្ថាប័ននានាទៀតដែរ។

សំខាន់កម្ពុជាក៏មិនបេះតែខ្ចីផ្តេសផ្តាសដែរ គឺមានការសិក្សា និង គ្រប់គ្រងបំណុលនេះ យ៉ាងមាន ប្រសិទ្ធភាព នេះជាការបញ្ជាក់របស់សម្តេច ហ៊ុន សែន ក្នុងសន្និសីទអន្តរជាតិលើកទី ២៧ ស្តីពីអនាគតរបស់អាស៊ី។




សម្តេចបានបញ្ជាក់ថា ៖ «ខ្ញុំសូមបញ្ជាក់ដាច់ណាត់ថាយើងខ្ញុំមិនអាចក្លាយទៅជាកូនបំណុលតែមួយគត់របស់ចិនទេ,ហើយចិនក៏គ្មានបំណងដាក់កម្ពុជាជាអន្ទាក់បំណុលនោះដែរ ក្រៅពីចិន កម្ពុជានៅខ្ចីប្រទេសផ្សេងៗទៀតដោយរួមទាំងជប៉ុន»។

សម្តេចបានបញ្ជាក់ទៀតថា ៖ «កម្ពុជាគឺមិនដាក់ខ្លួនទៅក្នុងអន្ទាក់នរណាទាំងអស់ហើយចិនក៏មិនមែនជាប្រទេសតែមួយគត់ដែលយើង ខ្ញុំខ្ចីប្រាក់នោះដែរ,ជប៉ុនយើងខ្ញុំខ្ចីប្រាក់ច្រើន,ជាមួយនឹងប្រទេសដទៃទៀតយើងខ្ញុំក៏ខ្ចីប្រាក់ដូចគ្នា តែកម្ពុជាមិនមែនបេះតែខ្ចីគេនោះទេ»។

សម្តេចបានថ្លែងបញ្ជាក់ថា សម្តេចសូមធានាថាអ្វីដែលកម្ពុជាខ្ចីកម្ពុជាមានការប្រុងប្រយ័ត្នខ្លួនឯង មានច្បាប់ទាក់ទងនឹងការខ្ចីបុលហើយបើគិតមកដល់ ពេលនេះពិដានសម្រាប់ការខ្ចីរបស់កម្ពុជាដែលគេអនុញ្ញាតឱ្យខ្ចីរហូតដល់៤០ភាគរយនៃផលិតផលក្នុងស្រុកសរុប តែកម្ពុជាទើបនឹងខ្ចីត្រឹមតែ២៣ ភាគរយតែប៉ុណ្ណោះ ដែលនៅសេសសល់ទំហំសម្រាប់ការខ្ចីតទៅទៀត។

សម្តេចបានបន្ថែមថា កម្ពុជាមិនមែនបេះតែខ្ចីដោយមិនបានគិតគូរអំពីស្ថានភាពបំណុលដែលអាចដោះស្រាយបាននោះទេ កម្ចីទាំងនោះគឺ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កម្ពុជាមិនដាក់ខ្លួនទៅជាកូនបំណុលរបស់នរណាមួយនោះទេព្រោះកម្ពុជាមិនអាចខ្ចីតែពីចិន តែកម្ពុជាអាចខ្ចីពីជប៉ុន កូរ៉េ ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក និងពីធនាគារអឺរ៉ុប។ ដូចនេះកម្ពុជាមិនអាចពឹងពាក់តែមួយជ្រុងនោះទេ ប៉ុន្តែវាច្បាស់ហើយថាចិនបានផ្តល់ជាមូល ដ្ឋានសម្រាប់កម្ពុជានេះជាបញ្ហាពិតប្រាកដ។

លោក ប៉ា ចន្ទរឿន ប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជាបាន លើកឡើងថា កម្ពុជាត្រូវមានការប្រយ័ត្នប្រយែងក្នុងការខ្ចីបុលដើម្បីធានាថាបំណុល កម្ចីដែលខ្ចីយកមកនេះនឹងមិនក្លាយជាអន្ទាក់វណ្ណកសម្រាប់ប្រទេសជាតិ។

លោកប្រទេសកម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍ ដែលត្រូវការនូវធនធានគ្រប់ប្រភេទដោយរួមទាំងធនធានផ្នែកហិរញ្ញវត្ថុក្នុងទំរង់ជាប្រាក់កំចីជាដើម ដើម្បីយកមកអភិវឌ្ឍប្រទេស ប៉ុន្តែកម្ពុជាត្រូវមានការប្រយ័ត្នប្រយែងក្នុងការខ្ចីបុលនេះផងដែរ។

លោក ប៉ា ចន្ទរឿន បានបញ្ជាក់ថា៖ «កម្ពុជាត្រូវតែបញ្ចៀសឱ្យបានក្នុងការដែលអាចធ្លាក់ចូលទៅក្នុងអន្ទាក់បំណុលរបស់ប្រទេសណាមួយ រួមទាំងប្រទេសចិនផងដែរ ដើម្បីកុំឱ្យកើតមានមហន្តរាយឬក៏ការប្រឈមស្អេកស្កះដូចប្រទេសមួយចំនួននៅក្នុងពិភពលោក»៕

## ប្រមុខរាជរដ្ឋាភិបាលកម្ពុជា៖ វ៉ាក់សាំងកូវីដ-១៩ ជានិមិត្តរូបនៃសាមគ្គីភាព និងឯកភាពជាតិ

*អត្ថបទ៖ អរិយបុត្រ*

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា មានប្រសាសន៍ថា វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ គឺជានិមិត្តរូបនៃឯកភាព និងសាមគ្គីភាពរបស់ប្រទេសជាតិ ហើយបាននិងកំពុងបន្តអនុវត្តដោយមិនមានការរើសអើងណាមួយឡើយ។

ថ្លែងក្នុងពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាលាភូមិន្ទរដ្ឋបាល នាព្រឹកថ្ងៃទី១៣ ខែមិថុនា សម្តេចបានមានប្រសាសន៍លើកទឹកចិត្តដល់មន្ត្រីនិងអាជ្ញាធរទាំងអស់ ឲ្យបន្តប្រកាន់ខ្ជាប់នូវការអនុវត្តនូវយុទ្ធនាការចាក់វ៉ាក់សាំងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ។

សម្តេច ហ៊ុន សែន ក៏បានចែករំលែកនូវយុទ្ធសាស្ត្រមួយចំនួនប្រឆាំងនឹងជំងឺដ៏កាចសាហាវនេះ រួមទាំងការគ្រប់គ្រងវិមជ្ឈការដល់ថ្នាក់ក្រោមជាតិលើបញ្ហានេះផងដែរ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ដោយសារការគ្រប់គ្រងបានល្អ និងយុទ្ធសាស្ត្រច្បាស់លាស់ក្នុងរយៈពេល៣៧ថ្ងៃកម្ពុជាអាចរក្សាអត្រាសូន្យនៃមេរោគកូវីដ-១៩ ខណៈវ៉ាក់សាំងជាមូលដ្ឋានអាចអនុវត្តបានជាង ៧៤ភាគរយ។

សម្តេចបានថ្លែងថា ទុនបម្រុងវ៉ាក់សាំងត្រូវបានដាក់ជាអាទិភាពដល់ឆ្នាំ ២០២៦។ សម្តេចបាននិយាយថា កម្ពុជានឹងមានវ៉ាក់សាំងសរុបចំនួន ១០៤ លានដូសសម្រាប់បម្រុងទុកនាឆ្នាំ ២០២៤ ឆ្នាំដល់ ២០២៦ សម្រាប់ឆ្នាំ២០២៣ នឹងត្រូវប្រើប្រាស់ជាមួយនឹងវ៉ាក់សាំងដែលមាននៅក្នុងស្តុក។

យោងតាមសម្តេច ហ៊ុន សែន មានវ៉ាក់សាំងសរុបចំនួន ១១លានដូស ក្នុងស្តុក ហើយ ១៥លានដូស នឹងបានមកពីប្រទេសចិន ៥,៥លានដូស ពីសហរដ្ឋអាមេរិក និង ០,៥លានដូស ពីប្រទេសអូស្ត្រាលី។

សម្តេចក៏បានអំពាវនាវដល់សមត្ថកិច្ចមូលដ្ឋានទាំងអស់បន្តជំរុញឱ្យសាធារណជនចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩៕

## សម្តេចតេជោប្រកាសថា កម្ពុជានឹងតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ

*អត្ថបទ៖ អរិយបុត្រ*

សម្តេច ហ៊ុន សែន បានបន្តជំរុញឲ្យពលរដ្ឋនិងមន្ត្រីបន្តប្រុងប្រៀបកាត់បន្ថយហានិភ័យទាក់ទងនឹងជំងឺកូវីដ-១៩ និង ផលប៉ះពាល់ដោយសារតែសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន ប៉ុន្តែរាជរដ្ឋាភិបាលនឹងគិតគូតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ គ្រូបង្រៀន និងក្រុមគ្រូពេទ្យ។

នៅព្រឹកមិញនេះនាពិធីបិទ និងប្រគល់សញ្ញាបត្រក្នុងវគ្គបណ្តុះបណ្តាលឆ្នាំ២០២០ ២០២១ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ របស់សាលាភូមិន្ទរដ្ឋបាលជាង២ពាន់នាក់ នៅរាជធានីភ្នំពេញ សម្តេចបានមានប្រសាសន៍ថា ស្ថាប័នហិរញ្ញវត្ថុមួយចំនួន ជាពិសេសគឺ IMF បានទម្លាក់ការព្យាករណ៍សេដ្ឋកិច្ចពិភពលោកដោយសារតែសង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែន។



សម្តេចបានមានប្រសាសន៍បន្ថែមទៀតថា ឥឡូវនេះពិភពលោកកំពុងតែប្រឈមមុខនឹងវិបត្តិថាមពល ហើយនៅពេលអនាគតវិបត្តិស្បៀងអាហារនឹងមកដល់ ហើយកម្ពុជា និង ប្រទេសនានា បាននឹងកំពុងតែទទួលផលប៉ះពាល់ ហើយសម្រាប់មន្ត្រីរាជការបានខកខានការតម្លើងប្រាក់បៀវត្សរ៍ នៅឆ្នាំ ២០២០ និង ២០២១ ប៉ុន្តែរាជរដ្ឋាភិបាលកំពុងតែគិតគូរ តម្លើង។

សម្តេចបានឲ្យដឹងថា គ្រូបង្រៀន និង គ្រូពេទ្យ គឺនឹងទទួលប្រាក់ខែទាបបំផុតត្រឹម ១,៥ លានរៀល ហើយសម្រាប់មន្ត្រីរាជការវិញ គឺ នឹងទាបបំផុត ១,៤ លានរៀល ដោយឡែកពន្ធលើប្រាក់បៀវត្សគឺនឹងអនុវត្តសម្រាប់អ្នកដែលទទួលប្រាក់បៀវត្សរ៍ទាបជាងគេបំផុត៕

# តុលាការកំពូលជាតិចំនួនបីបានជួបប្រជុំគ្នា ពិភាក្សាលើការកាត់ទោសឧក្រិដ្ឋកម្មសត្វព្រៃ



*អត្ថបទ៖ អមរិន្ទ ដានុត*

តុលាការកំពូលជាតិចំនួនបីបានជួបប្រជុំគ្នាដើម្បីពិភាក្សាលើការកាត់ទោសឧក្រិដ្ឋកម្មសត្វព្រៃថាជាឧក្រិដ្ឋកម្មដែលមានការរៀបចំយ៉ាងធ្ងន់ធ្ងរនៅក្នុងមហាទន្លេមេគង្គ និងកំណត់ផ្លូវឆ្ពោះទៅរកភាពប្រសើរឡើងនៃយុត្តិធម៌សម្រាប់សត្វព្រៃ។

កាលពីដើមខែមិថុនា ឆ្នាំ២០២២ តុលាការកំពូលពីប្រទេសកម្ពុជា ឡាវ និងវៀតណាម បានមកប្រជុំគ្នារយៈពេលពីរថ្ងៃសម្រាប់យុត្តិធម៌សម្រាប់សត្វព្រៃជាលើកដំបូងដែលរៀបចំដោយតុលាការប្រជាជនកំពូលនៃប្រទេសឡាវនៅទីក្រុងហ្លួងព្រះបាងឡាវ។

សន្និសីទដែលសហការរៀបចំដោយតុលាការប្រជាជនកំពូលនៃប្រទេសឡាវ និងក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ឡាវ ត្រូវបានកោះប្រជុំដើម្បីពង្រឹងការអនុវត្តច្បាប់ ការកាត់ទោស និងអត្រាផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសត្វព្រៃនៅក្នុងតំបន់។

យោងតាមសេចក្តីប្រកាសព័ត៌មានបានឱ្យដឹងថា ឧក្រិដ្ឋកម្មសត្វព្រៃជាច្រើននៅក្នុងតំបន់ និងអន្តរជាតិ មិនដែលកើតឡើងចំពោះតុលាការទេ ហើយឧក្រិដ្ឋកម្មទាំងនោះត្រូវបានទទួលទោសទណ្ឌជាប្រវត្តិសាស្ត្រ ដែលមិនត្រូវនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនោះទេ។

អនុប្រធានតុលាការប្រជាជនកំពូល លោក ខាំផែង ប៊ុនខុម បានលើកឡើងថា នេះជាលើកទីមួយ ហើយដែលតុលាការបានរៀបចំព្រឹត្តិការណ៍មួយនៃសមត្ថភាពនេះដែលគាំទ្រកិច្ចសហប្រតិបត្តិការលើការកាត់ទោសឧក្រិដ្ឋកម្មសត្វព្រៃ។

លោកបានថ្លែងថា ៖ «យើងមានសេចក្តីសោមនស្សរីករាយដែលបានឮថា សមភាគីរបស់យើងនៅកម្ពុជា និងវៀតណាមក៏ប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការទៅវិញទៅមករបស់យើងលើយុត្តិធម៌សម្រាប់សត្វព្រៃ ហើយខ្ញុំសង្ឃឹមថា យើងអាចបន្តប្រើប្រាស់យន្តការដែលមានស្រាប់ ដើម្បីចែករំលែកបទពិសោធន៍ និងមេរៀនរបស់យើងក្នុងវិស័យតុលាការដើម្បីប្រយុទ្ធប្រឆាំង»។

លោក ខាំផែង ប៊ុនខុម បានបញ្ជាក់ថា ការជួញដូរសត្វព្រៃ ហើយចាត់ទុកវាជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។

> អង្គការ WWF ត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើការជាមួយប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជាក្នុងការពង្រឹងឧបករណ៍ផ្លូវច្បាប់ និងការបង្កើនការកាត់ទោស ដែលនាំឱ្យមានការកាត់ទោសកាន់តែធ្ងន់ធ្ងរចំពោះជនល្មើសនៃឧក្រិដ្ឋកម្មសត្វព្រៃអន្តរជាតិ

ចំណែកលោក Jedsada Taweekan អ្នកគ្រប់គ្រងពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ក្នុងតំបន់សម្រាប់ W F-Greater Mekong បានលើកឡើងដែរថា ៖ «យើងបាននិងកំពុងធ្វើការដើម្បីជួយកែលម្អការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារអនុវត្តច្បាប់ ទាំងក្នុងប្រទេសនិងឆ្លងព្រំដែន ហើយយើងទទួលស្គាល់តួនាទីសំខាន់ដែលព្រះរាជអាជ្ញា និងតុលាការត្រូវដើរ ប្រសិនបើឧក្រិដ្ឋកម្មសត្វព្រៃត្រូវយកចិត្តទុកដាក់ខ្លាំងលើកម្រិតគ្រឿងញៀន និងបទល្មើសជួញដូរមនុស្ស»។

លោកបានបន្ថែមថា លោកមានសេចក្តីសោមនស្សរីករាយដែលចៅក្រមមកពីតុលាការកំពូលនៃប្រទេសមេគង្គទាំងបីកំពុងបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការកែលម្អការកាត់ទោសឧក្រិដ្ឋកម្មសត្វព្រៃ និងផ្ញើសារច្បាស់លាស់ទៅកាន់ប្រទេសរបស់ពួកគេ និងសហគមន៍អាស៊ានធំថា ពួកគេចាត់ទុកឧក្រិដ្ឋកម្មសត្វព្រៃជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។

ការបង្កើតគំរូមួយសម្រាប់ការពិភាក្សា និងកិច្ចសហប្រតិបត្តិការផ្នែកតុលាការឆ្លងព្រំដែនប្រភេទនេះគឺជាជំហានដំបូងដ៏គួរឱ្យរីករាយឆ្ពោះទៅរកការកែលម្អវិធីដែលឧក្រិដ្ឋកម្មសត្វព្រៃត្រូវបានកាត់ទោស និងកាត់ទោសនៅក្នុងតំបន់។ នេះបើតាមលើឡើងរបស់ លោក Sylvia Shweder ទីប្រឹក្សាច្បាប់អ្នកស្រុកប្រចាំតំបន់ OPDAT នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិកសម្រាប់ការប្រឆាំងការជួញដូរសត្វព្រៃនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

លោកថា ៖«នៅមានកិច្ចការជាច្រើនដែលត្រូវធ្វើ ហើយយើងប្តេជ្ញាគាំទ្រតុលាការប្រជាជនកំពូលឡាវឱ្យក្លាយជាជើងឯកសម្រាប់យុត្តិធម៌សត្វព្រៃនៅក្នុងតំបន់»។

នៅចុងបញ្ចប់នៃកិច្ចប្រជុំរយៈពេលពីរថ្ងៃ តំណាងនៃតុលាការកំពូលជាតិទាំងបីបានកំណត់ពីតម្រូវការក្នុងការសម្របសម្រួលមិនត្រឹមតែជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែឆ្លងព្រំដែនដោយលើកឡើងពីក្របខណ្ឌការសម្របសម្រួលត្រីភាគីដែលមានស្រាប់លើការកាត់ក្តីបញ្ហាឆ្លងដែន និងការផ្តល់យោបល់ថាសត្វព្រៃ។

លោក សេង ទៀក នាយកអង្គការ WWF-កម្ពុជា មានប្រសាសន៍ថា កិច្ចសហប្រតិបត្តិការល្អរវាងប្រទេសជិតខាង ដើម្បីដោះស្រាយឧក្រិដ្ឋកម្មសត្វព្រៃ តាមរយៈប្រព័ន្ធតុលាការដ៏មានប្រសិទ្ធភាព អាចលុបបំបាត់បណ្តាញជួញដូរសត្វព្រៃខុសច្បាប់ និងក្រុមសត្វព្រៃ។

លោកថា ឧក្រិដ្ឋកម្មសត្វព្រៃឆ្លងដែនមិនត្រឹមតែបំផ្លាញកិច្ចខិតខំប្រឹងប្រែងអភិរក្សប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិសុខជាតិ វិបុលភាពសេដ្ឋកិច្ច និងសុខភាពសាធារណៈផងដែរ។

លោក សេង ទៀក បានបន្ថែមថា ៖ «អង្គការ WWF ត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើការជាមួយប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជាក្នុងការពង្រឹងឧបករណ៍ផ្លូវច្បាប់ និងការបង្កើនការកាត់ទោសដែលនាំឱ្យមានការកាត់ទោសកាន់តែធ្ងន់ធ្ងរចំពោះជនល្មើសនៃឧក្រិដ្ឋកម្មសត្វព្រៃអន្តរជាតិ»។

បើតាមលោក Loris Palentini នាយកប្រចាំប្រទេសនៃអង្គការ WWF-ឡាវ ថា ការពិតដែលថាចៅក្រមឡាវជាង 100 នាក់មកពីតុលាការទូទាំងប្រទេស និងគណៈប្រតិភូពីកម្ពុជា និងវៀតណាម បានឆ្លៀតពេលចេញពីកាលវិភាគដ៏មមាញឹករបស់ពួកគេដើម្បីនៅទីនេះ ហើយរៀបចំផែនការឆ្ពោះទៅមុខ មានន័យថាយើងប្តេជ្ញាធ្វើការរួមគ្នាលើបញ្ហាឆ្លងដែននេះ។

លោកថា ៖ «យើងដឹងថាវាលំបាកប៉ុណ្ណាក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរសត្វព្រៃប្រកបដោយប្រសិទ្ធភាព ហើយវាមិនមែនជាអ្វីដែលយើងនឹងអាចដោះស្រាយបានមួយយប់នោះទេ ប៉ុន្តែខ្ញុំត្រូវបានលើកទឹកចិត្តដោយស្មារតីនៃកិច្ចសហប្រតិបត្តិការនេះហើយ WWF ប្តេជ្ញាធ្វើការជាមួយតុលាការ និងដៃគូផ្សេងទៀតដើម្បីសម្រេចបាន គោលដៅរួមរបស់យើងក្នុងការបញ្ចប់ឧក្រិដ្ឋកម្មសត្វព្រៃ»។

ជំងឺរាតត្បាត COVID-19 បាននាំមកនូវការយកចិត្តទុកដាក់ជាសកលចំពោះហានិភ័យសុខភាពសាធារណៈដ៏ធំសម្បើមដែលបង្កឡើងដោយការជួញដូរសត្វព្រៃ។ ឧក្រិដ្ឋកម្មសត្វព្រៃដែលបានរៀបចំឆ្លងដែនគឺជាការគំរាមកំហែងដល់សន្តិសុខជាតិ និងដល់ភាពធន់របស់សហគមន៍មូលដ្ឋានចំពោះចលាចលសង្គម និងសេដ្ឋកិច្ចដែលបណ្តាលមកពីការរិចរិលបរិស្ថាន។ ការវិនិច្ឆ័យប្រកបដោយប្រសិទ្ធភាពនៃឧក្រិដ្ឋកម្មសត្វព្រៃអាចជួយការពារសន្តិសុខ និងស្ថិរភាពនៃប្រទេសក្នុងតំបន់ និងជុំវិញពិភពលោក៕

# កុមារកម្ពុជា ១០ភាគរយជួបបញ្ហាខ្វះអាហាររូបត្ថម្ភធ្ងន់ធ្ងរបណ្ដាលមកពីសង្គ្រាមនៅអ៊ុយក្រែន

*អត្ថបទ៖ ផល សុផានិត*

នៅប្រទេសកម្ពុជា កុមារចំនួន ១០ភាគរយមានបញ្ហាស្គមស្គាំង។ កុមារទាំងនោះច្រើនមកពីគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមងាយរងគ្រោះ ដែលបណ្ដាលមកពីវិបត្តិសង្គ្រាមនៅអ៊ុយក្រែន។



យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អង្គការ UNICEF ចេញផ្សាយកាលពីពេលថ្មីៗនេះ កុមារកម្ពុជាទាំងនោះពុំសូវទទួលបានទឹកស្អាត និងលក្ខខណ្ឌអនាម័យប្រកបដោយសុវត្ថិភាព និងខ្វះការអនុវត្តល្អក្នុងការផ្ដល់អាហារដល់ទារក និងកុមារតូច គួបផ្សំជាមួយនឹងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចបច្ចុប្បន្នបង្កឡើងដោយការរាតត្បាតជំងឺកូវីដ-១៩ ដែលកាន់តែបង្កហានិភ័យធ្ងន់ធ្ងរលើអសន្តិសុខស្បៀង និងការខ្វះអាហារូបត្ថម្ភសម្រាប់គ្រួសារងាយរងគ្រោះ។

យូនីសេហ្វព្រមានថា ការរួមបញ្ចូលគ្នានៃការប៉ះទង្គិចជាសកលចំពោះសន្តិសុខស្បៀងដោយសារសង្គ្រាមនៅប្រទេសអ៊ុយក្រែន និងការលំបាកផ្នែកសេដ្ឋកិច្ចជាមួយនឹងការស្ដារឡើងវិញពីជំងឺរាតត្បាត និងគ្រោះរាំងស្ងួតជាប់ៗគ្នានៅក្នុងប្រទេសមួយចំនួនដោយសារបម្រែបម្រួលអាកាសធាតុ កំពុងបង្កើតលក្ខខណ្ឌនានាធ្វើឲ្យបញ្ហាស្គមស្គាំងធ្ងន់ធ្ងរកាន់តែកើនឡើងគួរឲ្យកត់សម្គាល់នៅកម្រិតពិភពលោក។

នៅកម្ពុជា មូលនិធិដើម្បីប្រយុទ្ធនឹងបញ្ហាស្គមស្គាំងធ្ងន់ធ្ងរ គឺមានចំនួនមិនគ្រប់គ្រាន់ទ្បើយដើម្បីឆ្លើយតបនឹងតម្រូវការកាន់តែកើនឡើង។ ផែនទីបង្ហាញផ្លូវជាតិសម្រាប់ឆ្លើយតបនឹងបញ្ហាស្គមស្គាំងរបស់កុមារត្រូវបានកំណត់តម្លៃថាមានចំនួនសរុបស្មើនឹង ២៥លានដុល្លារ ដើម្បីឆ្លើយតបនឹងតម្រូវការនៃបញ្ហាខ្វះអាហារូបត្ថម្ភនៅក្នុងរយៈពេលបីឆ្នាំខាងមុខ។ ទោះបីជាយ៉ាងណាក៏ក្ដី ៦៩% (១៧,២ដុល្លារ) នៃមូលនិធិត្រូវការសម្រាប់ការអនុវត្តពេញលេញនូវផែនការសកម្មភាពនេះ គឺមិនទាន់មានថវិកាគ្រប់គ្រាន់នៅឡើយ។

នាយិកាយូនីសេហ្វប្រចាំប្រទេសកម្ពុជា លោកស្រី ហ្វ័រហ្គ ហ្វយូហ្សិថ បានលើកឡើងថា៖ «អាហារូបត្ថម្ភ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍវ័យកុមារតូច និងមានឥទ្ធិពលយ៉ាងសំខាន់លើសមត្ថភាពរបស់កុមារក្នុងការរស់រាន ចម្រើនពេញវ័យ រៀនសូត្រ និងរីកចម្រើន»។ លោកស្រីបន្តថា៖ «យូនីសេហ្វកំពុងធ្វើការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីចាត់អាទិភាពលើបញ្ហាស្គមស្គាំងនៅក្នុងគោលនយោបាយ និងថវិកាជាតិដើម្បីបិទភ្និតគម្លាតនេះ ជាពិសេស ដោយស្វែងរកមតិគាំទ្រឲ្យមានការផ្ដល់ហិរញ្ញប្បទានប្រកបដោយចីរភាព សម្រាប់ធានាឲ្យមានអាហារព្យាបាលផលិតរួចស្រេច (RUTF) ដើម្បីព្យាបាលបញ្ហាខ្វះអាហាររូបត្ថម្ភធ្ងន់ធ្ងរក្នុងវ័យកុមារភាព។ យើងក៏កំពុងគាំទ្ររាជរដ្ឋាភិបាលក្នុងការពង្រឹងសកម្មភាពចុះដល់សហគមន៍ផងដែរ ដោយសារហេតុនេះ ករណីនៃបញ្ហាស្គមស្គាំងធ្ងន់ធ្ងរត្រូវបានកំណត់ឃើញតាំងពីដំបូង ហើយអ្នកថែទាំដឹងអំពីសេវាសុខភាព និងអាហារូបត្ថម្ភនៅក្នុងតំបន់របស់ពួកគេនឹងចូលរួមនៅក្នុងការប្រើប្រាស់សេវាទាំងនោះជាប្រចាំ សម្រាប់ការបង្ការបញ្ហាខ្វះអាហារូបត្ថម្ភ»។

ដើម្បីឆ្លើយតបនឹងវិបត្តិសកលនេះ យូនីសេហ្វសូមស្នើដល់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានានៅជុំវិញពិភពលោក ត្រូវចាត់អាទិភាពលើការផ្ដល់មូលនិធិបន្ទាន់ សម្រាប់អន្តរាគមន៍ផ្ដល់អាហារព្យាបាល និងការព្យាបាលសម្រាប់កុមារមានបញ្ហាស្គមស្គាំង និងធានាឲ្យមាននូវមូលនិធិសម្រាប់តម្រូវការរយៈពេលវែងនៃកុមារដែលងាយរងគ្រោះបំផុត៕

# យុទ្ធនាការ «ខ្ញុំសន្សំ» ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ

*អត្ថបទ៖ អមរិទ្ធ ដានុត*




ស្របតាមការប្ដេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ យុទ្ធនាការលើបណ្ដាញសង្គមមួយដែលត្រូវបានស្គាល់ថា «ខ្ញុំសន្សំ» ឬ «iSave» ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីប្រសិទ្ធភាពថាមពល។

តាមរយៈការស្វែងយល់និងអនុវត្តទម្លាប់ងាយៗ អ្នកប្រើប្រាស់តាមផ្ទះនិងម្ចាស់អជីវកម្មនឹងអាចកាត់បន្ថយការប្រើប្រាស់ថាមពល ចំណេញថវិកា និងរួមចំណែកបង្កើតបរិស្ថានប្រកបដោយសុខភាព។ «ខ្ញុំសន្សំ» នឹងត្រូវដាក់ឲ្យដំណើរការរយៈពេល ៥ខែ ចាប់ពីខែឧសភា ដល់ខែកញ្ញា ឆ្នាំ២០២។

យុទ្ធនាការ «ខ្ញុំសន្សំ» ត្រូវបានរៀបចំដោយក្រុមហ៊ុន Carbon Trust ដែលជាផ្នែកមួយនៃកម្មវិធីកាត់បន្ថយកាបូនក្នុងតំបន់អាស៊ាន និងអនុវត្តដោយដៃគូរួមមាន ស៊ី អ៊ិនវេសមិន ដែលជាសហគ្រាសសង្គមផ្ដល់ការគាំទ្រដល់សហគ្រាសធុនតូចរបស់សហគ្រិនស្ត្រីនៅក្នុងប្រទេសកម្ពុជា។

លោកស្រី Tina Redshaw ឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំកម្ពុជាបានមានប្រសាសន៍ថា៖ «ការផ្លាស់ប្ដូររបត់ទៅកាន់ថាមពលស្អាតដែលដើរទន្ទឹមគ្នានឹងប្រសិទ្ធភាពថាមពលក្លាយជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដែលធានានូវសន្តិសុខអាកាសធាតុនិងថាមពល និងភាពរុងរឿងសម្រាប់ប្រទេសកម្ពុជានិងពិភពលោកទាំងមូល»។

លោកស្រីបានបន្តថា សន្និសីទក្រុងប៉ារីសលើកទី២៦ របស់អង្គការសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុបានទទួលភាពជោគជ័យដ៏ធំមួយនៅក្នុងទីក្រុង ក្លាសហ្គោ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ក្រោយពីភាគីចំនួន ១៩៧ភាគីបានយល់ព្រមនៅក្នុងកតិកាសញ្ញាអាកាសធាតុទីក្រុងក្លាសហ្គោ មូលមតិគ្នាទៅលើភាពចាំបាច់នៃសកម្មភាពលើអាកាសធាតុ។

លោកស្រី Tina Redshaw បានបញ្ជាក់ថា៖ «ដើម្បីបន្តភាពជោគជ័យមួយនេះនៅក្នុងឆ្នាំ២០២២ និងឆ្លើយតបនឹងគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ការផ្លាស់ប្ដូរជាសកលក្នុងការប្រើប្រាស់ថាមពលស្អាតនិងប្រកបដោយប្រសិទ្ធភាពពិតជាមានការចាំបាច់ខ្លាំងណាស់»។

នៅស្ថានទូតអង់គ្លេសប្រចាំកម្ពុជា ពិតជាមានសេចក្ដីរីករាយក្នុងការបន្តការគាំទ្ររបស់ស្ថានទូតនេះទៅលើប្រទេសកម្ពុជា ក្នុងការឆ្លើយតបនឹងតម្រូវការសម្រាប់សន្តិសុខថាមពលនៅថ្ងៃនេះ និងនាពេលអនាគត។

«ខ្ញុំសន្សំ» ក៏នឹងដើរតួជាវេទិកាមួយដែលដៃគូនានាក្នុងប្រទេសកម្ពុជាដូចជា ស៊ី អ៊ិនវេសមិនជាដើម ក្នុងការអាចចូលរួមចែករំលែកចំណេះដឹងបច្ចេកវិទ្យា និងគំនិតៗថ្មីទាក់នឹងប្រសិទ្ធភាពថាមពល ទៅដល់សហគមន៍របស់ខ្លួនក្នុងប្រទេសកម្ពុជាដែលធ្វើអាជីវកម្មដែលពឹងផ្អែកលើអគ្គិសនីក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ពួកគេ។

នាយកនៃក្រុមហ៊ុន Carbon Trust ប្រចាំតំបន់អាស៊ី និង អាហ្វ្រិក លោក Chris Stephen បានឲ្យដឹងថា មតិដែលបានត្រឡប់មកពីការពិភាក្សាក្រុមបានបង្ហាញថា បើទោះបីជាពួកគេមានការចាប់អារម្មណ៍លើការសន្សំថាមពលក៏ដោយ កង្វះព័ត៌មានដែលទាក់ទងនឹងប្រសិទ្ធភាពថាមពលនៅតែជាបញ្ហាចោទ។

លោកថា ៖ «ខ្ញុំសន្សំ មានគោលបំណងជួយលុបគម្លាតនេះដោយផ្ដល់នូវព័ត៌មាននិងមាតិកាដែលឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ដើម្បីធ្វើឱ្យវាងាយស្រួលសម្រាប់ពួកគេក្នុងការទទួលបានដំបូន្មានដែលពួកគេត្រូវការដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពថាមពល និងដើម្បីដឹងពីអត្ថប្រយោជន៍នៃថាមពលជាដើម»។

គួរបញ្ជាក់ថា «ខ្ញុំសន្សំ» មានគោលបំណងជំរុញនិងលើកទឹកចិត្តដល់សហគ្រិនជាស្ត្រី យុវជន និងសាធារណៈជនអំពីការប្រើប្រាស់ថាមពលប្រកបដោយទំនួលខុសត្រូវ។ តាមរយៈ ទំព័ររបស់ខ្លួន«ខ្ញុំសន្សំ» នឹងផ្ដល់វិធីសាស្ត្រងាយៗ សាមញ្ញ ក៏ដូចជាព័ត៌មាននានា ដែលអាចឲ្យប្រជាជនតាមផ្ទះឬសហគ្រិនអាចប្រើប្រាស់ជាក្បួនណែនាំស្ដីពីការប្រើប្រាស់និងការសម្រេចចិត្តប្រចាំថ្ងៃទាក់ទងនឹងថាមពល៕



# ធនាគារពិភពលោកអនុម័តថវិកា ២០លានដុល្លារអាមេរិក លុបបំបាត់ការបំពុលដោយប្លាស្ទិក

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រុមប្រឹក្សានាយកប្រតិបត្តិនៃធនាគារពិភពលោក នៅថ្ងៃទី២២ ខែមិថុនា បានអនុម័ត កញ្ចប់ថវិកាចំនួន ២០លានដុល្លារអាមេរិក សម្រាប់ជួយដល់រដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ាន ក្នុងការងារលុបបំបាត់ការ បំពុលដោយកាកសំណល់ប្លាស្ទិកក្នុងដែនសមុទ្រក្នុងតំបន់របស់ខ្លួន តាមរយៈកម្មវិធីមួយដែលមានឈ្មោះថា Southeast Asia Regional Program on Combating Marine Plastics (SEA-Map)។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគារពិភពលោក បានឱ្យដឹងថា អាស៊ីអាគ្នេយ៍បានក្លាយជាចំណុចក្តៅមួយនៃការបំពុលដោយកាកសំណល់ប្លាស្ទិក ដោយសារតែមានការរីកលូតលាស់របស់ទីក្រុង និងការកើនឡើងនៃចំនួនមនុស្សវណ្ណៈកណ្តាលយ៉ាងឆាប់រហ័ស។

បញ្ហាបំពុលដោយប្លាស្ទិកនេះបានបង្កឲ្យមានការខាត បង់ច្រើន ក្នុងនោះ គ្រាន់តែក្នុងឆ្នាំ២០១៥ សកម្មភាពសេដ្ឋកិច្ចពាក់ព័ន្ធដែនសមុទ្រនៃបណ្តាប្រទេសសមាជិកអាស៊ាន រងការខូចខាតគិតជាតម្លៃទឹកប្រាក់ ប្រហែល ២,១ប៊ីលានដុល្លារអាមេរិក។ លើសពីនេះទៅទៀត វដ្តជីវិតទាំងមូលរបស់ប្លាស្ទិក រាប់ទាំងសកម្មភាពផលិត និងដឹកជញ្ជូនរបស់វា បានបំភាយឧស្ម័នកាបូនិករាប់ប៊ីលានតោនទៅក្នុងស្រទាប់បរិយាកាស។

សេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ថា ៖ «តាមរយៈកញ្ចប់ថវិកានេះ ធនាគារពិភពលោកនឹងសហការជាមួយអគ្គលេខាធិការដ្ឋានអាស៊ាន និងដៃគូនានានៅកម្រិតតំបន់ និងនៅតាមប្រទេសក្នុងការងារពង្រឹងគោលនយោបាយ និងក្របខណ្ឌបទបញ្ញត្តិដែលគ្រប់គ្រងសកម្មភាពផលិត និងការប្រើ ប្រាស់វត្ថុប្លាស្ទិកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍»។



អនុប្រធានធនាគារពិភពលោកប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក លោកស្រី ម៉ានអេឡូហ្វេរ៉ូ (Manuela V. Ferro) បានលើកឡើងថា ការកាត់បន្ថយការបំពុលដោយប្លាស្ទិកនៅតាមដងទន្លេនិងមហាសមុទ្ររបស់ពិភពលោក ចាំបាច់ត្រូវធ្វើសកម្មភាពនៅកម្រិតប្រទេស និងកិច្ចខិតខំប្រឹងប្រែងរួមជាមួយនឹងការសម្របសម្រួលគ្នាឲ្យបានល្អ។

លោកស្រីបានមានប្រសាសន៍ថា៖«យើងរីករាយក្នុងការជួយរដ្ឋ សមាជិកអាស៊ានក្នុងកិច្ចសហការគ្នាដើម្បីកាត់បន្ថយការបំពុលដោយប្រាស្លឹកទៅក្នុងដែនទឹកទន្លេនិងសមុទ្រ ក៏ដូចជាក្នុងការ ស្វែងរកដំណោះស្រាយចំពោះឥទ្ធិពលអវិជ្ជមាន ដែលកាកសំណល់ប្រាស្លឹកអាចបង្កដល់សេដ្ឋកិច្ច,បរិស្ថាន, អាកាសធាតុ និងសុខភាពរបស់ប្រជាជន»។

តាមរយៈកិច្ចសហការជាមួយរដ្ឋសមាជិកអាស៊ាន ធនាគារពិភពលោក កន្លងមក បានធ្វើការសិក្សាស្ទង់មើលស្ថានភាពទីផ្សារ របស់ប្លាស្ទិកនៅតាមប្រទេសជាក់លាក់ ហើយពេលនេះក៏កំពុងផ្តល់ការគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងផែនទីបង្ហាញ ផ្លូវថ្នាក់ជាតិ សម្រាប់ឈានទៅលុបបំបាត់ជាជំហានៗនូវទម្លាប់ប្រើប្រាស់វត្ថុប្លាស្ទិកតែមួយដងហើយគេវាត់ចោល និងពង្រឹងទម្លាប់កែច្នៃប្លាស្ទិកសម្រាប់ប្រើប្រាស់ឡើងវិញ។

ធនាគារពិភពលោកក៏កំពុងតែផ្តល់ជំនួយហិរញ្ញវត្ថុផងដែរដល់កិច្ចខិតខំប្រឹង ប្រែងនានាក្នុងការគ្រប់គ្រងកាកសំណល់ ដើម្បីលុបបំបាត់ការហូរធ្លាយនៃកាកសំណល់ប្លាស្ទិកទៅក្នុងបរិស្ថាន។

កម្មវិធីនេះនឹង ពង្រឹងគោលនយោបាយ និងស្ថាប័នក្នុងតំបន់លើផ្នែកការងារកែច្នៃកាកសំណល់ប្លាស្ទិកសម្រាប់ប្រើប្រាស់ឡើងវិញ ហើយនឹងបង្កើតវេទិកានានាក្នុងតំបន់សម្រាប់លើកកម្ពស់នវានុវត្តន៍, ចំណេះដឹង និងភាពជាដៃគូក្នុងការកែច្នៃសំណល់ប្លាស្ទិកឡើងវិញ។

លោក Dato Lim Jock Hoi អគ្គលេខាធិការនៃសមាគមអាស៊ាន មានប្រសាសន៍ថា៖ «ដែនសមុទ្រ និងឆ្នេរសមុទ្ររបស់យើង មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជីវិតនិងរបរចិញ្ចឹមជីវិត ក៏ប៉ុន្តែវាកំពុងតែរងសម្ពាធយ៉ាងខ្លាំង ជាពិសេសពីសំណាក់ការបំពុលដោយកាកសំណល់ប្លាស្ទិក ដែលអាចនាំគ្រោះថ្នាក់ដល់សុខភាព និងជះឥទ្ធិពលអវិជ្ជមានទៅលើឧស្សាហកម្ម ទេសចរណ៍និងនេសាទ ដែលមានសារៈសំខាន់មែនទែនសម្រាប់សេដ្ឋកិច្ចក្នុងតំបន់។

លោកថា ៖ «គម្រោងថ្នាក់តំបន់មួយនេះ ជាសក្ខីកម្ម បង្ហាញអំពីការតាំងចិត្ត និងការប្តេជ្ញាចិត្តរបស់រដ្ឋសមាជិកអាស៊ាន ក្នុងការស្វែងរកដោយប្រតិសកម្មនូវដំណោះស្រាយចំពោះ បញ្ហាឆ្លងដែនមួយនេះ ដើម្បីកែលម្អឲ្យប្រសើរឡើងវិញនូវសុខភាពរបស់ផ្ទៃដែនសមុទ្ររបស់យើង ដែលជាទីពឹងពាក់អាស្រ័យ របស់ប្រជាជនជាច្រើននៅក្នុងតំបន់អាស៊ានយើងនេះ»៕

# ករណីលួចនាំចូលជ្រូកខុសច្បាប់ពីប្រទេសជិតខាងនៅតែមាន

*អត្ថបទ៖ អរិយបុត្រ*

សមាគមអ្នកចិញ្ចឹមសត្វកម្ពុជាបានអះអាងថា ករណីលួចនាំចូលជ្រូកដោយខុសច្បាប់មកពីប្រទេសជិតខាងគឺនៅតែមាន ហើយវាគឺជាប្រភពដែលកំពុងតែបង្កការលំបាកដល់អ្នកចិញ្ចឹមនៅក្នុងស្រុក។

ប្រភពដដែលបានអះអាងថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ សមត្ថកិច្ចចម្រុះបានបង្ក្រាប និងស្ទាក់ចាប់បានជ្រូកដែលគេលួចនាំចូលរហូតដល់ចំនួន៨០ក្បាលដែលឈ្មួញលួចឆ្មក់នាំចូលតាមច្រកស្វាយអាង៉ោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយបម្រុងនាំយកទៅចែកចាយនៅរាជធានីភ្នំពេញ។



ប្រតិបត្តិការនេះ បានធ្វើឡើង ដោយមានការសម្របសម្រួលនីតិវិធីពី ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តព្រៃវែង ក្រុមការងារអន្តរាគមន៍បង្ក្រាបបទល្មើសចលនាសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វដឹកនាំដោយផ្ទាល់ពី លោក តាន់ ផាន់ណារ៉ា អគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តព្រៃវែង។

ក្រោយពីបង្ក្រាបបាន ក្រុមមន្ត្រីជំនាញបាននាំយកបទល្មើស និងវត្ថុតាងទាំងនោះទៅរក្សាទុកនៅទីតាំងចត្តាឡីស័កសត្វ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ ។

ប្រភពដដែលបានបន្តថា ក្នុងសកម្មភាពចុះបង្ក្រាបបទល្មើសនេះផងដែរ គេសង្កេតឃើញមានក្រុមឡានស៊ីរ៉ែន ២គ្រឿងបានធ្វើសកម្មភាពចេញមុខកាងការពាររថយន្តល្មើសច្បាប់ក្នុងគោលបំណងអន្តរាគមន៍រំដោះរថយន្តល្មើសច្បាប់នេះ ក៏ប៉ុន្តែនៅតែមិនអាចគេចរួចពីសំណាញ់ច្បាប់ ពីមន្ត្រីជំនាញនោះឡើយ។

ប្រភពដដែលបានអះអាងថា នេះពិតជាការសោកស្តាយ ដែលបុគ្គលតាំងខ្លួនជាមន្ត្រីរូបមួយចំនួន កំពុងតែបំផ្លាញនូវសមិទ្ធផលដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជា ខិតខំជំរុញលើកស្ទួយវិស័យចិញ្ចឹមសត្វក្នុងស្រុក ជាពិសេសការចិញ្ចឹមសត្វលក្ខណៈគ្រួសារ លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

ពាក់ព័ន្ធនឹងការលួចនាំចូលសត្វជ្រូកដោយខុសច្បាប់បែបនេះ លោក ស្រ៊ុន ពៅ ប្រធានសមាគម អ្នកចិញ្ចឹមសត្វកម្ពុជា បានអះអាងប្រាប់អ្នកសារព័ត៌មានថ្មីៗនេះថា ការនាំចូលជ្រូកខុសច្បាប់ដែលបន្តកើតឡើងនឹងបង្កវិនាសដល់ការចិញ្ចឹមជ្រូក ក្នុង ស្រុក។ លោកបានអះអាងថា ប្រទេសកម្ពុជាបានធ្វើការផ្អាកការនាំចូលសត្វជ្រូករស់ចូលពីប្រទេសជិតខាងប្រមាណ១ឆ្នាំមកហើយដោយសារក្តីបារម្ភពីជំងឺប៉េស្ត ជ្រូកអាហ្វ្រិកដែលនៅតែបន្តឆ្លងរាលដាល ប៉ុន្តែនៅតែ មានជ្រូករាប់រយក្បាលត្រូវបានលួចនាំចូលដោយខុសច្បាប់ តាមច្រករបៀងផ្សេង។៕

# ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល ៩ខែ មាន កំណើនចំនួនជិត ២២% ចិននៅតែធំជាងគេ

*អត្ថបទ៖ អរិយបុត្រ*

សហព័ន្ធស្រូវអង្ករកម្ពុជាបានអះអាងថា ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២២ កម្ពុជាបាននាំចេញអង្ករគ្រប់ប្រភេទទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈក្រុមហ៊ុនចំនួន ៥៣ក្រុមហ៊ុន បានអង្ករសរុបចំនួន ២៨៣ ៦៧៥ តោន ដែលគិតជាទឹកប្រាក់ មានចំនួន ១៧៣, ៤៧ លានដុល្លារ។

ប្រភពដដែលបានឲ្យដឹងថា ប្រទេសចិន រួមទាំងតំបន់ស្វយ័តហុងកុង ម៉ាកាវ នៅតែជាប្រទេសនាំចូលអង្ករពីកម្ពុជាច្រើនជាងគេ ដែលមានបរិមាណសរុបបានចំនួន ១៤៩ ៤៤៧ តោន ឬស្មើនឹង ៥២,៦៨% ដែលមាន កំណើនចំនួន ២៣,៦៨% បើធៀបទៅនឹង រយៈពេលដូចគ្នា ក្នុងឆ្នាំ២០២១ ការនាំចេញទៅកាន់ ប្រទេសនានានៅក្នុងទ្វីបអឺរ៉ុប ចំនួន ២៣ប្រទេស បានចំនួន ៨៨ ១៦៧ តោន ឬស្មើនឹង ៣១% មានកំណើន ចំនួន ៤៩,២៦%។



ការនាំចេញទៅកាន់ ប្រទេសក្នុងសមាជិកអាស៊ាន ៤ប្រទេស បានចំនួន ២៥ ៦៩១ តោន ឬស្មើនឹង ៩,០៦% ដែលមានកំណើនចំនួន ១៧,៥៩% និងការនាំ ចេញទៅកាន់គោលដៅផ្សេងៗ ចំនួន ២១ប្រទេសបានចំនួន ២០ ៣៧៦ តោន ឬស្មើនឹង ៧,២០%។

ប្រភពដដែលបានបន្តថា ក្នុងរយៈពេល៩ខែនេះដែរកម្ពុជាបាននាំចេញស្រូវសរុបបានចំនួន ១ ៦៩៨ ៩០៨ តោន ដែល គិតជាទឹកប្រាក់មានចំនួន ៣៩១,៦៩ លានដុល្លារ សម្រាប់អង្ករ គឺមានការនាំចេញ អង្ករក្រអូប គ្រប់ប្រភេទ បានចំនួន ៦៤,១០% អង្ករស ចំនួន ៣៣,១២% អង្ករចំហុយ១,៤២% និងអង្ករសរីរាង្គចំនួន ១,៤២%។

លោក សុង សារ៉ន ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា មានប្រសាសន៍ថា ប្រទេសចិនគឺជាទីផ្សារដ៏ធំសម្រាប់អង្ករកម្ពុជា ហើយកម្ពុជា ត្រូវបានគេរំពឹងថានឹងនាំចេញអង្ករកាន់តែច្រើនទៅកាន់ប្រទេសចិន បន្ទាប់ពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) បានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ ២០២២ ។

លោកថា៖«កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ នេះ នឹងសម្រួលបន្ថែមទៀតដល់ការធ្វើពាណិជ្ជកម្មទំនិញរវាងកម្ពុជានិងចិន ក៏ដូចជាប្រទេសដែលចូលរួមផ្សេងទៀត»។

លោកបានបន្តថា កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ដ៏ធំនេះ ផ្តល់នូវទីផ្សារកាន់តែទូលំទូលាយសម្រាប់ផលិតផលរបស់កម្ពុជា ហើយខ្ញុំគិតថាវានឹងទាក់ទាញអ្នកវិនិយោគបរទេសកាន់តែច្រើនមកបណ្តាក់ទុនក្នុងវិស័យផ្សេងៗ រួមទាំងក្នុងឧស្សាហកម្មអង្ករ ដើម្បីនាំចេញផលិតផលសម្រេចទៅកាន់ប្រទេសសមាជិកនៃកិច្ចព្រមព្រៀងនេះ។៕

# កង្វះខាតជំនាញនៅតែជារបាំងដ៏សំខាន់សម្រាប់ ឱកាសចាប់យកការងាររបស់យុវជននៅអាស៊ាន

*អត្ថបទ៖ អរិយបុត្រ*

ជំងឺរាតត្បាតជាសកលអស់រយៈពេលប្រមាណជា២ឆ្នាំនៅក្នុងតំបន់បានលាតត្រដាងពីភាពងាយរងគ្រោះរបស់យុវជនក្នុងតំបន់អាស៊ានទាំងមូលទាក់ទងនឹងជំនាញរបស់ពួកគេ និងឱកាសនៅក្នុងការបោះជំហានទៅក្នុងអនាគតនៃទីផ្សារការងារ។

លើសពីនេះ ការទទួលបានជំនាញថ្មីរបស់ពួកគេដែលតម្រូវឱ្យអនុវត្តសម្រាប់មុខងារការងារជាក់លាក់មួយមានកម្រិត ដោយសារការតែបញ្ហានៃការខ្វះឱកាស ហិរញ្ញវត្ថុ និងពេលវេលាមិនគ្រប់គ្រាន់សម្រាប់ការបង្កើនជំនាញ និងកម្មសិក្សា។

តាមអត្ថបទវិភាគមួយដែលចុះផ្សាយដោយកាសែតបរទេសនៅក្នុងតំបន់បានឲ្យដឹងថា និន្នាការនេះមានការព្រួយបារម្ភ ដោយសារអនាគតនៃតំបន់ត្រូវបានកំណត់ដោយយុវជនដែលជាពលរដ្ឋវ័យក្មេងមានអាយុពី ១៥ ទៅ ៣៤ ឆ្នាំ ដោយបច្ចុប្បន្ននេះមានចំនួនប្រមាណជា ៣៤% ឬប្រហែល ២២៣ លាននាក់នៃចំនួនប្រជាជនសរុបនៅក្នុងប្រទេសសមាជិកទាំង ១០ នៃប្លុកអាស៊ានទាំងមូល។

ដោយយល់ពីសារៈសំខាន់នៃតួនាទីរបស់ពួកគេ ប្រទេសកម្ពុជានៅក្នុងនាមជាប្រធានអាស៊ានម្តងវេននៅឆ្នាំ ២០២២ បានប្រកាសយកឆ្នាំនេះ ជាឆ្នាំនៃយុវជនអាស៊ាន។ សម្តេច ហ៊ុន សែន ក្នុងឋានៈជាប្រធានអាស៊ានឆ្នាំ២០២២ បានសន្យាថា បញ្ហាយុវជនជាអាទិភាពរបស់កម្ពុជាក្នុងការ «ពង្រឹងការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋានសម្រាប់ការកសាងសហគមន៍ លើកកម្ពស់ការចូលរួមរបស់ស្ត្រី និងយុវជនក្នុងការកសាង និងរក្សាសន្តិភាព និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមរួម»។

រហូតមកដល់ពេលនេះ យុវជនកំពុងដើរតួយ៉ាងសំខាន់ក្នុងការកំណត់អនាគតនៃតំបន់ អត្រាអត់ការងារធ្វើសម្រាប់កម្មករវ័យក្មេង ដែលមានអាយុក្រោម ៣៤ ឆ្នាំ នៅក្នុងតំបន់អាស៊ានគឺខ្ពស់រួចទៅហើយមុនពេលជំងឺរាតត្បាតផ្ទុះឡើងពោលគឺកាលពីឆ្នាំ ២០១៩ មានអត្រាអត់ការងារធ្វើរហូតដល់ទៅ ៨,៩ភាគរយ ហើយដោយសារតែជំងឺរាតត្បាតកូវីដ ១៩ អត្រានេះបានឡើង១១,៣ ភាគរយនៅឆ្នាំ ២០២១ ។

តាមតួលេខនេះបង្ហាញថា យុវជនអាស៊ានទាំងមូលមានចំនួនប្រហែលជា ២៥,៤លាននាក់នៅក្នុងតំបន់ត្រូវបានទុកឱ្យគ្មានការងារធ្វើក្នុងអំឡុងពេលការរឹតបន្តឹងដោយសារតែការរីករាលដាល នៃមេរោគកូវីដ-១៩ ។ ជាលទ្ធផល កម្មករវ័យក្មេងជាច្រើននាក់ ដែលកំពុងសិក្សានៅពេលកំពុងធ្វើការបានបាត់បង់ការងារ និងប្រាក់ចំណូល ហើយជាលទ្ធផលត្រូវបញ្ឈប់ការសិក្សារបស់ពួកគេ ដែលជាស្ថានភាពធ្ងន់ធ្ងរដែលអង្គការពលកម្មអន្តរជាតិ (ILO) ពិពណ៌នាថាជា «រឿងរន្ធត់រហូតដល់ទៅ៣ដង»។

ក្នុងរយៈពេលនេះ ម៉ោងធ្វើការនៅអាស៊ានបានធ្លាក់ចុះយ៉ាងខ្លាំងពោលគឺប្រមាណជា ៨,៤ភាគរយ ដែលនាំឲ្យប៉ះពាល់ដល់ពលករវ័យក្មេងប្រមាណជា ២៤ លាននាក់ដែលពីមុនធ្វើការពេញម៉ោងពោល គឺ ៤៨ ម៉ោងនៅក្នុងមួយសប្តាហ៍។ មិនតែប៉ុណ្ណោះនិន្នាការនៃការផ្លាស់ប្តូរបានធ្វើឲ្យយុវនិសិត្សដែលទើបតែបញ្ចប់ពីសាកលវិទ្យាល័យ និងសាលាថ្មីៗជាង ១៥លាននាក់នៅទូទាំងតំបន់មិនអាចចាប់ផ្តើមដំណើរការអាជីពរបស់ខ្លួនបានទេ។

មិនត្រឹមតែកម្មករវ័យក្មេងជួបប្រទះនឹងទីផ្សារការងារដែលដួលរលំទេ ទិដ្ឋភាពនៃការងារ ការសិក្សា និងការរស់នៅទូទៅក៏មានការផ្លាស់ប្តូរយ៉ាងខ្លាំងផងដែរ។ ការបិទខ្ទប់បានបង្ខំឲ្យប្រជាជន កម្មករ និងជាពិសេសសិស្សនិស្សិត ទៅកាន់បច្ចេកវិទ្យាឌីជីថល ដែលជាមធ្យោបាយសុវត្ថិភាពសម្រាប់ការទំនាក់ទំនង និងប្រតិបត្តិការ។

ពាក់ព័ន្ធនឹងបញ្ហានេះការសិក្សាមួយបង្ហាញថា ចាប់តាំងពីការផ្ទុះឡើងដំបូងនៃជំងឺរាតត្បាតកូវីដ ១៩ ការប្រើប្រាស់អ៊ីនធឺណិតបានកើនឡើងពី ៥០ភាគរយ ទៅ ៧០ ភាគរយ ។

ជាមួយនឹងបញ្ហានេះ ទោះបីជាមានការប្រើប្រាស់អ៊ីនធឺណិតខ្លាំងក្លាយ៉ាងណាក៏ដោយក៏យុវជនអាស៊ានប្រហែលជាមិនមានជំនាញគ្រប់គ្រាន់សម្រាប់ការងារដែលកំពុងរីកចម្រើននោះទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ជំនាញឌីជីថលក្នុងចំណោមយុវជនអាស៊ានប្រហែលជាមិនគ្រប់គ្រាន់សម្រាប់មុខតំណែងការងារដែលត្រូវការជំនាញកម្រិតខ្ពស់នោះទេ។

ជាឧទាហរណ៍ យុវជន ប្រមាណជា ៤៧,៨ ភាគរយ មានជំនាញឌីជីថលជាមូលដ្ឋាន «គ្មាន» ឬ «ទាប» មានន័យថា យុវជនស្ទើរតែម្នាក់ក្នុងចំនោមយុវជនពីរនាក់នៅក្នុងអាស៊ាន មិនអាចអនុវត្តមុខងារជាមូលដ្ឋាននៃកម្មវិធីការងារបានគ្រប់គ្រាន់ នេះបើយោងតាមតួលេខរបស់មូលនិធិអាស៊ាន និង Google.org លើទីផ្សារការងារយុវជន និងតម្រូវការជំនាញសម្រាប់អនាគត។ អាក្រក់ជាងនេះទៅទៀត របាយការណ៍ដដែលនេះផ្តល់នូវស្ថិតិគួរឱ្យព្រួយបារម្ភដែលថាជិតបីភាគបួននៃយុវជន អាស៊ានមិនមានជំនាញឌីជីថលជ្រៅជ្រះទេ។

ដោយខ្វះជំនាញឌីជីថលដែលត្រូវការច្រើន យុវជនទាំងនេះស្វែងរកផ្លូវឆ្ពោះទៅមុខដោយក្លាយជា «អ្នកធ្វើការដោយខ្លួនឯង» ឬ«សហគ្រិន»។ ការសិក្សានេះបង្ហាញឱ្យឃើញបន្ថែមទៀតថា ៣៥,៣ ភាគរយ នៃយុវជនអាស៊ានដែលស្វែងរកឱកាសធ្វើជាសហគ្រិន គឺជាប់លំដាប់កំពូលក្នុងបញ្ជី បន្ទាប់មកអាជីពក្នុងរដ្ឋាភិបាល មានប្រមាណជា ២៦,២ ភាគរយ ក្នុងប្រព័ន្ធផ្សព្វផ្សាយ មាន ២០,៦ ភាគរយ ហើយនៅក្នុងវិស័យបច្ចេកវិទ្យាវិញគឺមាន តែ១៨,២ ភាគរយនៃយុវជនដែលប្រាថ្នាចង់ធ្វើការនៅក្នុងវិស័យនេះ។

ទាំងនេះគឺជាព័ត៌មានជារួមនៃបញ្ហាទាក់ទងនឹងស្ថានភាពការងារធ្វើរបស់ក្រុមយុវជន នៅទូទាំង តំបន់ ដូច្នេះ វាគឺជាបទពិសោធន៍មួយដែលយុវជនកម្ពុជា ត្រូវតែរិះគិត ហើយខិតខំធ្វើយ៉ាងណា ព្យាយាមបង្កើតឱកាស និងចាប់ឱកាសការងារ ហើយសម័យនេះ គឺត្រូវតែបង្កើនសមត្ថភាព ទាក់ទងនឹងឌីជីថល៕

# ផ្សិតព្រៃក៏មានតម្លៃសម្រាប់ ទីផ្សារម្ហូបអាហារនៅក្នុងប្រទេស







*អត្ថបទ៖ អរិយបុត្រ*

រហូតមកដល់ពេលបច្ចុប្បន្ននេះផ្សិតមានច្រើនប្រភេទកំពុងបង្ហាញវត្តមាននៅលើទីផ្សារ ប៉ុន្តែ ដោយឡែកផ្សិតព្រៃគឺកម្រមានណាស់ ប៉ុន្តែវាក៏ជាអនុផលមានតម្លៃសម្រាប់បម្រើការហូបចុក របស់ប្រជាពលរដ្ឋផងដែរ ជាពិសេសនៅអំឡុងពេលភ្លៀងធ្លាក់ដើមរដូវនេះ ។

អង្គការសត្វស្លាបអន្តរជាតិបានឲ្យដឹងកាលពីពេលថ្មីៗកន្លងទៅនេះថា ប្រជាពលរដ្ឋស្រុកលំផាត់ នៃខេត្តរតនៈគិរី កំពុងមមាញឹកជាមួយការប្រមូលផលអនុផលព្រៃឈើពិសេសផ្សិតព្រៃ។

ប្រភពដដែលបានបន្តថា ក្នុងឆ្នាំនេះមានផ្សិតព្រៃពីរប្រភេទគឺផ្សិតក្រោកនិងផ្សិតអំបោះនៅក្នុងដែនជម្រកសត្វព្រៃលំផាត់ ខេត្តរតនគិរី ដែលត្រូវបានប្រជាពលរដ្ឋបានចូលមកប្រមូលសម្រាប់ហូបចុក និងដោះដូរជីវភាពដោយតាមការសម្ភាសរបស់ក្រុមការងារសហគមន៍អង្គការជីវិតធម្មជាតិនៅកម្ពុជា ពលរដ្ឋក្នុងម្នាក់ៗ អាចដកផ្សិតបានពី៥ដល់១០គីឡូក្រាមតាមស្ថានភាពជាក់ស្តែងនិងកត្តាអំណោយផល។

ប្រភពដដែលបានបន្តថា ប្រជាពលរដ្ឋដែលរកបានច្រើនគាត់លក់ខ្លះនិងទុកខ្លះដើម្បីធ្វើជាអាហារ។ ក្នុងនោះផងដែរផ្សិត១គីឡូក្រាមលក់បាន៥.០០០ ទៅ ១.២០០០រៀល ខណៈដែលឈ្មួញខ្លះក្នុងមួយថ្ងៃទិញបានចន្លោះពី៥០០ទៅ១.០០០គីឡូក្រាម ។

លោកស្រី ដេត សុធា ជាស្ត្រីមេផ្ទះមួយរូបបានឲ្យដឹងថា ផ្សិតគឺជាបន្លែដែលក្រុមគ្រួសារលោកស្រីបានចូលចិត្ត ហើយប្រសិនបើបានផ្សិតធម្មជាតិពីព្រៃវារិតតែជាចំណូលចិត្តរបស់គ្រួសារ ។

លោកស្រីបានបន្តថា ៖ «ផ្សិតធម្មតា យើងអាចទិញកន្លែងណាក៏បាននៅភ្នំពេញ តែពពួកផ្សិតធម្មជាតិដែលដុះតាមព្រៃ គឺមានរដូវ មានខែវាដុះ យូៗបានហូបម្តង គឺវាមានរស់ជាតិប្លែក»។

លោកស្រីបានបន្តថា សព្វថ្ងៃនេះនៅតាមទីផ្សារផ្សិតមានច្រើនប្រភេទ ហើយមួយចំនួនទំនងជានាំចូលដោយសារតែមានអក្សរបរទេស ហើយមួយចំនួនប្រហែលជាកសិករយើងអាចផលិតបាន ឃើញសំបូរដូចជាផ្សិតចំបើង ផ្សិតអំបោះជាដើម ។

លោកស្រីបានបន្ថែមថា ខែនេះ ប្រសិនបើបានធ្វើដំណើរទៅតាមខេត្តដែលមានព្រៃឈើដូច ជាភូមិភាគឥសាន្ត គឺទំនងជាបានទទួលទានផ្សិតធម្មជាតិច្រើនជាពិសេសគឺពពួកផ្សិត ក្រោក និង ពពួកផ្សិតធម្មជាតិផ្សេងទៀត ប៉ុន្តែក៏ត្រូវប្រយ័ត្នដែរ ពីព្រោះផ្សិតខ្លះអាចពុល គ្រោះថ្នាក់ ដល់ជីវិតប្រសិនបើមិនចេះមើល៕

# មន្ត្រីរដ្ឋាភិបាល៖ គោលការណ៍ដោះដូរទីតាំងដីធ្វើការអភិវឌ្ឍ មិនប៉ះជាន់ផ្ទៃដីសួនសត្វភ្នំតាម៉ៅឡើយ

## ខណៈអ្នកជំនាញអភិរក្សសត្វ បារម្ភខ្លាចបាត់បង់



*អត្ថបទ៖ អមរិន្ទ ដានុត*

ឧទ្យានសួនសត្វភ្នំតាម៉ៅនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងសាប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ មានចំងាយ ៤០គ.ម តាមផ្លូវជាតិលេខ២ពីរាជធានីភ្នំពេញ។ ភ្នំនេះជារម្មណីយដ្ឋានចំរុះមានប្រាង្គប្រាសាទ ព្រៃភ្នំធម្មជាតិ និងជាសួនសត្វដ៏ធំក្នុងប្រទេសកម្ពុជា។

ភ្ញៀវជាតិនិងអន្តរជាតិដែលមកលេងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ មិនដែលរំលងទស្សនាសត្វកម្រ ៦ ប្រភេទមានដូចជា ពោះថ្លាន់ ក្រពើ ខ្លា តោ ដំរី និង ខ្លាឃ្មុំ។ សត្វទាំងនេះមានប្រជាប្រិយភាពខ្លាំង និងស្ថិតនៅក្នុងបញ្ជីលើគេដែលទាក់ទាញភ្ញៀវទេសចរច្រើនបំផុតទស្សនាពេលមកកម្សាន្តនៅសួនឧទ្យានភ្នំតាម៉ៅ។

ថ្មីៗនេះ មានព័ត៌មានជាច្រើនបានធ្វើការផ្សព្វផ្សាយអំពីសួនសត្វភ្នំតាម៉ៅថានឹងត្រូវការដោះដូរដីមួយផ្នែកដើម្បីធ្វើការអភិវឌ្ឍក្បែរសួនសត្វភ្នំតាម៉ៅ ដែលធ្វើឱ្យប្រជាពលរដ្ឋ ពិសេសអង្គការអភិរក្សសត្វមានការបារម្ភជាខ្លាំងពីការប៉ះពាល់និងបាត់បង់សត្វព្រៃ និងសត្វកម្រនៅក្នុងរមណីយដ្ឋានមួយនេះនៅពេលមានការអភិវឌ្ឍ។

លោក ខូយ យុនហ៊្សរ រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី បានលើកឡើងថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ដោះដូរទីតាំងដីស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ទំហំ៣០០ហិកតា និងទីតាំងដីរដ្ឋបាលព្រៃឈើភ្នំតាម៉ៅ ទំហំ៥០០ហិកតា ស្ថិតនៅឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ជាមួយក្រុមហ៊ុន ខ្មែរ ហ្វ្រេស មីល និងអនុញ្ញាតផ្ទេរកម្មសិទ្ធិឲ្យក្រុមហ៊ុននិងដៃគូសហការមុនធ្វើការអភិវឌ្ឍ ព្រមទាំងរាល់ការបង់ពន្ធប្រថាប់ត្រាជាបន្ទុករបស់រដ្ឋ ជាថ្នូរនឹងទ្រព្យសម្បត្តិមួយចំនួន។

លោក ខូយ យុនហ៊្សរ បានលើកឡើងដូចនេះតាមរយៈលិខិតចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ផ្ញើជូនរដ្ឋមន្ត្រីក្រសួងចំនួន៣ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម រួមនឹងអភិបាលខេត្តតាកែវផងដែរ។

ទ្រព្យសម្បត្តិដែលជាថ្នូរក្នុងការដោះដូរនេះមាន៖ ទីតាំងទី១ គឺទីតាំងដីស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ទំហំ៣០០ហិកតា ស្ថិតនៅភូមិឬក្ខាសាំង ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ជាថ្នូរនឹងដីដែលមាន ទំហំ៤០០ហិកតា ស្ថិតនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ អគាររដ្ឋបាលទំហំ ១១ម x ២១ម មានជាន់ E0 និង E1 ប្រក់ដំបូលក្បឿង ចំនួន១ខ្នង, អគារស្នាក់នៅទំហំ ១៦ម x ៣៦ម ដំបូលក្បឿង ចំនួន១ខ្នង, ក្រោលគោទំហំ ៣២ម x ៤៥ម ដំបូលស័ង្កសី PU ចំនួន២ខ្នង, ឃ្លាំងចំណីសត្វទំហំ ១៥ម x ២៥ម ដំបូលស័ង្កសី PU ចំនួន២ខ្នង។

ទីតាំងសម្រាប់ជាថ្នូរក្នុងការដោះដូរក៏មានឃ្លាំងសម្ភារៈទំហំ ១៥ម x ២០ម ដំបូលស័ង្កសី PU ចំនួន១ខ្នង, កន្លែងសម្លាប់មេរោគទំហំ ៥មx១០ម ២កន្លែង, រថយន្ត Van ១២កៅអី ចំនួន១គ្រឿង, រថយន្ត Pick Up ចំនួន៥គ្រឿង, ត្រាក់ទ័រចនឌារ ៩០សេះ ចំនួន២គ្រឿង, ត្រាក់ទ័រចនឌា៥០សេះ ចំនួន២គ្រឿង, ទោចក្រយានយន្ត ចំនួន៥០គ្រឿង, គ្រឿងសង្ហារឹម, ប៉ុស្តិ៍យាម, ភ្ជាប់បណ្តាញអគ្គីសនី បណ្តាញទឹកប្រព័ន្ធស្រោចស្រពវាលស្មៅ ប្រព័ន្ធផ្លូវគមនាគមន៍ តភ្ជាប់ផ្លូវធ្វើដំណើរក្នុងទីតាំង និងរបងលួសបន្លាព័ទ្ធជុំវិញទីតាំងដី។

> ខ្ញុំបានធ្វើការជាអ្នកអភិរក្សសត្វព្រៃនៅស្រុកខ្មែរ២០ឆ្នាំ ហើយ ខ្ញុំជាមនុស្សតូចតាចមិនមានអំណាច តែខ្ញុំមានបេះដូងស្រលាញ់សត្វនិងធម្មជាតិ។ ខ្ញុំនិងអ្នកអភិរក្សផ្សេងទៀតសូមសំណូមពរដល់សម្តេចហ៊ុន សែន ជួយការពារព្រៃភ្នំតាម៉ៅដដែលដើម្បីទុកជាជម្រកសត្វព្រៃនិងជាកន្លែងកម្សាន្តធម្មជាតិដ៏ល្អសម្រាប់ប្រជាជន

ចំណែកទីតាំងទី២ គឺទីតាំងឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ ទំហំ៥០០ហិកតា ស្ថិតនៅឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ជាថ្នូរនឹងបង្កើតសួនសត្វ Satari Angkor លើផ្ទៃដី ទំហំ២៥០ហិកតា ស្ថិតក្នុងស្ថានីយស្តារ និងអភិវឌ្ឍន៍ព្រៃឈើបន្ទាយស្រី ក្នុងស្រុកបន្ទាយស្រី និងស្រុកស្វាយលើ ខេត្តសៀមរាប ដែលរួមមានការសាងសង់អគាររដ្ឋបាល អគារបត្តាឡីស័ក អគារព្យាបាលសត្វព្រៃ សាងសង់របងព័ទ្ធជុំវិញ សាងសង់ផ្លូវ រៀបចំទីតាំងអភិវឌ្ឍន៍នានា ទិញ



> ការដោះដូរផ្ទៃដីតំបន់ភ្នំតាម៉ៅ ជាការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមូលដ្ឋាន ព្រមទាំងផ្តល់បន្ថែមទៀតនូវទុនសម្រាប់ការអភិវឌ្ឍ គម្រោងយុទ្ធសាស្ត្រនានាជំរុញនិងកែសម្ផឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅអាចប្រកួតប្រជែង ក្នុងបរិបទសេដ្ឋកិច្ចបច្ចុប្បន្ន ព្រមទាំងជំរុញកំណើនចំណូលជានានិរន្តរភាពផងដែរ






សម្ភារបរិក្ខារ និងតបណ្តាញទឹក ភ្លើងជាដើម។

វាក៏ជាថ្នូរនឹងការបង្កើតឡើងនៃសួនភូតគាម «មណ្ឌលគិរី» មានផ្ទៃដី ៤៧២,៨០៩ ហិកតា នៅស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលរួមមានការសាងសង់សួនផ្កាទំហំ ២០ហិកតា រៀបចំប្រព័ន្ធផ្លូវ ប្រព័ន្ធស្រោចស្រព កសាងទំនប់បង្អៀរ សាងសង់អគាររដ្ឋបាល អគារសម្រាកលំហែដែល មាន ៣០បន្ទប់ ថ្នាលបណ្តុះកូនឈើនិងផ្កា តបណ្តាញទឹក ភ្លើង និងទិញសម្ភារៈបរិក្ខារជាដើម។

ប្រភពដដែលបន្តថា មានការចាក់ថ្នល់កៅស៊ូនៅក្នុងបរិវេណក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ទិញរថយន្តថ្មី suv ចំនួន១គ្រឿង រថយន្ត Ford Raptor ចំនួន៣គ្រឿង រថយន្តFord Ranger ចំនួន៦គ្រឿង និងម៉ូតូចំនួន២០គ្រឿង។

ផ្តល់កម្មសិទ្ធិឯកជន ទំហំ៩,៨ ហិកតា ស្ថិតនៅឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដែលអាចសាងសង់ផ្ទះស្នាក់នៅអចិន្ត្រៃយ៍ជូនមន្ត្រី បុគ្គលិក និងកម្មករចំនួន៨៥នាក់ នៃឧទ្យានសួនសត្វ និងមជ្ឈមណ្ឌល សង្គ្រោះសត្វព្រៃភ្នំតាម៉ៅ។

បើតាមការបញ្ជាក់ក្នុងលិខិតរបស់លោក ខូយ យុនហ៊្សរ តម្លៃដោះដូរត្រូវមានការឯកភាពពីគណៈកម្មាធិការឯកជនភាវូបនីយកម្មផងដែរ។

ទាក់ទងនឹងការដោះដូរនេះ លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់ថា ការអភិវឌ្ឍនៅតំបន់ភ្នំតាម៉ៅ មិនប៉ះពាល់លើផ្ទៃដីឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅដែលមានទំហំជាង ៤០០ ហិកតាមានរបងព័ទ្ធជុំវិញ និងមានហេដ្ឋារចនាសម្ព័ន្ធនានាដែលបានអភិវឌ្ឍកន្លងមកនោះទេ។

លោកបានលើកឡើងដូចនេះតាមរយៈលិខិតដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០២២ ថា ករណីសំណើសុំការអនុញ្ញាតជាគោលការណ៍ដោះដូរទីតាំងដីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនប៉ះជាន់លើផ្ទៃដីឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅដែលមានទំហំជាង៤០០ ហិកតា និងមានរបងព័ទ្ធជុំវិញជាង៨ ៣៩៤ម៉ែត្រ និងមានហេដ្ឋារចនាសម្ព័ន្ធនានាដែលបានអភិវឌ្ឍកន្លងមកនោះទេ។

លោកបានបញ្ជាក់ថា វាក៏មិនប៉ះពាល់ទៅដល់ការសហការជួយរបស់អង្គការ Wildlife Alliance ឬការអនុវត្តអនុស្សរណៈយោគយល់គ្នា រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ Wildlife Alliance ផងដែរ។












លោក វេង សាខុន បានបន្ថែមថា ៖ «ការដោះដូរផ្ទៃដីតំបន់ភ្នំតាម៉ៅ ជាការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមូលដ្ឋាន ព្រមទាំងផ្តល់បន្ថែមទៀតនូវទុនសម្រាប់ការអភិវឌ្ឍ គម្រោងយុទ្ធសាស្ត្រនានាជំរុញនិងកែសម្ផឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅអាចប្រកួតប្រជែង ក្នុងបរិបទសេដ្ឋកិច្ចបច្ចុប្បន្ន ព្រមទាំងជំរុញកំណើនចំណូលជានានិរន្តរភាពផងដែរ»។

លោក នីច ម៉ាក អ្នកជំនាញអភិរក្សសត្វព្រៃនៅអង្គការសម្ព័ន្ធមិត្តសត្វព្រៃបានថ្លែងក្នុងវីដេអូបង្ហោះលើហ្វេសប៊ុកកាលពីថ្ងៃទី ១៦ ខែឧសភា ថា ភ្នំតាម៉ៅ មិនត្រឹមតែជាសួនសត្វប៉ុណ្ណោះទេ ប៉ុន្តែវាជាផ្ទះសម្រាប់សត្វរាប់ពាន់ក្បាលដែលហ៊ុមព័ទ្ធដោយព្រៃឈើ ដែលមានសារៈសំខាន់សម្រាប់ការអភិរក្ស។

ដោយសារមានកិច្ចសហការដ៏ល្អរវាងរដ្ឋបាលព្រៃឈើ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃអស់រយៈពេល២០ឆ្នាំ ភ្នំតាម៉ៅបានក្លាយជាទីតាំងដ៏សំខាន់សម្រាប់ការស្តារសត្វព្រៃឡើងវិញ និងអភិរក្សសត្វព្រៃ។ ភ្នំតាម៉ៅជាសួនសត្វដែលល្អមួយជាងសួនសត្វផ្សេងៗ ដោយសារតែភ្នំតាម៉ៅជាកន្លែងធម្មជាតិ មានព្រៃជុំវិញស្អាត។

លោកបានថ្លែងថា ៖ «ខ្ញុំបានធ្វើការជាអ្នកអភិរក្សសត្វព្រៃនៅស្រុកខ្មែរ២០ឆ្នាំហើយ ខ្ញុំជាមនុស្សតូចតាចមិនមានអំណាច តែខ្ញុំមានបេះដូងស្រលាញ់សត្វនិងធម្មជាតិ។ ខ្ញុំនិងអ្នកអភិរក្សផ្សេងទៀត សូមសំណូមពរដល់សម្តេចហ៊ុន សែន ជួយការពារព្រៃភ្នំតាម៉ៅដដែលដើម្បីទុកជាជម្រកសត្វព្រៃនិងជាកន្លែងកម្សាន្តធម្មជាតិដ៏ល្អសម្រាប់ប្រជាជនផងដែរ»។

គួរបញ្ជាក់ថា បច្ចុប្បន្នឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះ សត្វព្រៃភ្នំតាម៉ៅបានដើរតួនាទីយ៉ាងសំខាន់ជាកន្លែងសង្គ្រោះ ព្យាបាលសត្វព្រៃ របួស ស្រ្តេស ពិការ ឈឺ សត្វព្រៃដែលម្ចាស់អស់និស្ស័យ សត្វព្រៃដែលបង្ក្រាបបានពីការជួញដូរខុសច្បាប់ និងចិញ្ចឹមថែរក្សាទុកសត្វព្រៃដែលមិនមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់អាចលែងទៅទីជម្រកដើមបានសម្រាប់ប្រើប្រាស់ជាកម្មវត្ថុនៃការងារអប់រំផ្សព្វផ្សាយអំពី សត្វព្រៃ។

ជាមួយនឹងតួនាទីទាំងនេះ ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ ត្រូវបានអភិវឌ្ឍ និង ពង្រឹងខ្លួនដោយបានសាងសង់របងសុវត្ថិភាពរឹងមាំប្រវែង៨ ៣៩៤ម៉ែត្រ ហ៊ុមព័ទ្ធជុំវិញផ្ទៃដីជាង៤០០ហិកតា ក្នុងនោះបានធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានាមានផ្លូវថ្នល់ ទ្រុងសត្វ សួនច្បារ អគារសារមន្ទីរ អគារអប់រំ ប្រព័ន្ធផ្គត់ផ្គង់ទឹក បណ្តាញអគ្គិសនី អគារការិយាល័យដើម្បីបម្រើឱ្យសេវាការសង្គ្រោះ ការព្យាបាល ការសិក្សាស្រាវជ្រាវ ការអប់រំ និងទេសចរណ៍ និងកំពុងចិញ្ចឹមថែរក្សា បង្កាត់ពូជសត្វព្រៃចំនួន ១១៨ ប្រភេទ ស្មើនឹង១ ៦៧៨ក្បាល៕

# កូនកន្ធាយក្បាលកង្កែបឬល្បិច ជិត ៦០០ ក្បាល ត្រូវបានព្រលែងអបអរសាទរទិវាអណ្តើកពិភពលោក

*អត្ថបទ៖ អមរិន្ទ ដានុត*

កូនកន្ធាយក្បាលកង្កែបឬល្បិចដែលជាប្រភេទជិតផុតពូជបំផុតចំនួន ៥៨០ក្បាលត្រូវបានព្រលែងចូលទៅក្នុងទីជម្រកធម្មជាតិតាមដងទន្លេមេគង្គនៅខេត្តក្រចេះ ដើម្បីចូលរួមអបអរសាទរទិវាអណ្តើកពិភពលោក។

អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដោយមានការសហការជាមួយរដ្ឋបាលជលផល និង ខណ្ឌរដ្ឋបាលជលផលក្រចេះ បានលែងកូនកន្ធាយក្បាលកង្កែបឬល្បិចដែលជាប្រភេទជិតផុតពូជបំផុតចំនួន ៥៨០ ក្បាលចូលទៅក្នុងទីជម្រកធម្មជាតិតាមដងទន្លេមេគង្គនៅខេត្តក្រចេះ។

លោក កែន សេរីរដ្ឋា នាយកអង្គការ WCS បានលើកឡើងថា ដោយមានការគាំទ្រជាបន្តបន្ទាប់ពី ម្ចាស់ជំនួយ និងមានកិច្ចសហប្រតិបត្តិការល្អពីរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន ព្រមទាំង មានការប្តេជ្ញាចិត្តខ្ពស់របស់បុគ្គលិកនៅទីវាលនិងក្រុមការពារសំបុកសហគមន៍ អង្គការ WCS សម្រេចបាន នូវសមិទ្ធផលជាច្រើនគួរឲ្យកត់សម្គាល់ក្នុងការអនុវត្តគម្រោងរបស់ខ្លួនក្នុងរយៈពេលជាច្រើនឆ្នាំ កន្លងមក។

លោក សេរីរដ្ឋា បានបន្ថែមទៀតថា ៖ «កំណើននៃសំបុកនិងពងកន្ធាយបានជំរុញនិងលើកទឹកចិត្តយើងឱ្យខិតខំ ប្រឹងប្រែងបន្តទៀតដើម្បីអភិរក្សកន្ធាយក្បាលកង្កែបដែលកំពុងទទួលរងគ្រោះជិតផុតពូជបំផុតនេះ»។

លោកបានបន្តថា ៖ «ក៏ប៉ុន្តែ កន្ធាយប្រភេទនេះកំពុងទទួលរងការគំរាមកំហែងដោយសារការប្រមាញ់និងការជួញដូរខុសច្បាប់។ នៅឆ្នាំ២០២១ យ៉ាងហោចណាស់មានកន្ធាយក្បាលកង្កែបចំនួន ៩ក្បាល ត្រូវបានគេជួញដូរតាមប្រព័ន្ធអនឡាញ និង២ក្បាល បានស្លាប់ដោយសារការនេសាទខុសច្បាប់»។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានឱ្យដឹងថា នៅក្នុងរដូវពងកូនឆ្នាំ ២០២២ នេះ ក្រុមការពារសំបុកសហគមន៍បានរកឃើញសំបុកកន្ធាយក្បាលកង្កែបចំនួ ៦៣សំបុក ស្មើនឹង ២ ១៥៥ ពង។ គិតត្រឹមពីដើមខែមីនាដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ មានកូនកន្ធាយក្បាលកង្កែបសរុបចំនួន ៩៨២ កូនបានញាស់ចេញពីសំបុកចំនួន ៤០ សំបុក ហើយក្រុមការងារ បានលែងកូនកន្ធាយចំនួន ៤០២ក្បាលចូលក្នុងទីជម្រកធម្មជាតិវិញ និងនៅសល់ ៥៨០ក្បាលទៀត ត្រូវលែងនៅក្នុងទិវាអណ្តើកពិភពលោកនេះ។

យក្រុមការងាររំពឹងថាពងដែលនៅសេសសល់អាចនឹងញាស់បានខ្លះបន្ថែមទៀត។

ប្រភពដដែលបានបន្តថា កាលពីរដូវពងកូនឆ្នាំ២០២១ ក្រុមការងារបានរកឃើញ ៦៦សំបុក ស្មើនឹង ២ ៥២៨ ពង និងបានលែង ១ ៣០០ កូន ចូលក្នុងទីជម្រកធម្មជាតិវិញ។

លោក អ៊ុក វិបុល ប្រធាននាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផល បានឱ្យដឹងថា លោកអបអរសាទរយ៉ាងក្រៃលែងចំពោះការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ ប្រជាពលរដ្ឋ និងជា ពិសេសអង្គការ WCS ដែលបាននឹងកំពុងស្តារប្រភេទដែលកំពុងរងគ្រោះថ្នាក់នេះឲ្យមានវត្តមានក្នុងដែន ទឹក ធម្មជាតិនេះឡើងវិញ។

លោកក៏បានស្នើឲ្យភាគីពាក់ព័ន្ធបន្តកិច្ចការស្តារប្រភេទកន្ធាយនេះ ព្រមទាំង ក្រើនរំលឹកដល់ជនមួយចំនួន ដែលនៅតែបន្តជួញដូរប្រភេទសត្វនេះ នឹងត្រូវទទួលទោសចំពោះមុខច្បាប់។



ចំណែក លោក ក្លេមីន បេគ័រ (Clemens Beckers) តំណាងប្រតិភូសហភាពអឺរ៉ុប បានថ្លែងថា៖ «ប្រទេសកម្ពុជាមានទីជម្រកនិងសត្វព្រៃដ៏សម្បូរបែបជាច្រើនប្រភេទ។ កន្ធាយក្បាលកង្កែបគឺជាប្រភេទដ៏កម្រមួយដែលត្រូវការ ការពារជាបន្ទាន់»។

សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន រដ្ឋបាលជលផល និងអង្គការ WCS ត្រូវតែបន្តកិច្ច ខិតខំប្រឹងប្រែងរួមគ្នាដើម្បីការពារនិងស្តារប្រភេទដ៏កម្រនេះឡើងវិញ។ ទាំងអស់គ្នាមានគោលដៅរួមតែមួយក្នុងការជួយសង្គ្រោះប្រភេទនេះកុំឲ្យផុតពូជ ហើយសហភាពអឺរ៉ុបនៅតែប្តេជ្ញាចិត្តធ្វើការជាមួយដៃគូទាំង អស់ដើម្បីសម្រេចគោលដៅរួមនេះ។ នេះបើតាមការបញ្ជាក់ពីលោក លោក ក្លេមីន បេគ័រ។

កន្ធាយក្បាលកង្កែបគឺជាប្រភេទមួយក្នុងចំណោមប្រភេទកម្រៗជាច្រើនទៀតនៅតាមដងទន្លេមេគង្គ ព្រោះ កន្ធាយក្បាលកង្កែបរស់នៅក្នុងអន្លង់ជ្រៅៗជាមួយត្រីមូលហ្វីន និងត្រីបបែលយក្សជាដើម។ ការលែងកន្ធាយ ក្បាលកង្កែបដែលជាប្រភេទដ៏សំខាន់ចូលក្នុងជម្រកធម្មជាតិ គឺជាការរួមចំណែកយ៉ាងសំខាន់ដល់ការស្តារ ប្រភេទនេះឡើងវិញ កុំឱ្យផុតពូជនាពេលអនាគត។

កន្ធាយក្បាលកង្កែបឬប៉ិច ដែលមានឈ្មោះវិទ្យាសាស្ត្រថា Pelochelys cantori ត្រូវបានចាត់ចូលក្នុងបញ្ជី ក្រហមរបស់អង្គការ IUCN ជាប្រភេទសត្វរងគ្រោះជិតផុតពូជបំផុត។ វានៅមានចំនួនតិចតួចប៉ុណ្ណោះក្នុង ប្រទេសឡាវ និងប្រទេសមួយចំនួនទៀត និងវាទំនងជាបានផុតពូជហើយនៅតាមអតីតទីជម្រកដែលវាធ្លាប់រស់នៅភាគច្រើនក្នុងប្រទេស វៀតណាមនិងថៃ ដោយសារមានការលួចចាប់និងធ្វើពាណិជ្ជកម្ម រួមទាំងសកម្មភាពខុសច្បាប់ក្នុងការប្រមូលយកពងរបស់យកទៅលក់ឬធ្វើជាអាហារ៕

# សំណល់ភក់បង្គន់នៅរាជធានីភ្នំពេញ នឹងកើនឡើងដល់ ៣៣០.០០០ម៉ែត្រគូប ក្នុងឆ្នាំ២០៣៥

*អត្ថបទ៖ អមរិន្ទ ដានុត*

យោងតាមការសិក្សា នៅឆ្នាំ២០០១ សំណល់ភក់បង្គន់ របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញមានចំនួនប្រមាណ ២៦.០០០ម៉ែត្រគូប ក្នុងមួយឆ្នាំ និងបានបន្តកើនឡើងជាលំដាប់ ហើយតាមការប៉ាន់ស្មាននៅឆ្នាំ២០៣៥ សំណល់ភក់បង្គន់របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ នឹងកើនឡើងដល់ ៣៣០.០០០ម៉ែត្រគូប ក្នុងមួយឆ្នាំ។

នេះជាការលើកឡើងរបស់លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ក្នុងពិធីបើកការដ្ឋានស្ថាបនាស្ថានីយប្រព្រឹត្តកម្មសំណល់ភក់បង្គន់ មានទីតាំងស្ថិតនៅក្នុងសង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល រាជធានីភ្នំពេញនាព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២នេះ។ លោកបានថ្លែងថា៖ «កំណើនសំណល់ភក់បង្គន់របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញនេះ ទាមទារឱ្យមានការរៀបចំអាងប្រព្រឹត្តកម្មសំណល់ភក់បង្គន់នេះឱ្យបានត្រឹមត្រូវ ស្របតាមស្តង់ដាបច្ចេកទេសដែលមិនធ្វើឱ្យប៉ះពាល់បរិស្ថាន»។

លោក ឃួង ស្រេង បានបន្តទៀតថា រាជធានីភ្នំពេញនាពេលបច្ចុប្បន្ន មានការអភិវឌ្ឍយ៉ាងខ្លាំងទាំបែបទូលាយ និងបែបជម្រៅ ក្នុងនោះ ព្រំប្រទល់រដ្ឋបាលត្រូវបានពង្រីកពី ៣០០ ទៅ ៦៩២,៤៦ គីឡូម៉ែត្រក្រឡា មានប្រជាជនរស់នៅ និងស្នាក់នៅបម្រើការងារប្រមាណ ៣លាននាក់។

យោងតាមការសិក្សា នៅឆ្នាំ២០០១ សំណល់ភក់បង្គន់ របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ មានចំនួនត្រឹមតែ ២៦.០០០ម៉ែត្រគូប ក្នុងមួយឆ្នាំ និងមានការកើនឡើងជាលំដាប់ ហើយតាមការប៉ាន់ស្មាន នៅឆ្នាំ២០៣៥ សំណល់ភក់បង្គន់របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ នឹងកើនឡើងដល់ ៣៣០.០០០ម៉ែត្រគូបក្នុងមួយឆ្នាំ ពោលគឺកើនឡើងជិត ១៣ ដង ដូច្នេះទាមទារឱ្យយើងត្រូវយកចិត្តទុកដាក់គ្រប់គ្រង ជាពិសេសរៀបចំអាងប្រព្រឹត្តកម្មសំណល់នេះ ឱ្យបានត្រឹមត្រូវ ស្របតាមស្តង់ដាបច្ចេកទេស។

លោក ឃួង ស្រេង ថា ៖ «នេះហើយគឺជាកម្ពុជាពិត ដែលក្នុងពេលអតីតកាល យើងគ្មានឡើយតម្រូវការស្ថានីយប្រព្រឹត្តកម្មប្រភេទនេះ ព្រោះប្រជាជនយើងមានជីវភាពខ្វះខាត គ្មានអាហារបរិភោគគ្រប់គ្រាន់ និងគ្មានឡើយស្តង់ដារស់នៅ»។

លោកបានបន្តទៀតថា ៖ «ប៉ុន្តែក្នុងសម័យតេជោ ជីវភាពប្រជាជនយើងកាន់តែមានភាពល្អប្រសើរ នឹងមានអាហារបរិភោគគ្រប់គ្រាន់ ដូច្នេះ៖ ស្តង់ដានៃការរស់នៅក្នុងទីក្រុង ក៏ត្រូវតែលើកកម្ពស់ឱ្យកាន់តែប្រសើរឡើងជាលំដាប់ផងដែរ»។

រាជធានីភ្នំពេញ គឺពិតជាមានភាពចាំបាច់ និងមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីលើកកម្ពស់អនាម័យសាធារណៈ ឆ្លើយតបទៅនឹងអត្រាកំណើនប្រជាពលរដ្ឋ កំណើនសេដ្ឋកិច្ច នគរូបនីយកម្មការពង្រីកទីក្រុង និងការកើនឡើងផ្នែកជីវភាព តម្រូវការរស់នៅកាន់តែស៊ីវិល័យរបស់ប្រជាពលរដ្ឋ។

គម្រោងនេះ នឹងផ្តល់នូវអត្ថប្រយោជន៍សំខាន់ចំនួន ៣ ដល់ប្រជាពលរដ្ឋរួមមាន ៖ទី១ អត្ថប្រយោជន៍ផ្នែកបរិស្ថាន តាមរយៈការគ្រប់គ្រងសំណល់ភក់បង្គន់បានត្រឹមត្រូវ, ទី២ អត្ថប្រយោ ជន៍ផ្នែកសង្គម តាមរយៈការបង្កើតការងារ និងកែច្នៃសំណល់ភក់បង្គន់ទៅជាជីសរីរាង្គ កាត់បន្ថយការប្រើប្រាស់ជីគីមី និងទី៣ អត្ថប្រយោជន៍ ផ្នែកសេដ្ឋកិច្ច តាមរយៈការលក់ជីសរីរាង្គដែលផលិតបានទៅក្នុងទីផ្សារកសិកម្ម ឬ អាចនិយាយបានថា «យកសំណល់ គ្រប់គ្រងសំណល់»។

នាឱកាសនោះដែរ លោកព្យែរ ប៉ែយ៉ លេខាធិការអចិន្ត្រៃយ៍ នៃសមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង ក៏បានលើកឡើងផងដែរ ការរៀបចំអាងប្រព្រឹត្តកម្មសំណល់ភក់បង្គន់នេះជាគោលនយោបាយមួយធ្វើឱ្យប្រសើរឡើង នៃការរស់នៅរបស់ប្រជាពលរដ្ឋនៅភ្នំពេញ ប្រកបដោយសុខមាលភាព ដោះស្រាយបំរែបំរួលអាកាសធាតុ។

លោកមានប្រសាសន៍ថា ៖ «សំណល់ភក់បង្គន់នេះនឹងប្រែក្លាយទៅជាជីសំរាប់បងប្អូនប្រជាពលរដ្ឋធ្វើកសិកម្ម ហើយវានឹងផ្តល់ការងារជូនក្រុមហ៊ុនតូចតាចមានការងារធ្វើផងដែរ»៕

# លោក ប្រាក់ សុខុន គោរព គោរពវិញ្ញាណក្ខ័ន្ធ កងកម្លាំងរក្សាសន្តិភាពពិភពលោក



*អត្ថបទ៖ អមរិន្ទ ដានុត*

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២នេះ លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងតំណាងរដ្ឋាភិបាលបណ្តាប្រទេសប្រចាំនៅកម្ពុជា បានអញ្ជើញគោរពវិញ្ញាណក្ខ័ន្ធ កងកម្លាំងរក្សាសន្តិភាពដែលបានពលីជីវិតក្នុងបុព្វហេតុបំពេញបេសកកម្មថែរក្សាសន្តិភាពពិភពលោក នៅសាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ ( PKO) ខេត្តកំពង់ស្ពឺ ។

ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិសម្របសម្រួលការបញ្ជូនកម្លាំងរក្សាសន្តិភាព លោក ប្រាក់ សុខុន បានថ្លែងថា ពិធីគោរពវិញ្ញាណកងកម្លាំងរក្សាសន្តិភាពពិភពលោកនេះ បានធ្វើឡើងស្របដែលបណ្តាប្រទេសបរិច្ចាគកងកម្លាំងចូលរួមថែរក្សាសន្តិភាពលើពិភពលោក បាននាំគ្នាប្រារព្ធទិវាអន្តរជាតិ នៃអ្នកថែរក្សាសន្តិភាពអង្គការសហប្រជាជាតិ ២៩ ឧសភា លើកទី៧៤ ។

លោកថា ៖ «ពិធីនេះធ្វើឡើងដើម្បីរំលឹកដល់ការចូលរួមពីគ្រប់កងកម្លាំងយោធា នគរបាល និងបុគ្គលិកស៊ីវិលទាំងបុរស និងនារី ក្នុងប្រតិបត្តិការថែរក្សាសន្តិភាព ហើយក៏ជាថ្ងៃប្រារព្ធពិធីគោរពវិញ្ញាណក្ខ័ន្ធ វិរៈយុទ្ធជន យុទ្ធនារី ដែលបានពលីក្នុងបុព្វហេតុចូលរួមស្វែងរកសន្តិភាពនៅតាមប្រទេសមានជំលោះសង្គ្រាមតាំងពីឆ្នាំ១៩៤៨ រហូតមកដល់បច្ចុប្បន្ននេះ»។

ជាមួយគ្នានេះដែរ លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ថ្លែងថា ចាប់តាំងពីឆ្នាំ១៩៤៨ រហូតមកដល់បច្ចុប្បន្ន មានអ្នកថែរក្សាសន្តិភាពជាបុរស និងស្ត្រី ប្រមាណជាង១លាននាក់ ចូលរួមប្រតិបត្តិថែរក្សាសន្តិភាពពិភពលោក ក្រោមឆ័ត្រUN ក្នុងមានយុទ្ធជន យុទ្ធនារីថែរក្សាសន្តិភាពប្រមាណ៤២០០នាក់ បានពលីជីវិតក្នុងបុព្វហេតុរក្សាសន្តិភាពនេះ ក្នុងនៅមានកម្លាំងរក្សាសន្តិភាពកម្ពុជា ចំនួន១០នាក់ផងដែរ។

ចំណែក លោក សែម សុវណ្ណនី អនុប្រធានគណកម្មាធិការជាតិ និងជាអគ្គនាយកមជ្ឈមណ្ឌលជាតិរក្សាសន្តិភាពថ្លែងថា នៅក្នុងឆ្នាំ២០២២នេះ គឺជាខួបលើកទី៣០ ដែលអង្គការសហប្រជាជាតិUN បានបង្កើតបេសកកម្មរក្សាសន្តិភាពនៅកម្ពុជា ហៅកាតថាUNTAC ដើម្បីចូលរួមរួមចំណែកជួយស្តារឡើងវិញនូវសុខសន្តិភាពជូនប្រទេសកម្ពុជា ពីការសង្គ្រាមហែកហួរក្នុងស្រុក និងការរៀបចំការបោះឆ្នោតជាលើកដំបូងនៅកម្ពុជា។

នៅក្នុងប្រតិបត្តិការបេសកកម្មរក្សាសន្តិភាររបស់UNTACនៅ កម្ពុជា លោក សែម សុវណ្ណនី បញ្ជាក់ថា ៖ «ក្នុងអំឡុង ឆ្នាំ១៩៩២ ឆ្នាំ១៩៩៣ មានកម្លាំងUNTACប្រមាណជាង ១៥០០០នាក់ កម្លាំងនគរបាលស៊ីវិល៣០០០នាក់ បុគ្គលិកស៊ីវិល៩០០នាក់ មកពីបណ្តាប្រទេស៤៥ បានមកបំពេញបេសកកម្មរក្សាសន្តិភាពនៅកម្ពុជា ហើយមានកម្លាំង UNTACនេះ ៨២នាក់ មកប្រទេសចំនួន២៧ប្រទេស បានរងពលីជីវិត»។

លោកបានបន្តថា ដោយឡែកសម្រាប់កម្ពុជាវិញ ក្នុងរយៈពេល១៦ឆ្នាំ កម្ពុជាបានបញ្ជូនអ្នកថែរក្សាសន្តិភាពUN ចំនួនជាង៨០០០នាក់ ទៅបំពេញបេសកកម្មរក្សាសន្តិភាពចំនួនចំនួន៩ប្រទេស ខណៈនៅក្នុងឆ្នាំ២០២២នេះ កម្ពុជា មានកម្លាំងមួកខៀវចំនួនជិត៨០០នាក់ កំពុងឈរជើងបំពេញបេសកកម្មថែរក្សាសន្តិភាពUNនៅតាមបណ្តាប្រទេសចំនួន៤ រួមមាន: ប្រទេសស៊ូដង់ខាងត្បូង លីបង់ អាហ្វ្រិកកណ្តាល និងប្រទេសម៉ាលី៕

# ធនាគារពិភពលោក អនុម័តទឹកប្រាក់ ១៦៩លានដុល្លារ លើការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

ធនាគារពិភពលោក នៅថ្ងៃទី២៦ ខែឧសភានេះ បានអនុម័តលើជំនួយមានទឹកប្រាក់ចំនួន ១៦៩លានដុល្លារអាមេរិក ជាកញ្ចប់ហិរញ្ញប្បទានថ្មីដល់គម្រោងការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិអាស៊ីអាគ្នេយ៍នៅកម្ពុជាដំណាក់កាលទី២ សម្រាប់បង្កើនភាពធន់នៃបណ្តាញផ្លូវជនបទទៅនឹងគ្រោះធម្មជាតិ និងកត្តាអាកាសធាតុ និងសម្រាប់លើកកម្ពស់សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការទ្រទ្រង់ដល់ការងារសុវត្ថិភាពផ្លូវ និងភាពធន់ទៅនឹងកត្តាអាកាសធាតុ។



យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគារពិភពលោក បានឱ្យដឹងថាគម្រោងនេះជួយដល់ការសាងសង់ផ្លូវ និងស្ពាននៅតាមតំបន់រងការជន់លិចទឹក និងជួយបង្កើនសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងគ្រោះធម្មជាតិបង្កដោយអាកាសធាតុ។ ធនាគារពិភពលោក បានបន្តថា គម្រោងនេះនឹងនាំអត្ថប្រយោជន៍ដល់ប្រជាជនចំនួនប្រហែល ៥,៥លាននាក់ ក្នុងនោះ ៥២ភាគរយជាស្ត្រី នៅក្នុងខេត្តចំនួនប្រាំពីរ និងដល់អ្នកដែលប្រើប្រាស់បណ្តាញផ្លូវទាំងនេះ។

មន្ត្រីរាជរដ្ឋាភិបាល ភាគច្រើនមកពីក្រសួងអភិវឌ្ឍន៍ជនបទ នឹងទទួលបានការបណ្តុះបណ្តាលតាមរយៈគម្រោងនេះអំពីការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិ, ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃតម្រូវការក្រោយមានគ្រោះធម្មជាតិ។

លោកស្រី ម៉ារីយ៉ាម សាលីម (Maryam Salim) ប្រធានគ្រប់គ្រងនៃធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ថា ជាមួយនឹងការប្តេជ្ញាចិត្តមុះមុតរបស់ក្រសួងអភិវឌ្ឍន៍ជនបទនៃរាជរដ្ឋាភិបាលកម្ពុជា។

លោកស្រីថា ៖ « គម្រោងនេះនឹងជួយធ្វើយ៉ាងណាឱ្យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទឱ្យនៅមានភាពរឹងមាំ និងធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ហើយទន្ទឹមគ្នានោះជួយការពារផងដែរដល់ប្រជាជនងាយរងគ្រោះពីហេតុការណ៍គ្រោះធម្មជាតិដែលគ្មានអ្នកណាអាចដឹងមុន»។

កម្ពុជាជាប្រទេសមួយដែលងាយរងគ្រោះណាស់ពីផលប៉ះពាល់អវិជ្ជមាននានា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ក្នុងនោះមានជាពិសេសទឹកជំនន់ និងភាពរាំងស្ងួត ហើយហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទក៏ងាយរងគ្រោះខ្លាំងណាស់ដែរពីហានិភ័យនៃគ្រោះធម្មជាតិបង្កដោយអាកាសធាតុ។

បណ្តាញផ្លូវជនបទមានភាពចាំបាច់ខ្លាំងណាស់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍ជនបទ ហើយការខូចខាតផ្នែកនានានៅលើបណ្តាញផ្លូវអាចធ្វើឱ្យជីវភាពគ្រួសារជនបទជួបការលំបាក និងបង្កឧបសគ្គដល់លទ្ធភាពទទួលបានសេវាសាធារណៈជាមូលដ្ឋាននានា មានដូចជាទីផ្សារ, សាលារៀន និងមន្ទីរពេទ្យ។

បើតាមធនាគារពិភពលោក ការខូចខាតយ៉ាងដំណំដោយសារទឹកជំនន់ក្នុងឆ្នាំ២០២០ បានគូសបញ្ជាក់ច្បាស់អំពីសេចក្តីត្រូវការរបស់កម្ពុជាឱ្យមានការវិនិយោគបន្ថែមទៀត ទៅលើការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិ និងស្ថានភាពងាយរងគ្រោះរបស់ហេដ្ឋារចនាសម្ព័ន្ធផ្លូវសំខាន់។

គម្រោងនេះនឹងត្រូវបានអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានដើរតួសកម្មនៅក្នុងការបង្កើនភាពធន់របស់ការសាងសង់ និងរបស់ស្តង់ដាថែទាំផ្លូវ។ គម្រោងនេះនឹងបន្តធ្វើពីដំណាក់កាលទី១នៃគម្រោងគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិអាស៊ីអាគ្នេយ៍ នៅកម្ពុជា ដោយផ្តោតសំខាន់លើការពង្រីកបណ្តាញតភ្ជាប់ផ្លូវជនបទដែលធន់នឹងកត្តាអាកាសធាតុ និងលើការពង្រឹងការរៀបចំផែនការហិរញ្ញវត្ថុរបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ទ្រទ្រង់ភាពធន់នឹងគ្រោះធម្មជាតិ។

ថវិកានេះគឺជាឥណទានពីសមាគមអភិវឌ្ឍន៍អន្តរជាតិនៃធនាគារពិភពលោក ហើយក៏មានជំនួយទឹកប្រាក់ចំនួន ៤៥០០០០ដុល្លារអាមេរិកទៀត ពីកម្មវិធីរួមគ្នារវាងប្រទេសជប៉ុននិងធនាគារពិភពលោកសម្រាប់បញ្ជ្រាបការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ (Japan-Bank Program for Mainstreaming DRM in Developing Countries) ដែលកម្មវិធីនេះទទួលថវិកាពីរដ្ឋាភិបាលជប៉ុន និងគ្រប់គ្រងដោយមូលនិធិសាកលសម្រាប់កាត់បន្ថយនិងស្តារឡើងវិញពីគ្រោះធម្មជាតិ។ កម្ពុជានឹងរួមចំណែកថវិកាបដិភាគចំនួន ២លានដុល្លារអាមេរិក ទៅក្នុងកញ្ចប់ហិរញ្ញប្បទានថ្មីនេះ៕

# រដ្ឋាភិបាល ជំរុញការប្រើប្រាស់យានយន្ត អគ្គិសនីដើម្បីកាត់បន្ថយការបំពុលបរិស្ថាន

*អត្ថបទ៖ អមរិន្ទ ដានុត*

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន លោក ស៊ុន ចាន់ថុល បានលើកឡើងថា រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ ដើម្បីឱ្យការបញ្ចេញឧស្ម័នកាបូនធ្លាក់នៅកម្រិតសូន្យនៅឆ្នាំ២០៥០ និងជំរុញការប្រើប្រាស់យានយន្តអគ្គិសនីឱ្យបានប្រមាណ៤០% នៅឆ្នាំ២០៥០ និងម៉ូតូ៧០% នៅឆ្នាំ២០៥០ ។

លោកបានថ្លែងដូចនេះក្នុងកម្មវិធីMPWT LIVE SHOW ក្រោមប្រធានបទ៖ ការប្រើប្រាស់យានយន្តអគ្គិសនីនៅកម្ពុជា នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២នេះ។

កម្មវិធីMPWT Live Showនេះ បង្កើតឡើងក្នុងគោលបំណងជំរុញការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ និងសម្បូរបែបជូន ប្រជាពលរដ្ឋអំពីបេសកកម្ម ចក្ខុវិស័យ កិច្ចខិតខំប្រឹងប្រែងសមិទ្ធផល និងវឌ្ឍនភាពការងាររបស់ក្រសួង ផ្សារភ្ជាប់ទំនាក់ទំនងរវាងថ្នាក់ដឹកនាំក្រសួងជាមួយពលរដ្ឋ និងឆ្លើយតបរាល់ចម្ងល់នានារបស់សាធារណជនពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូនផងដែរ។

នាឱកាសនោះលោក ស៊ុន ចាន់ថុល បានគូសបញ្ជាក់ពីចរន្តកើនឡើងនៃការ ប្រើប្រាស់រថយន្តអគ្គិសនី ដើម្បីចូលរួមកាត់បន្ថយការបំពុលបរិស្ថាន



នៅកម្ពុជា ក៏ដូចជាពិភពលោក និងបានបន្ថែមថា ក្រសួងបានខិតខំប្រឹងប្រែងរៀបចំគោលនយោបាយដឹកជញ្ជូន ក្នុងនោះមានមួយផ្នែកនិយាយអំពីការប្រើប្រាស់យានយន្តអគ្គិសនីផងដែរនៅកម្ពុជា។

លោកមានប្រសាសន៍ថា ៖ «រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោ បាយ ដើម្បីឱ្យការបញ្ចេញឧស្ម័នកាបូនធ្លាក់នៅកម្រិតសូន្យនៅឆ្នាំ២០៥០ និងជំរុញការប្រើប្រាស់យាន យន្តអគ្គិសនីឱ្យបានប្រមាណ៤០% នៅឆ្នាំ២០៥០ និងម៉ូតូ៧០% នៅឆ្នាំ២០៥០»។

លោករដ្ឋមន្ត្រីក៏បានជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រើប្រាស់យាន យន្តអគ្គិសនីឱ្យបានច្រើន ដើម្បីចូលរួមចំណែកកាត់បន្ថយការចំណាយលើប្រេងឥន្ធនៈ និងការបំពុល បរិស្ថាន។

លោក ស៊ុន ចាន់ថុល បានអំពាវនាវថា ៖ «សុំឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ចូលរួមគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ដើម្បីសុវត្ថិភាពយើងទាំងអស់គ្នា និងបានក្រើនរំលឹកផងដែរថាបច្ចុប្បន្ននេះ គ្រោះថ្នាក់ចរាចរណ៍បានបង្ក ឱ្យមនុស្សស្លាប់ជាមធ្យមពី៤នាក់ទៅ៥នាក់ក្នុងមួយថ្ងៃ និងរបួសជាច្រើននាក់ ខាតបង់ទ្រព្យសម្បត្តិ និង ថវិការហូតទៅដល់៣០០ ទៅ៤៥០ លានដុល្លាក្នុងមួយឆ្នាំ»។

នាពេលនោះដែរ លោកក៏បានបញ្ជាក់ដែរថា ក្នុងរយៈពេល៤ខែដើមឆ្នាំ២០២២នេះ ការនាំចូលរថយន្តអគ្គិសនីនេះ មានយានយន្តអគ្គិសនីចុះបញ្ជីនៅក្រសួងសាធារណការ និងដឹកជញ្ជូនសរុបចំនួន៦៦គ្រឿង ប្រៀបធៀប នឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានការកើនឡើងប្រមាណជាង៦០០%។

លោកថា នៅក្នុងឆ្នាំ២០២២នេះ ក្រសួងបានសហការជាមួយអង្គការUNDP និងវិស័យឯកជនក្នុងការដាក់ឱ្យដំណើរការទីតាំងសាកយានយន្តអគ្គិសនី មួយចំនួនក្នុងនោះរួមមាន០៤ទីតាំងត្រូវបានគាំទ្រដោយអង្គការUNDP និង០១ ត្រូវបានគាំទ្រដោយ សភាពាណិជ្ជកម្មចិននៅកម្ពុជា។

ក្រសួងសាធារណការនិងដឹកជញ្ជូន ក៏កំពុងសហការជាមួយអង្គការUNDPផងដែរក្នុងការសិក្សា និងចងក្រងផែនទីចង្អុលផ្លូវស្តីពីហេដ្ឋារចនាសម្ព័ន្ធបញ្ចូលថាមពលយានយន្តអគ្គិសនី ដែលនឹងកំណត់ អំពីទីតាំងជាក់លាក់លក្ខខណ្ឌនៃការរៀបចំស្ថានីយបញ្ចូលថាមពលដើម្បីស្វែងរកដៃគូវិនិយោគ និង ពង្រីកបណ្តាញស្ថានីយបញ្ចូលថាមពលទូទាំងប្រទេសកម្ពុជា។

គួរបញ្ជាក់ផងដែរថា ក្នុងព្រះរាជាណាចក្រកម្ពុជាគិតត្រឹមថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ អគ្គនាយកដ្ឋាន ដឹកជញ្ជូនផ្លូវគោក បានធ្វើការចុះបញ្ជីយានយន្តអគ្គិសនីបានចំនួន ១៤៨គ្រឿង ក្នុងនោះរថយន្តបានចំនួន ១១០គ្រឿង និងទោចក្រយានយន្តត្រីចក្រយានយន្តអគ្គិសនីបានចំនួន ៣៨គ្រឿង។

កំណើនយានយន្ត អគ្គិសនីក្នុង រយៈពេលប្រាំខែដំបូងនៃឆ្នាំ២០២២នេះ មានចំនួន៨៤គ្រឿង ដោយប្រៀបធៀបនឹងរយៈពេល ដដែលក្នុង ២០២១ មានចំនួន៩គ្រឿង ដែលនេះបានបង្ហាញពីការកើនឡើងជាង៨០០%។

យោងលើកំណើនដ៏ឆាប់រហ័សនេះ ក្រសួងរំពឹងថានឹងមានការកើនឡើងយានយន្តស្របទៅតាមទិសដៅ កំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្ររយៈពេលវែងស្តីពីអាព្យាក្រឹត កាបូនឆ្នាំ២០៥០ ដោយជំរុញ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់រថយន្តអគ្គិសនីក្នុងអាត្រា៤០% និងម៉ូតូអគ្គិសនីក្នុងអាត្រា៧០%៕

## នាយករដ្ឋមន្ត្រីកម្ពុជា សុទិដ្ឋិនិយមលើការការពារកុមារ លើគ្រប់វិស័យ និងជំរុញការសិក្សាតាមបែបឌីជីថល

*អត្ថបទ៖ ផល សុផានិត*

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅតែបន្តមានសុទិដ្ឋនិយមលើកកម្ពស់ និងជំរុញការអនុវត្តសិទ្ធិកុមារអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ននិងមានចែងក្នុងរដ្ឋធម្មនុញ្ញជាធរមាន ជាពិសេសបន្តវិនិយោគកុមារលើវិស័យអប់រំ។

តាមរយៈសារលិខិតអបអរទិវាកុមារអន្តរជាតិ១ មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ និងទិវាកុមារកម្ពុជា ឆ្នាំ២០២២ រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ មានឆន្ទៈមោះមុត និងប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងសូមលើកទឹកចិត្តដល់ជនរួមជាតិ ជាពិសេសកុមារខ្លួនឯងត្រូវទទួលស្គាល់ថា កុមារគឺជាអ្នកដែលត្រូវបន្តវេនក្នុងការជួយស្ថារ កសាង និងអភិវឌ្ឍសង្គមកម្ពុជា។

រួមគ្នាបន្តវិនិយោគកុមារ និងបង្កើតធនធានមនុស្សដែលមានជំនាញ ប្រកបដោយសក្តានុពលនាពេលអនាគត សំដៅធ្វើអោយសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។

សម្តេចហ៊ុនសែនបានលើកឡើងថា ៖ «រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យច្បាស់លាស់ធ្វើយ៉ាងណាឱ្យកុមារ ក្រុមគ្រួសារ និងសហគមន៍ទទួលបាននូវគុណភាពនិងគុណធម៌នៃការរស់នៅ ដោយចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពគ្នាក្នុងតម្លាភាពសង្គម ព្រមទាំងជំរុញឱ្យមានឱកាសក្នុងការអភិវឌ្ឍ គ្រប់វិស័យ គ្រប់កម្រិត»។

សម្តេច ហ៊ុន សែន ក៏បានស្នើដល់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ទាំងអស់ បន្តពង្រឹងយន្តការសម្របសម្រួលក្នុងការបង្ការទប់ស្កាត់ អន្តរគមន៍ និងការឆ្លើយតបលើករណីកុមារ ដើម្បីលើកកម្ពស់និងផ្តល់សេវាយុត្តិធម៌សង្គម ដោយធានាឱ្យមានសមភាពរវាងកុមារា និងកុមារី ព្រមទាំងបង្កើនឱកាសស្មើភាពគ្នាក្នុងកម្លាំងចលករសង្គមសម្រាប់ជីវភាពសាធារណៈ ជីវភាពនយោបាយ សកម្មភាពសង្គម វប្បធម៌ សិល្បៈ សសនា និងសកម្មភាពផ្សេងៗទៀត។

លោកក៏បានបន្តអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន អង្គការអន្តរជាតិ គ្រប់លំដាប់ថ្នាក់ បង្កើនសិទ្ធិអំណាចពិសេស កុមារីនិងសហគមន៍ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរសំខាន់ៗ ដោះស្រាយការរើសអើង ការផាត់ចេញពីសង្គម និងភាពរងគ្រោះ។

អនុវត្តគោលនយោបាយនៅក្នុងកម្រិតមូលដ្ឋាន និងកម្រិតជាតិ ការចែករំលែកចំណេះដឹង បទពិសោធន៍ ស្តីពីតថភាពរបស់កុមារដែលកំពុងជួបប្រទះ។ សមាហរណកម្មចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ ដោយផ្តល់អាទិភាពជាចម្បងដល់កុមារីកុមារជាជនជាតិដើមភាគតិច និងកុមារមានពិការភាព។

សម្តេចបានបញ្ជាក់ថា ៖ «គ្រប់ក្រសួង ស្ថាប័ន ត្រូវចូលរួមគាំទ្រឱ្យកុមារទទួលបានការអភិវឌ្ឍប្រកបដោយសុវត្ថិភាព និងជោគជ័យដោយបន្តពង្រឹងសេវាគាំពារ និងអភិវឌ្ឍកុមារតូច អាហារូបត្ថម្ភ សុខភាពបន្តពូជយុវវ័យ ការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ និងបំណិនជីវិត»។

ទប់ស្កាត់ បង្ការ លុបបំបាត់ការជួញដូរមនុស្ស និងរូបភាពអាសអាភាសកុមារ តាមរយៈក្នុងប្រព័ន្ធអនឡាញនិងក្រៅប្រព័ន្ធអនឡាញក្នុងសហគមន៍ ដើម្បីធានាសុវត្ថិភាពស្របតាមគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ។ នេះបើតាមការលើកឡើងបន្ថែមរបស់សម្តេច ហ៊ុន សែន៕

## កម្មករ-ការិនីរោងចក្រ ឈ្វេងយល់អំពើបៀតបៀនកេរ្តិ៍ខ្មាស



*អត្ថបទ៖ ចាន់ ម៉ានុត*

គណៈកម្មការពលករនៃព្រះសហគមន៍កាតូលិកភ្នំពេញ បានរៀបចំកម្មវិធីសិក្ខាសាលាមួយស្តីពី «សុខភាពកម្មករ» ដោយមានសិក្ខាកាមចូលរួមជិត៣០នាក់ ធ្វើឡើងនៅព្រះសហគមន៍សន្តសិលា សន្តប៉ូល ភ្នំពេញថ្មី នាល្ងាចថ្ងៃអាទិត្យ ទី០១ ខែឧសភា ឆ្នាំ២០២២។

កញ្ញា ម៉ៅ ស្រីកែវ ជាលេខាធិការនៃគណៈកម្មការពលកររបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជាអ្នកសម្របសម្រួលនៅក្នុងកម្មវិធីនេះបានឲ្យដឹងថា យើងចង់ឲ្យខាងកម្មករកម្មការិនី យល់ដឹងបន្ថែមទៀត ទៅលើការបៀតបៀនកេរ្តិ៍ខ្មាសនៅក្នុងរោងចក្រ និងចេះការពារខ្លួនរបស់គាត់ និងមិត្តរួមការងារពីអំពើនេះ។

កម្មវិធីសិក្ខាសាលាដែលរៀបចំឡើងដោយគណៈកម្មការពលករព្រះសហគមន៍កាតូលិកភ្នំពេញ ដែលមានសិក្ខាកាមដែលជាកម្មករកម្មការិនី មកពីរោងចក្រនានាដែលកំពុងបំពេញការងារនៅក្នុងទីក្រុងភ្នំពេញ ចំនួន២៩នាក់ ធ្វើឡើងដោយមានអ្នកស្រី នៅ សុវ៉ាត់ថា ដែលជាវាគ្មិនកិត្តិយស មកពីអង្គការ ឃែរ កម្ពុជា (Care Cambodia)។

អានបន្តទំព័រ-១៩...

# លោកអភិបាលអូលីវីយេ ឲ្យគ្រីស្តបរិស័ទយកគំរូតាមនាង Pauline Jaricot

*អត្ថបទ៖ ដាលីស*

នៅក្នុងពិធីអគ្គសញ្ញាលាបប្រេងថ្វាសដល់បេក្ខជន ៤៨រូបនៃមណ្ឌលសកកម្មភាពបាសាក់ លោកអភិបាលអូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានណែនាំឲ្យគ្រីស្តបរិស័ទយកគំរូតាមនាងប៉ូលីន ចារីខូ (Pauline Jaricot ) ដែលសម្តេចប៉ាបបានប្រកាសពេលថ្មីៗនេះ ថា នាងជាអ្នកពោរពេញដោយសុភមង្គល។

លោកអភិបាលបានមានប្រសាសន៍ថា «ប៉ូលីន ជាយុវនារីបារាំងដែលកើតនៅក្នុងគ្រួសារអ្នកមានក្នុងឆ្នាំ ១៧៩៩ ដោយបានបង្កើតក្រុមដើម្បីឧបត្ថម្ភសាសនទូតដែលទៅប្រកាសដំណឹងល្អតាមប្រទេសនីមួយៗក្នុងពិភពលោកក្នុងឆ្នាំ ១៨០០ និងពេលនេះគ្រប់២០០ឆ្នាំហើយ»។

លោកអភិបាលរំលឹកថា នាងបានកែប្រែចិត្តគំនិតដោយផ្ញើជីវិតលើព្រះជាម្ចាស់និងបម្រើព្រះសហគមន៍ ដោយសារគំរូនៃការលះបង់ជីវិតរបស់ម្ដាយដើម្បីឲ្យគាត់មានសុខភាពល្អឡើងវិញ។

ក្រោយមកក្នុងឆ្នាំ១៨១៧ ក្នុងវ័យ១៨ឆ្នាំ ប៉ូលីនបានបង្កើតសមាគមនារី ដើម្បីបង្ហាញឱ្យមនុស្សលោកដឹងថា ព្រះបេះដូងព្រះយេស៊ូមានសេចក្ដីស្រឡាញ់សម្រាប់មនុស្សទាំងអស់។ សមាគមនេះ បានលើកតម្លៃអ្នកជំងឺ អ្នកក្រីក្រ និងមនុស្សដែលគេបោះបង់ចោល «ដោយដឹងថាពេលយើងលះបង់ចោលនរណាម្នាក់យើងក៏បានបោះបង់ព្រះយេស៊ូដែរ។» នេះបើតាមការរៀបរាប់របស់លោកអភិបាលប្រាប់ដល់បេក្ខជននិងគ្រីស្តបរិស័ទដែលបានចូលរួមក្នុងពិធីនោះ នៅព្រះវិហារសន្តយ៉ូសែប (ជ្រៃធំ)ក្នុងខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែឧសភាកន្លងទៅនេះ។

លោកអភិបាលសង្កត់ធ្ងន់ទៀតថា វីរភាពរបស់ស្ត្រីរូបនេះ ក្នុងវ័យ២៣ឆ្នាំ បានបង្កើតសមាគមព្រះមាលាដ៏មានជីវិត ដើម្បីរួមគ្នាអធិដ្ឋានផ្គុំ និងផ្តល់ប្រាក់ឧបត្ថម្ភដល់សាសនទូតក្រៅប្រទេសនានា ដែលខ្វះខាតប្រាក់និងរងការបៀតបៀនពីរដ្ឋអំណាច ក្នុងការប្រកាសដំណឹងល្អ។ ពេលនេះសមាគមនេះមាននៅក្នុងប្រទេសបារាំងនិងប្រទេសមួយចំនួនក្នុងពិភពលោក។

ក្នុងនោះដែរ លោកអភិបាលអូលីវីយេ បានឲ្យគ្រីស្តបរិស័ទប្រើប្រាស់ជីវិតរបស់ខ្លួនឲ្យសកម្មដូចប៉ូលីន ដែលតែងតែនឹកគិតដល់ផ្លូវវិញ្ញាណរបស់មនុស្ស។ ក្នុងសម័យនោះ កម្មករកម្មការិនីរោងចក្រ ធ្វើការងារច្រើនម៉ោង គ្មានពេលអធិដ្ឋាននិងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ឃើញដូច្នេះ ប៉ូលីន ដែលជាកូនក្នុងគ្រួសារអ្នកមានទ្រព្យ បានបង្កើតរោងចក្រកាតូលិកមួយ ដើម្បីឲ្យពួកគេអាចធ្វើការផង អធិដ្ឋាននិងស្តាប់ព្រះបន្ទូលផង។

តាមរយៈគំរូនិងសមាគមរបស់ប៉ូលីន ចារីខូ បានធ្វើឲ្យព្រះសហគមន៍នៃប្រទេសនីមួយៗជារៀងរាល់ឆ្នាំ ប្រមូលលុយដើម្បីផ្ញើទៅទីក្រុងរ៉ូម ដែលជាសញ្ញាសម្គាល់ថាព្រះសហគមន៍ក្នុងពិភពលោកជួយគ្នាទៅវិញទៅមកក្នុងការប្រកាសដំណឹងល្អ។ លោកអភិបាលបន្ថែម។

លោកអភិបាលបន្តថា៖ «គាត់បានណែនាំឲ្យយើងយល់ថា យើងត្រូវការភ្ជាប់ជាមួយប្រភពនៃជីវិតរបស់យើង គឺព្រះជាម្ចាស់ ឲ្យយើងអធិដ្ឋានផង ឲ្យយើងស្រឡាញ់យ៉ាងជាក់ស្ដែង»។

ហើយសម្រាប់យើងសព្វថ្ងៃ យើងត្រូវពិចារណាដែរ អំពីសកម្មភាពអ្វីខ្លះដែលយើងបានធ្វើសម្រាប់សង្គមរបស់យើង ធ្វើអ្វីខ្លះដើម្បីប្រកាសដំណឹងល្អ និងអ្វីខ្លះដើម្បីធ្វើជាគ្រីស្តបរិស័ទសកម្ម។ លោកអភិបាលសង្កត់ធ្ងន់យ៉ាងនេះ «ខ្ញុំជឿថា យុវនារីប៉ូលីន ចារីខូ ជាគំរូមួយដ៏អស្ចារ្យសម្រាប់យើងទាំងអស់គ្នា។...ជីវិតរបស់គាត់គឺបូជាជីវិតនៅក្បែរឈើឆ្កាង»។

លោកអភិបាលបន្ថែមថា ប៉ូលីនមិនដែលចង់មានឈ្មោះល្បីទេ ព្រោះគាត់ដឹងថា ព្រះជាម្ចាស់ដឹងទាំងអស់ ហើយអ្វីដែលសំខាន់យើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងអធិដ្ឋាន ណែនាំឲ្យយើងដឹងថាព្រះជាម្ចាស់មានវត្តមាននៅក្នុងជីវិតរបស់យើង ណែនាំឲ្យយើងចេះស្រឡាញ់បងប្អូនឯទៀតៗ។

ជាមួយគ្នានេះ លោកអភិបាលបានរំលឹកថា ប៉ូលីន បានទទួលសារលើកទឹកចិត្តមួយឃ្លាពីសន្តយ៉ូហាន ម៉ារី វីយ៉ាណែរ ដែលបានប្រាប់ថា៖ «យើងមានព្រះជាម្ចាស់តែមួយអង្គគត់ដែលជាសាក្សីរបស់យើង ព្រះយេស៊ូតែមួយអង្គគត់ដែលជាគំរូសម្រាប់យើង យើងមានព្រះនាងម៉ារីតែមួយគត់ដែលជួយគាំទ្រនិងលើកទឹកចិត្តយើង ហើយនៅក្នុងជីវិតរបស់យើងគឺមានរឿងតែមួយគត់ដែលសំខាន់ គឺធ្វើអ្វីៗទាំងអស់នៅក្នុងសេចក្ដីស្រឡាញ់ដោយបូជាជីវិត»។

ក្នុងពិធីនោះ មានបេក្ខជនទទួលអគ្គសញ្ញាលាបប្រេងថ្វាសចំនួន៤៨រូបមកពីព្រះសហគមន៍ជ្រៃធំចំនួន៣៧នាក់ ព្រះសហគមន៍កោះទាវ ១០នាក់ និងស្អាងម្នាក់។

អ្នកស្រី ទ្រឿង យ៉ុង ប្រធានគណៈកម្មការព្រះសហគមន៍ និងជាតំណាងអាណាព្យាបាលបេក្ខជន នៅថ្ងៃនេះព្រះសហគមន៍របស់យើងបានទទួលផលជាច្រើន ហើយផលទាំងនោះគឺមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ជាពិសេសប្អូនៗ និងកូនៗយើងដែលទទួលអគ្គសញ្ញាលាបប្រេងថ្វាស ឱ្យក្លាយជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈ គឺជាគំរូនៃជំនឿជាសាក្សីនៃជំនឿ បញ្ជាក់ពីជំនឿ និងហ៊ានស៊ូឬជីវិតដើម្បីជំនឿ ជាពិសេសគឺដើម្បីព្រះគ្រីស្ត។ ក្នុងនាមយើងខ្ញុំជាឪពុកម្ដាយ អាណាព្យាបាល សូមថ្លែងអំណរគុណដល់លោកអភិបាលដែលបានយកចិត្តទុកដាក់ជួយណែនាំជីវិតខាងផ្លូវវិញ្ញាណរបស់យើងខ្ញុំ៕

# ដូនជីបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់រំលឹកពាក្យសច្ចានៅមុខកូនសិស្សទាំងអស់

*អត្ថបទ៖ កែវ កញ្ញា*

កាលពីថ្ងៃទី២៤ ខែឧសភា នេះ ក្រុមដូនជីបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់នៃដុនបូស្កូទឹកថ្លាបាន រំលឹកពាក្យសច្ចានៅមុខកូនសិស្សជាង១០០០នាក់ ដែលស្ថិតនៅក្នុងវិទ្យាល័យដុនបូស្កូទឹកថ្លា ក្នុងសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ដូនជីទូរអេឡ តេរេសា មានប្រសាសន៍ថា កម្មវិធីថ្ងៃនេះ គឺក្រុមដូនជីធ្វើតាមការស្នើសុំរបស់ដូនជីប្រធានធំនៅអ៊ីតាលី ឲ្យក្រុមដូនជីសាលេស៊ានដុនបូស្កូទាំងអស់ រំលឹកពាក្យសច្ចារបស់ខ្លួនឡើងវិញ នៅចំពោះមុខកូនសិស្សរបស់យើងទាំងអស់។

ដូនជីតេរេសាបន្តថា ជាទូទៅ «យើងម្នាក់ៗរំលឹកពាក្យសច្ចារបស់យើងរៀងរាល់មួយខែម្ដងរៀងៗខ្លួន ដោយមានសំណាក់ធម៌ រិះគិតអំពីការត្រាស់ហៅនិងបេសកកម្មរបស់យើង។ ហើយមូលហេតុដែលយើងមាន គឺនៅពេលនេះ (គ្រួសារ) យើងធ្វើខួប១៥០ឆ្នាំ។»

ដូនជីរូបនេះ បញ្ជាក់ថា ពិធីនេះ យើងធ្វើតែម្ដងនេះប៉ុណ្ណោះ គ្មានធ្វើនៅឆ្នាំក្រោយៗទៀតនោះឡើយ។

នៅមុខកូនសិស្សទាំងអស់ ក្រុមដូនជីដែលមាន២សហគមន៍នៅក្នុងសង្កាត់អូរបែកក្អមសរុបចំនួន១៤នាក់ បានអង្គុយនៅលើឆាក ហើយប្រកាសរំលឹកពាក្យសច្ចារបស់ខ្លួន ដោយក្នុងនោះរួមមាន ការស្ដាប់បង្គាប់ រស់នៅជាព្រហ្មចារីធម៌ និងរស់នៅដោយភាពក្រីក្រ ស្របតាមផ្លូវវិញ្ញាណរបស់លោកឪពុកបូស្កូ និងអ្នកម្ដាយម៉ាស្សារ៉េឡូ ដែលជាអ្នកបង្កើតក្រុមគ្រួសារបព្វជិតាមួយនេះ។




ថុន ឱម៉ារត្តី ជាសិស្សថ្នាក់ទី១២ បានឲ្យដឹងថា៖ «បេសកកម្មរបស់គាត់(ដូនជី) គាត់បានជួយដល់យុវជនសាលេស៊ាន និងក្មេងក្រីក្រហើយ តែពេលឃើញគាត់តាំងចិត្តមោះមុតបែបហ្នឹង ខ្ញុំកាន់តែរំភើប ហើយខ្ញុំដឹងថា កូនខ្មែរជំនាន់ក្រោយៗនឹងមាន អ្នកជួយបន្តៗទៀត។»

យុវតីឱម៉ារត្តី បានចូលសិក្សានៅសាលាដុនបូស្កូរបស់ក្រុមដូនជីរយៈពេល១៥ឆ្នាំមកហើយ តាំងពីកម្រិតមត្តេយ្យថ្នាក់ដំបូង។ នាងឲ្យដឹងទៀតថា នាងសូមអរគុណដល់ក្រុមដូនជី និងបុគ្គលិកសិក្សាទាំងអស់ដែលបានចំណាយពេលវេលាស្ទើរតែពាក់កណ្ដាលជីវិតរបស់ខ្លួនដើម្បីអប់រំណែនាំយុវជនខ្មែរ។

ឱម៉ារត្តីបន្ថែមថា៖ «មិនថាពេលខ្លះពួកខ្ញុំខូចប្រទៀសបើសម៉េចទេ ពួកគាត់អប់រំពួកខ្ញុំតាំងពីសីលធម៌រស់នៅ ក៏ដូចជា វិជ្ជាជីវៈផ្សេងៗ រួមនិងបញ្ហាផ្សេងៗទៀតនៅក្នុងជីវិត។»

បច្ចុប្បន្ន នៅក្នុងសង្កាត់អូរបែកក្អម ក្រុមដូនជីបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់ មានសាលាមត្តេយ្យសិក្សា រហូតដល់សាលាវិទ្យាល័យ ដែលមានសិស្សសរុបប្រមាណជា១៥០០នាក់ និងមានបុគ្គលិកសិក្សាចំនួន១០០នាក់។

សែត ឡាង ជាគ្រូបង្រៀននៅថ្នាក់វិទ្យាល័យ ដែលបានបំពេញកិច្ចការងារអប់រំនេះ ជាមួយក្រុមដូនជីជាង៧ឆ្នាំមកហើយ បាននិយាយថា៖ «យើងមកទីនេះ យើងមានអារម្មណ៍ថា ស្រឡាញ់ក៏ដូចជាចូលចិត្តរបៀបនៃការដឹកនាំក៏ដូចជាបេសកកម្មរបស់បងស្រីទាក់ទងនឹងការបម្រើយុវជន។»

អ្នកគ្រូបានឲ្យដឹងទៀតថា បើនិយាយអំពីប្រាក់ខែគឺមានចំនួនតិចតួចទេ ប៉ុន្តែ បងស្រីអត់មានប្រាក់ខែទេ គាត់មកពីផ្ទះរបស់គាត់ ពីប្រទេសនានាមក វប្បធម៌ ភាសា ម្ហូប គឺអត់ត្រូវទេ តែគាត់មានទឹកចិត្តបម្រើយុវជនខ្លាំងមែនទែន។ «វាចំបេះដូងរបស់ខ្ញុំ ធ្វើឲ្យខ្ញុំស្រឡាញ់ ហើយខ្ញុំគិតថាប្រាក់ខែប៉ុណ្ណឹងយើងអាចរស់បាន ហើយយើងក៏អាចចូលរួមកសាងធនធានមនុស្ស ជាឆន្ទៈដែលយើងចង់បាន។» អ្នកគ្រូឡាងបញ្ជាក់។

ដូនជីតេរេសា បានបន្ថែមថា ទិសដៅរបស់ក្រុមគ្រួសារសាលេស៊ានដុនបូស្កូ គឺអប់រំដល់យុវជននិងកុមារឲ្យមានសីលធម៌ គុណធម៌ក្នុងការរស់នៅ មិនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ។

ដូនជីឲ្យដឹងទៀតថា យើងមានបំណងចង់បង្កើតឲ្យមានសាលានៅភូមិភាគកំពង់ចាម ប៉ុន្តែយើងមិនទាន់មានដូនជីគ្រប់គ្រាន់នៅឡើយ។

ក្រុមដូនជីសាលេស៊ានដុនបូស្កូឬបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់ បានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២។ បច្ចុប្បន្នក្រុមដូនជីមានសាលាចំនួន៣ទីតាំងនៅក្នុងទីក្រុងភ្នំពេញក្នុងនោះមានមត្តេយ្យសិក្សាដល់បឋមសិក្សានៅភូមិច្រេសមត្តេយ្យសិក្សាដល់វិទ្យាល័យនៅទឹកថ្លា និងមត្តេយ្យសិក្សា និងផ្នែកបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅទួលគោក រីឯមួយទីតាំងទៀតនៅខេត្តបាត់ដំបង ជាមណ្ឌលសម្រាប់យុវតីស្នាក់នៅដើម្បីសិក្សារៀនសូត្រ៕

# ព្រះសហគមន៍ភូមិភាគភ្នំពេញ៖ ធ្វើដំណើររួមគ្នាជាផ្លូវតែមួយ ចូលរួមប្រកាសដំណឹងល្អ

*អត្ថបទ៖ ដាលីស*

ព្រះសហគមន៍ភូមិភាគភ្នំពេញ សរុបចម្លើយសន្និបាតព្រះសហគមន៍ ២០២២-២០២៣៖ «ធ្វើដំណើររួមគ្នា ជាផ្លូវតែមួយ ចូលរួម ប្រកាសដំណឹងល្អ» នៅមណ្ឌលសកម្មភាពភូមិភាគភ្នំពេញ ដោយមានតំណាងគ្រីស្តបរិស័ទពីព្រះសហគមន៍ នៃតំបន់សកម្មភាពទាំង៩ គ្រប់ការិយាល័យ និង អង្គការកាតូលិកនានា ក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ ប្រមាណជាង២០០នាក់ នាថ្ងៃទី១៤ ឧសភា ២០២២។




លោកអភិបាលព្រះសហគមន៍ អូលីវីយេ ឝ្មិត ហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានណែនាំអង្គប្រជុំដោយមានប្រសាសន៍ថា ថ្ងៃនេះជួបជុំគ្នាយ៉ាងឱឡារិក ដើម្បីចូលរួមបូកសរុបយោបល់ សម្រាប់មហាសន្និបាត២០២១-២០២៣ ជាពេលវេលាពិសេសដោយស្តាប់ចម្លើយសំណួរទាំង៣ របស់មហាសន្និបាត របស់គ្រីស្តបរិស័ទ អ្នកដឹកនាំព្រះសហគមន៍ បព្វជិត-ជិតា គ្រហស្ថ និងអង្គការកាតូលិកក្នុងភូមិភាគភ្នំពេញ ដែលទាក់ទងទៅនឹងរបៀបរបស់ព្រះសហគមន៍ដើររួមគ្នា ទាំងអំណរសប្បាយ និងឧបសគ្គនានា និងរបៀបនៃការប្រកាសដំណឹងល្អរួមគ្នា។ លោកអភិបាលបន្ថែមថា តាមចម្លើយរបស់បងប្អូនតាមតំបន់សកម្មភាព ដែលបងប្អូនបានឆ្លើយរួមគ្នា នេះក៏ជាផែនការណ៍សម្រាប់ភូមិភាគភ្នំពេញយើងផងដែរ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានអញ្ជើញព្រះសហគមន៍តាមភូមិភាគនីមួយៗនៅទូទាំងសកលលោក កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ ឲ្យបើកសន្និបាតព្រះសហគមន៍សកលតាមកន្លែងនីមួយៗ។ នៅថ្ងៃនោះ លោក អូលីវីយេ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បានបើកសន្និបាតព្រះសហគមន៍នេះសម្រាប់ភូមិភាគភ្នំពេញយ៉ាងឱឡារិក ដោយមានតំណាង ពីរនាក់ៗ ពីព្រះសហគមន៍នានាទាំង៩តំបន់សកម្មភាព ក្រុមបព្វជិត-ជិតា លោកបូជាចារ្យ និងស្ថាប័ននានា ក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ ចូលរួមសរុបចំនួន៥០នាក់ប៉ុណ្ណោះ ព្រោះស្ថិតនៅក្នុងបម្រាមជួបជុំដើម្បីប្រយុទ្ធប្រឆាំងការរីករាលដាលនៃកូវីដ១៩។

បន្ទាប់ពីបើកសន្និបាតយ៉ាងឱឡារិកនេះ លោកអភិបាលអូលីវីយេបានផ្ញើសំណួរចំនួន៣ ទៅកាន់តំបន់សកម្មភាពទាំង៩ ក្រុមបព្វជិត បព្វជិតា ការិយាល័យនានា និងអង្គការនានាក្នុងភូមិភាគនេះរិះគិតរួមគ្នា។

សកម្មភាពទាំង៩ ក្រុមបព្វជិត បព្វជិតា ការិយាល័យនានា និងអង្គការនានាក្នុងភូមិភាគនេះរិះគិតរួមគ្នា។ សំណួរទាំងបីរួមមាន៖

១) តើនៅក្នុងព្រះសហគមន៍របស់ខ្ញុំផ្ទាល់ ខ្ញុំដើររួមជាមួយគ្នាយ៉ាងដូចម្តេច តាមរយៈក្រុមនានា និងគណៈកម្មការ ?

២) នៅពេលយើងធ្វើដំណើរ រួមជាមួយគ្នា នៅក្នុងព្រះសហគមន៍របស់យើងផ្ទាល់ តើយើងជួបឧបសគ្គអ្វីខ្លះ? តើយើងជួបអំណរសប្បាយអ្វីខ្លះ ?

៣) តាមបទពិសោធន៍របស់យើងនៅការធ្វើដំណើររួមជាមួយគ្នា នៅក្នុងព្រះសហគមន៍របស់យើងផ្ទាល់ តើយើងត្រូវការកែអ្វីខ្លះ ដើម្បីឲ្យយើងរីកចម្រើន នៅក្នុងការប្រកាសដំណឹងល្អ ដល់បងប្អូនយើងទាំងអស់?

ក្រោយពេលផុតពីបម្រាមជួបជុំដើម្បីប្រយុទ្ធប្រឆាំងកូវីដ-១៩ ក្នុងអំឡុងខែមីនា ដល់ខែមេសា នៅតាមតំបន់សកម្មភាពនីមួយៗ គ្រីស្តបរិស័ទ និងលោកបូជាចារ្យ បព្វជិត បព្វជិតា និងអង្គការកាតូលិកទាំងអស់បានជួបជុំគ្នាជាក្រុមៗ រិះគិតលើសំណួរទាំង៣នោះ ។

នៅថ្ងៃទី ១៣ ខែឧសភា ក្នុងអង្គប្រជុំ លោកបូជាចារ្យទាំងអស់ក្នុងភូមិភាគភ្នំពេញ លោកបូជាចារ្យ ប្រធាន ការិយាល័យយុវជន ការិយាល័យអប់រំជំនឿ និងការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក បានប្រមូលចម្លើយ ទាំងអស់ ដាក់បញ្ចូលគ្នា សរុបចម្លើយទាំងអស់ដើម្បីពិភាក្សាក្នុងសន្និបាតតំណាងព្រះសហគមន៍ទាំងអស់ នៅថ្ងៃទី១៤ ខែឧសភា ។

នៅថ្ងៃទី ១៤ ខែឧសភា តំណាងគ្រីស្តបរិស័ទ សាសនទូត បព្វជិតបព្វជិតា អង្គការនានា និងការិយាល័យនានាក្នុងភូមិភាគ ប្រមាណជាង២០០នាក់ បានពិនិត្យឡើងវិញ និងបានសរុបចម្លើយទាំងអស់រួមជាមួយគ្នា ព្រមទាំងបានប្រគល់ជូនលោក អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញយ៉ាងឱឡារិក នៅក្នុងពិធីអភិបូជា បុណ្យរំលឹកសន្តម៉ាទីយ៉ាស។

បន្ទាប់ពីបានស្តាប់ ចម្លើយរបស់គ្រីស្តបរិស័ទ លោកអភិបាល អូលីវីយេបញ្ជាក់ក្នុងធម្មទេសនាថា បងប្អូនជាតំណាងព្រះសហគមន៍ ដែលបានចួបជុំគ្នានៅទីនេះសម្រាប់ភូមិភាគភ្នំពេញទាំងមូល យើងជាទូត ដែលទទួលតួនាទី ជាមាត់ ជាត្រចៀក និង ជាសំឡេង តាមកន្លែងនីមួយៗ ដើម្បីឱ្យគំនិតដែលយើងបានស្តាប់នៅក្នុងថ្ងៃនេះទៅដល់ភូមិភាគភ្នំពេញទាំងមូល។

លោកបន្តថាគ្រីស្ត បរិស័ទជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។ នេះជាអំណោយទានពិសេសដែលយើងបានទទួលពីព្រះជាម្ចាស់។ មិត្តសម្លាញ់របស់ព្រះយេស៊ូរស់នៅតាមរបៀបថ្មីដើម្បីធ្វើជាសាវ័កសព្វថ្ងៃក្នុងសង្គមរបស់យើង។ វិន័យរបស់ខ្ញុំគឺអ្នកស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ (យហ១៤)។ សម្រាប់ព្រះសហគមន៍យើងកំពុងធ្វើដំណើជាមួយគ្នា រិះគិតពិរចារណាធ្វើ ដូចម្តេច ដើម្បី ប្រកាស ដំណឹងល្អ? ចម្លើយគឺស្រលាញ់គ្នាទៅវិញទៅមក ព្រោះព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។

សម្រាប់សំនួរទី២ លោកអភិបាលអូលីយេ លើកឡើងថា សម្រាប់ចម្លើយមួយអំពីអំណរសប្បាយរបស់យើងគឺ «អំណោយទាន នៃជីវិត»។ ជីវិត ដែលយើងបានទទួលពីព្រះជាម្ចាស់។ ជាអំណោយទានយ៉ាងពិសេស ដែលយើងទទួលតាមរយៈអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញានានាដែលយើងទទួលជាប្រចាំ ដើម្បីទៅជាមនុស្សថ្មី។ ជីវិតដែលទទួលនៅលើផែនដីនេះ គឺដើម្បីរៀបចំសម្រាប់ឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ចនៅស្ថានបរមសុខ។

លោកអភិបាលអូលីវីយេបញ្ជាក់ទៀតថា យើងក៏បានស្តាប់អំពីទុក្ខលំបាក។ ទុក្ខលំបាកទាំងអស់ដែលយើងបានស្តាប់ គឺជាប់ជាមួយប្រវត្តិសាស្ត្ររបស់យើង គឺដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ប៉ុលពត ជាង២០ឆ្នាំយើងគ្មានឱកាសជួបជុំគ្នា ដោយគ្រូគង្វាលរបស់យើង បព្វជិត បព្វជិតារបស់យើងបានទទួលមរណភាពក្នុងសម័យប៉ុលពត។ ទុក្ខលំបាកនេះ នាំឲ្យដាច់ឫសនៃការបន្តជំនឿ សម្រាប់អ្នកជំនាន់ក្រោយ។ ជាបញ្ហាប្រឈមមួយ គ្រីស្តបរិសកាតូលិកខ្មែរស្ទើរតែទាំងអស់សព្វថ្ងៃ ជាពន្លកថ្មីនៃជំនឿជំនាន់ទី១។

លោកបញ្ជាក់ថា «ទុក្ខលំបាកមួយនេះ ទៅជាកម្លាំងមួយដែរ»។ បងប្អូននៅទីនេះជាគ្រីស្តបរិស័ទជំនាន់ទីមួយ នឹងមានកូនចៅ ហើយបញ្ជូនបន្តជំនឿ ដែលនេះជាសេចក្តីសង្ឃឹមមួយរបស់ព្រះសហគមន៍។ លោកបន្តថា ទុក្ខលំបាក១ទៀត តើត្រូវធ្វើយ៉ាងណាដើម្បីឲ្យការប្រកាសដំណឹងល្អនៅលើទឹកដីកម្ពុជា អាចចាក់គ្រឹះយ៉ាងជ្រៅបំផុតនៅក្នុងភាសា ប្រពៃណី វប្បធម៌របស់ខ្មែរ៕

# បុណ្យគោរពព្រះកាយព្រះលោហិតព្រះគ្រីស្ត និងអបអរសាទរដល់បេក្ខជនបេក្ខនារី១៦នាក់ទទួលព្រះកាយលើកដំបូង

*អត្ថបទ៖ ព្រះសហគមន៍កាតូលិកខេត្តបាត់ដំបង*

នៅថ្ងៃទី១៩ខែមិថុនា ឆ្នាំ២០២២ ព្រះសហគមន៍កាតូលិកបាត់ដំបង បានប្រារព្ធកម្មវិធីបុណ្យគោរពព្រះកាយព្រះលោហិតព្រះគ្រីស្ត និងអបអរសាទរបេក្ខជន បេក្ខនារី១៦នាក់ ទទួលអគ្គសញ្ញាទទួលព្រះកាយលើកដំបូង ។ កម្មវិធីបុណ្យនេះបានរៀបជាក្បួនដង្ហែព្រះកាយនៅជុំវិញភូមិ ដោយមានលោកបូជាចារ្យប្រោះទឹកព្រះពរដល់បងប្អូនផងដែរ។ ក្នុងធម្មទេសនាលោកអភិបាលទេព ច័ន្ទពិសិដ្ឋ (គីគេ) បានមានប្រសាសន៍ថា៖ «ព្រះកាយព្រះគ្រីស្ត គឺជាវត្តមានរបស់ព្រះយេស៊ូគ្រីស្តដែលគង់នៅជាមួយយើង ព្រះអង្គមិនបោះបង់ពួកយើងចោល។ យើងទទួលព្រះកាយដើម្បីឲ្យព្រះយេស៊ូ គ្រីស្តគង់នៅជាមួយយើង ព្រោះព្រះអង្គចង់មានវត្តមាននៅក្នុងជីវិតយើង។ ព្រះកាយព្រះគ្រីស្តរំលឹកយើងពីការរងទុក្ខលំបាករបស់ព្រះយេស៊ូ មុនពេលអង្គរងទុក្ខលំបាកព្រះអង្គមានពិធីជប់លៀងជាមួយក្រុមសាវ័ក ហើយយកនំប៉័ងមកកាន់អរព្រះគុណព្រះជាម្ចាស់ ដើម្បីឲ្យយើងដឹងថាព្រះយេស៊ូមានវត្តមាននៅក្នុងនំនោះ ដូច្នេះពេលណាយើង ទទួលព្រះកាយព្រះគ្រីស្ត យើងរំលឹកថាព្រះអង្គទទួលការលំបាក និងបូជាជីវិតដើម្បីសង្គ្រោះមនុស្សលោក។ ហើយយើងក៏ចូលរួមទុក្ខលំបាកជាមួយព្រះយេស៊ូដែរ។ ពេលយើងទទួលព្រះកាយ យើងទទួលបានកម្លាំងពីព្រះអង្គ ទាំងកម្លាំងចិត្ត និងកម្លាំងកាយ ដើម្បីបន្តដំណើរទៅខាងមុខរួមជាមួយគ្នាដោយក្តីស្រឡាញ់»។

ជាមួយគ្នានោះដែរបេក្ខនារី ម៉ាឡៃ សុមេត្តា ជាបេក្ខនារីម្នាក់ក្នុងចំណោមបេក្ខជនបេក្ខនារី១៦នាក់បានលើកឡើងថា៖ «ខ្ញុំមានអំណរសប្បាយដែលបានទទួលព្រះកាយលើកដំបូង ខ្ញុំមានជំនឿលើព្រះកាយ ព្រោះជួយឲ្យខ្ញុំកាន់តែជិតស្និតជាមួយព្រះជាម្ចាស់ខ្លាំងជាងមុន ជួយឲ្យខ្ញុំហ៊ានប្រកាសជំនឿដល់អ្នកដទៃ និងមានចិត្តធម៌មេត្តាករុណាចំពោះជនក្រីក្រ និងអ្នកដែលគ្មានទីពឹង»។

# ព្រះសហគមន៍កាតូលិកនឹករឭកដល់អគ្គសញ្ញាជាបូជាចារ្យក្នុងថ្ងៃព្រហស្បតិ៍ពិសិដ្ឋ

*អត្ថបទ៖ ដាលីស*

ព្រះវិហារសន្តយ៉ូសែប(ស្អាង) ក្នុងមណ្ឌលសកម្មភាពបាសាក់នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នឹករឭកដល់អគ្គសញ្ញាជាបូជាចារ្យក្នុងពិធីបុណ្យអភិបូជាថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ដែលជាត្រៃទិវារបស់ព្រះសហគមន៍កាតូលិក។

ពិធីនេះធ្វើឡើងក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតហាស្លេរ នាល្ងាចថ្ងៃទី ១៤ មេសា ២០២២ ក្នុងស្រុកស្អាង ខេត្តកណ្ដាល។

នៅក្នុងឱកាសនេះដែរ លោកអភិបាលអូលីវីយេ មានថ្លែងនៅក្នុងធម្មទេសនាដោយរំឭកដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណី ១៤ មេសា កាលពីម៉ោង១០ នៅប្រទេសកម្ពុជាទាំងមូលចូលឆ្នាំថ្មី និងយើងនឹករលឹកដល់១៤ មេសា ១៩៧៥ ដែលលោកអភិបាលតែងតាំងលោកឆ្មារ សាឡាស ជាអភិបាលព្រះសហគមន៍ជាតិខ្មែរមុនគេបង្អស់។ លោកអភិបាលអូលីវីយេ មានប្រសាសន៍បន្តថា ថ្ងៃនេះយើងរំឭកដល់ថ្ងៃលោកបូជាចារ្យទាំងអស់រំឭកពាក្យសច្ចារបស់ខ្លួនជាបូជាចារ្យ។

ផ្លែនៃការបម្រើគឺជាសុខសន្តិភាព ផ្លែនៃសន្តិភាពគឺភាពស្ងៀមស្ងាត់ ផ្លែនៃភាពស្ងៀមស្ងាត់គឺការអធិដ្ឋាន ផ្លែនៃការអធិដ្ឋានគឺជាជំនឿ ផ្លែនៃជំនឿគឺជាសេចក្តីស្រឡាញ់ ផ្លែនៃសេចកីស្រឡាញ់គឺការបម្រើ ផ្លែនៃការបម្រើគឺសេចក្តីសុខសាន្ត។

លោកអភិបាលអូលីវីយេបានដាស់តឿនថា ៖ «ដោយសារព្រះអង្គស្រឡាញ់គេគឺព្រះអង្គស្រឡាញ់រហូតដល់ទីបំផុត គឺរហូតដល់ព្រះអង្គលាងជើងឱ្យពួកគេ»។

លោកអភិបាលបន្តដោយរំឭកពីពាក្យរបស់សន្តីតេរេសានៃក្រុងកាល់គូតាថា ផ្លែនៃភាពស្ងៀមស្ងាត់គឺការអធិដ្ឋាន ផ្លែនៃការអធិដ្ឋានគឺជំនឿ នៅពិតមែនការអធិដ្ឋាននៅក្នុងភាពស្ងៀមស្ងាត់ព្រះយេស៊ូបានអធិដ្ឋាន បង្ហាញជំនឿរបស់ព្រះអង្គរហូតដល់ពាក្យចុងក្រោយនៅលើឈើឆ្កាង និងរបៀបដែលព្រះយេស៊ូប្រកាសដំណឹងល្អប្រៀបដូចព្យាបាលជំងឺ គឺព្រះយេស៊ូមើលគេដោយព្រះហឫទ័យនៃសេចក្តីស្រឡាញ់និងព្រះហឫទ័យប្រណីសន្តោសមេត្តាករុណា។

ព្រះយេស៊ូបានទតមើលលោកសិលាដោយព្រះហឫទ័យអាណិតអាសូរ និងលើកលែងទោស។ ជំនឿរបស់ព្រះយេស៊ូណែនាំឱ្យមនុស្សលោកពេញដោយសេចកីស្រឡាញ់ដ៏ធំធេងជាសេចកីស្រឡាញ់ដ៏បរិសុទ្ធដ៏ពេញលក្ខណៈ។ នេះជាប្រសាសន៍របស់លោកអភិបាលអូលីវីយេ គង្វាលព្រះសហគមន៍ក៏បានលើកទឹកចិត្តដល់អស់លោកបូជាចារ្យ និងគ្រីស្តបរិស័ទដោយមានប្រសាសន៍ថា ការបម្រើ អធិដ្ឋាន ការលើកលែងទោសឱ្យអ្នកដទៃ។ លោកក៏បានណែនាំដោយស្នើឱ្យគ្រីស្តបរិស័ទចូលរួមអធិដ្ឋានរួមជាមួយសន្តោតេរេសានៃព្រះកុមារយេស៊ូផងដែរ។ នៅក្នុងពាក្យអធិដ្ឋាននេះពិភពលោករបស់យើងមានសេចក្តីសង្ឃឹមតែមួយគឺរកឃើញសេចក្តីសុខសាន្តសាជាថ្មី។

លោកបានអញ្ជើញលោកបូចាចារ្យ និងគ្រីស្តបរិស័ទឱ្យអធិដ្ឋានរួមជាមួយសន្តីតេរេសាដែលមានខ្លឹមសារជាអាថ៌៖ ប្រសិនបើយើងមើលឃើញអយុត្តិធម៌ដែលណែនាំឱ្យបងប្អូនឱ្យគេឈឺចិត្តនឹងយើងចូលចិត្តដែរ ប្រសិនបើយើងយល់ថាសត្វដទៃជាបងប្អូនរបស់យើងបង្កើត ប្រសិនបើយើងយល់ថាសាសន៍ដទៃជាបងប្អូនបង្កើត យកចិត្តទុកដាក់នៅក្នុងការបម្រើបងប្អូនឯទៀតដែលឈឺចិត្ត ចែករំលែកបានរបស់យើងដោយថែមដួងចិត្តនៃសេចក្តីស្រឡាញ់ដ៏ពិតប្រាកដ។ តើងរស់នៅក្នុងសេចក្តីស្រឡាញ់ ប្រសិនបើសិនបើយើងជឿថាការលើកលែងទោសមានប្រយោជន៍ជាងការសងសឹក នោះសេចក្តីសុខសាន្តអាចយាងមកបាន។

ដោយឡែក លោកបូជាចារ្យ សុខ ណា មានប្រសាសន៍ចែករំលែកអំពីជីវិតជាបូចារ្យនេះថា ថា តាមពិតនៅពេលយើងនិយាយពីបូជាចារ្យ ខ្ញុំមិនចង់មើលពីជីវិតខ្ញុំទេ ប៉ុន្តែខ្ញុំចង់មើលព្រះគ្រីស្តជាមហាបូជាចារ្យ និងអ្វីៗទាំងអស់ដែលបានកើតឡើងជាមួយព្រះយេស៊ូ និងក្រុមគ្រីស្តទូតជាងពីរពាន់ឆ្នាំមុន ជាអ្វីដែលកំពុងតែកើតឡើងសព្វថ្ងៃនេះ។

លោកបញ្ជាក់ថា ៖ «នៅពេលដែលយើងចូលក្នុងសក្ការបូជា យើងចូលនៅក្នុងពេលវេលាតែមួយគត់។ ប្រសិនបើយើងមើលព្រះយេស៊ូ យើងរកឃើញអ្វីៗទាំងអស់ដែលជាខ្លឹមសារនៃជីវិតរបស់បូជាចារ្យ ដោយអំណរសប្បាយ ទុក្ខលំបាក ការស្ម័គ្រចិត្តស្តាប់បង្គាប់ និងលះបង់រហូតដល់ស៊ូប្តូរជីវិត របស់លោកបូជាចារ្យជាព្រះយេស៊ូ ជាកំពូលនៃអ្វីៗទាំងអស់»។

លោកបានបន្តថា រៀងរាល់ថ្ងៃនៅក្នុងជីវិតខ្ញុំជាបូជាចារ្យ ខ្ញុំសប្បាយរៀងរាល់ពេលវេលានៅក្នុងជីវិតរបស់ខ្ញុំពោរពេញដោយសេចក្តីសុខសាន្ត។ នេះមកពីព្រះជាម្ចាស់ដែលស្រឡាញ់ខ្ញុំ ត្រាស់ហៅខ្ញុំឱ្យទៅជាបូជាចារ្យដើម្បីបម្រើព្រះជាម្ចាស់ និងបម្រើព្រះសហគមន៍នៅកម្ពុជាយើង ជាប្រទេស ជាទឹកដីដែលខ្ញុំស្រឡាញ់។ ខ្ញុំចង់សហការជាមួយព្រះជាម្ចាស់ ជាមួយព្រះយេស៊ូ ជាមួយព្រះសហគមន៍ ដោយស្តាប់បង្គាប់ ដែលជាអត្ថន័យដ៏សំខាន់នៅក្នុងជីវិតជាបូជាចារ្យ និងស្តាប់បង្គាប់លោកអភិបាល។

លោកបូជាចារ្យ សុខ ណា ខ្ញុំចង់ស្តាប់ ខ្ញុំចង់ស្រឡាញ់ហើយស្រឡាញ់ទៀតនិងបម្រើអស់មួយជីវិតដោយរៀងរាល់ថ្ងៃ។ អ្វីដែលខ្ញុំបានទទួលគឺខ្ញុំយល់ថាគ្មានអ្វីដែលខ្ញុំត្រូវសង្ស័យពីជីវិតខ្ញុំជាបូជាចារ្យទៀត ដោយសារអំណរសប្បាយ សេចក្តីស្រឡាញ់ ជំនឿ សេចក្តីសុខសាន្ត សុភមង្គលយ៉ាងពិតប្រាកដនៅក្នុងជីវិតខ្ញុំចេះតែហូរហៀររាល់ថ្ងៃ និងរាល់ថ្ងៃសឹងតែទ្រាំមិនបាននៅពេលដែលកើតឡើងច្រើនដង និងនៅពេលដែលខ្ញុំប៉ះធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ នៅពេលដែលខ្ញុំកំពុងបម្រើអគ្គសញ្ញានានានៅក្នុងជីវិតរបស់ខ្ញុំនិងកើតឡើងជាប្រចាំ។

សម្រាប់ខ្ញុំខ្ញុំស្រឡាញ់ជីវិតជាបូជាចារ្យពេញមួយជីវិតរបស់ខ្ញុំ និងសូមជូនពរឱ្យជីវិតអស់លោកដែលទទួលការត្រាស់ហៅជាបូជាចារ្យ ឱ្យយើងសម្លឹងមើលព្រះយេស៊ូគ្រីស្តរបស់យើងជាមហាបូជាចារ្យ និងរស់នៅតាមគំរូព្រះយេស៊ូគ្រីស្តរបស់យើង។

សម្រាប់យុវជនទាំងឡាយអើយកុំឱ្យខ្លាច សូមមានសេចក្តីក្លាហានយ៉ាងពិតប្រាកដ ដោយសារជីវិតយើងជាគ្រីស្តបរិស័ទ យើងទទួលការត្រាស់ហៅពិសេសណាស់ចូលនៅក្នុងជីវិតនេះ និងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយយើងនឹងទទួលសេចក្តីសុខយ៉ាងស្កប់ស្កល់ពិតមែននៅពេលដែលយើងចូលនៅក្នុងជីវិតនៃការត្រាស់ហៅជាលោកបូជាចារ្យ ដោយសារនេះជាអគ្គសញ្ញាឱ្យយើងបន្តជីវិតពោរពេញដោយអំណរសប្បាយពិតមែន និងពោរពេញដោយក្តីសុខនិងកម្លាំងដែរ ដើម្បីឱ្យយើងឈានមុខនៅក្នុងការបម្រើព្រះយេស៊ូគ្រីស្ត បម្រើប្រជាពលរដ្ឋ និងសង្គមជាតិរបស់យើងពិតមែន៕

# លោកវីលៀម ថនតុន បឺន (បៀល) បន្សល់ទុកក្តីស្រឡាញ់សម្រាប់កម្ពុជា

*ដោយ កកស្រីនិ*

«ខ្ញុំនឹងចងចាំអំពើល្អគាត់នៅក្នុងបេះដូង និងក្រុមគ្រួសាររបស់យើងខ្ញុំទាំងអស់នឹងចងចាំគាត់។» នេះជាប្រសាសន៍របស់លោកលោកចាន់ សុភ័ណ្ឌ ជាកូនចិញ្ចឹមរបស់លោកបៀល បានថ្លែងនៅក្នុងពិធីបុណ្យសពនៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន នារាជធានីភ្នំពេញ កាលពីចុងខែមីនា ឆ្នាំ២០២២។

លោក សុភ័ណ្ឌ បន្តថា គាត់សូមអរគុណដល់ព្រះជាម្ចាស់ដែលបានប្រទានលោកបៀលមកលើភពផែនដីនេះ។ គាត់បានជួយទាំងអស់មនុស្សនៅលើពិភពលោកនេះ មិនថាកូរ៉េ ចិន ជប៉ុនឬប្រទេសផ្សេងៗ ជាពិសេសគាត់បានជួយច្រើននៅប្រទេសកម្ពុជាយើង។

រយៈពេលកន្លងមក លោកបៀលបានរស់នៅជាមួយក្រុមគ្រួសាររបស់លោក សុភ័ណ្ឌ ក្រោយពេលវិលត្រឡប់មកពីសហរដ្ឋអាមេរិក។ សុភ័ណ្ឌបន្ថែមថា «ខ្ញុំក៏មិនដឹងសងគុណគាត់យ៉ាងម៉េច មានតែការមើលថែគាត់ ហើយខ្ញុំក៏សោកស្តាយផងដែរដែលខ្ញុំបានបាត់បង់អ្នកទីប្រឹក្សារបស់ខ្ញុំម្នាក់។ នៅពេលដែលខ្ញុំមានបញ្ហាអ្វីមួយខ្ញុំពិភាក្សាជាមួយគាត់មុនគេ ប៉ុន្តែមានតែគាត់ទេយល់ចិត្តខ្ញុំច្រើន។»

ពិធីបុណ្យសពរបស់លោកវីលៀម ថនតុន បឺន (បៀល) (Br. William Thornton Burns_Bill) នៃក្រុមគ្រួសារម៉ារីណុល ត្រូវបានធ្វើឡើងក្រោមអធិបតីភាពរបស់ លោកបូជាចារ្យ ដាមីញ៉ាំង ហ្វារនី និងបូជាចារ្យជាច្រើនរូបទៀត នៅព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុន ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ។

តាមការឱ្យដឹងពីលោកបូជាចារ្យ ដាមីញ៉ាំង ហ្វានី បងប្រុសវីលៀម បៀល បានរស់នៅកម្ពុជាជាង២០ឆ្នាំ ធ្វើជាសក្ខីភាពអំពីព្រះយេស៊ូអំពីវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង អំពីព្រះជាម្ចាស់ក្នុងព្រះសហគមន៍របស់យើងនៅកម្ពុជា។

លោកបូជាចារ្យ ដាមីញ៉ាំង «បងប្រុសបៀលមិនមែនជាបងប្រុសម៉ារីណុល ក៏ប៉ុន្តែចិត្តរបស់គាត់នៅជាមួយម៉ារីណុល ហើយអ្វីដែលគាត់បានធ្វើសម្រាប់ព្រះជាម្ចាស់ រួមជាមួយនិងក្រុមម៉ារីណុលតាមស្មារតី របស់ក្រុមម៉ារីណុល ហើយបងប្រុសបៀល គាត់ជាថ្មដ៏រឹងមាំមួយនៃព្រះវិហារយើង។»

កុមារបៀលកើតនៅថ្ងៃទី១៧ខែឧសភាឆ្នាំ១៩៤៣ នៅសហរដ្ឋអាមេរិក។ លោកជាកូនទី៣ ដែលមានបងប្រុសពីររូប។ ពេលចម្រើនវ័យ និងបញ្ចប់ការសិក្សា លោកបានអភិវឌ្ឍខ្លួនជាសាស្ត្រាចារ្យ ដោយបង្រៀននៅសាកលវិទ្យាល័យ Jesuit Sogang នៅប្រទេសកូរ៉េ ប្រទេសអារ៉ាប់ខាងត្បូង និងប្រទេសហ្វីលីពីន នាឆ្នាំ ១៩៦៥ដល់ឆ្នាំ២០០១។

ក្នុងឆ្នាំ២០០១ លោកបានទទួលបេសកកម្មស្ម័គ្រចិត្តមកប្រទេសកម្ពុជាតាមរយៈអង្គការម៉ារីណុល ដោយបង្រៀនភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងចូលរួមជាសាមាជិកភាពនៃក្រុមអ្នកនៅលីវដើម្បីប្រកាសដំណឹងល្អ។ លោកបានវិលត្រលប់ទៅសហរដ្ឋអាមេរិកវិញក្នុងឆ្នាំ២០១៣ និង៤ឆ្នាំក្រោយមកលោកបៀលបានសម្រេចចិត្តកម្ពុជាម្តងទៀត រហូតដល់ជីវិតចុងក្រោយរបស់លោក ដោយទទួលមរណភាពនៅក្នុងប្រទេសកម្ពុជាកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។

ក្នុងពេលធម្មទេសនា ក្នុងពិធីបុណ្យសពនេះ លោកបូជាចារ្យឆាលី ឌីដម៉ែយ៉រ ជាបូជាចារ្យនៃក្រុមគ្រួសារម៉ារីណុលបាននិយាយពីជីវិតរបស់លោកបៀលថា៖ ដោយបៀលបានមកកម្ពុជាមិនមែនព្រោះតែគ្មានអាហារបរិភោគនៅសហរដ្ឋអាមេរិកទេ ហើយក៏មិនមែនព្រោះតែបញ្ហានៅទីនោះដែរ។

លោកបូជាចារ្យឆាលីបន្ថែមថា បៀលមកដោយសារតែសេចក្តីស្រឡាញ់ចំពោះបងប្អូននៅទីនេះ ដើម្បីជួយដល់បងប្អូនទៅតាមជំនាញនិងលទ្ធភាពដែលគាត់មាន។ បៀលបានរៀបចំកន្លែងពិសេសមួយនៅក្នុងបេះដូងរបស់គាត់ សម្រាប់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់សុភណ្ឌ និងគ្រួសាររបស់គាត់ ទោះបីជាទំនៀមទម្លាប់ អាហារ និងភាសាខុសគ្នា ប៉ុន្តែសេចក្តីស្រឡាញ់បានអញ្ជើញគាត់ឱ្យស្នាក់នៅកម្ពុជារហូតដល់ថ្ងៃស្លាប់។

នៅក្នុងជីវិតរបស់លោកបៀល មានទំនាក់ទំនងយ៉ាងជ្រៅជាមួយជនជាតិខ្មែរ នេះបើយោងតាមការឱ្យដឹងពី ដូនជីវីជីណា ពេលីគ័រ នៃក្រុមគ្រួសារម៉ារីណុលនៅកម្ពុជាដែលជាអ្នកអានសារលិខិតរបស់ក្រុមគ្រួសាររបស់លោកបៀល។

តាមខ្លឹមសារនៃលិខិតនោះ បានឱ្យដឹងថា «គ្រួសារលោកបៀល សូមថ្លែងអំណរគុណដល់ប្រជាជនកម្ពុជាទាំងអស់ ដែលបានរួមចំណែកក្នុងជីវិតរបស់លោកបៀល។ លោក បៀល ពិតជាមានអារម្មណ៍ថាប្រទេសកម្ពុជា គឺជាផ្ទះរបស់គាត់ ហើយគាត់មានបំណងតម្កល់អដ្ឋិធាតុនេះ នៅព្រះវិហារដែលគាត់បានចូលរួមអភិបូជានៅកម្ពុជា។»

លោកបូជាចារ្យ ដាមីញ៉ាំង ហ្វារនី ប្រោះទឹកប្រទានពរជាចុងក្រោយដល់សពលោក បៀល និងទូលអង្វរព្រះជាម្ចាស់ដោយផ្ញើគាត់ក្នុងព្រះហស្តរបស់ព្រះអង្គ ដោយរួមជាមួយក្តីសង្ឃឹម និងជឿជាក់ថា យើងគ្រប់ៗគ្នា ដែលនិងទទួលជីវិតថ្មីដ៏រុងរឿង តាមរយៈព្រះយេស៊ូគ្រីស្ត។

សពលោកបៀលត្រូវបានបូជា ហើយអដ្ឋិធាតុរបស់លោកត្រូវបានតម្កល់នៅព្រះវិហារព្រះកុមារបឹងទំពុន នារាជធានីភ្នំពេញ៕

# សន្តអាសនៈ តែងតាំងលោកអភិបាលថ្មី ប្រចាំព្រះសហគមន៍កាតូលិក ប៉ាក់សេ ប្រទេសឡាវ

*អត្ថបទ៖ បរទេស*

សន្តអាសនៈបានតែងតាំងលោកបូជាចារ្យ អន់ឌ្រេ ស៊ុកសាវ៉ាត លូអាន អាសា (Rev. Fr. Andrew Souksavath Nouane Asa) ដែលជាបូជាចារ្យ និងបច្ចុប្បន្នជាអភិបាលស្តីទីព្រះសហគមន៍ភូមិភាគបាក់សេ ទៅជាអភិបាលព្រះសហគមន៍ ភូមិភាគកាតូលិកប៉ាក់សេ ប្រទេសឡាវ។

លោកបូជាចារ្យ អន់ឌ្រេ ស៊ុកសាវ៉ាត លូអាន អាសា កើតនៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៧២ នៅទីក្រុង ប៉ាក់សេ ជាកន្លែងដែលលោកបានចូលរៀននៅអនុវទេវិទ្យាពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩១។ ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ១៩៩៦ លោកបានសិក្សានៅសាកលវិទ្យាល័យគរុកោសល្យនៃទីក្រុងវៀងចន្ទ ដោយទទួលបានសញ្ញាបត្រជាគ្រូបង្រៀន ភាសាអង់គ្លេស។

ពីឆ្នាំ ១៩៩៨ ដល់ ២០០២ លោក អន់ឌ្រេ ស៊ុកសាវ៉ាត លូអាន អាសា បានសិក្សាទស្សនវិជ្ជានៅទេវវិទ្យាល័យ ព្រះគ្រីស្តជាព្រះមហាក្សត្រ (The Seminary of Christ the King) នៅទីក្រុង ប្រ៊ីដធីស កូឡុមបៀ (British Columbia) ប្រទេសកាណាដា។ ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៦ លោក សិក្សាទេវវិទ្យា នៅ ទេវវិទ្យាល័យ សន្ត យ៉ូសែប (Saint Joseph Seminary) នៅអេដមុនតុន ( Edmonton) នៅ រដ្ឋ អាប៊ែតា(Alberta) ដោយទទួលបានបរិញ្ញាបត្រផ្នែកទេវវិទ្យា។

លោក អន់ឌ្រេ ស៊ុកសាវ៉ាត លូអាន អាសា បានអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៦ នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគប៉ាក់សេ ។

បន្ទាប់ពីទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យជាលើកដំបូង លោកបានទទួលខុសត្រូវបម្រើព្រះសហគមន៍ចំនួន១០កន្លែង ពីឆ្នាំ២០០៧-២០០៩ ។ លោកជាប្រធានយុវជនភូមិភាគប៉ាកសេ ពីឆ្នាំ២០០៧-២០១២។

បន្ទាប់មកលោកបានបន្តការសិក្សាបន្ថែមទៀតលើមុខវិជ្ជា ទេវវិទ្យា នៅមហាវិទ្យាទេវវិទ្យាសន្តវ៉ាំងសង់ (Saint Vincent School of Theology) នៃសាកលវិទ្យាល័យ អាដាមសុន (Adamson University) ក្នុងទីក្រុងម៉ានីលប្រទេសហ្វីលីពីន ពីឆ្នាំ២០០៨-២០១០។

ក្រោយមកលោកត្រលប់មកប្រទេសឡាវវិញ លោកទទួលខុសត្រូវបម្រើ ព្រះសហគមន៍ចំនួន១២កន្លែង ពីឆ្នាំ ២០១០-២០១៧។ ចាប់តាំងពីឆ្នាំ២០១២ មកលោកជាសាស្ត្រាចារ្យទស្សនវិជ្ជានៅទេវវិទ្យាល័យ សន្ត យ៉ូហាន ម៉ារី វីយ៉ាណេ (Saint Jean-Marie Vianney Major Seminary) នៅសាវណ្ណាខេត។

ពីឆ្នាំ២០១៧លោកជាបូជាចារ្យទទួលខុសត្រូវលើព្រះសហគមន៍ចំនួន១០ កន្លែង នៅតំបន់បូលីវី និងជាអភិបាលស្តីទី នៅព្រះសហគមន៍ភូមិភាគ ប៉ាក់សេ រហូតមកដល់បច្ចុប្បន្ន ( apostolic administrator sede vacante et ad nutum Sanctae Sedis of the apostolic vicariate of Paks)៕

# ការផ្លាស់ប្តូរមុខងារនិងកន្លែងទទួលខុសត្រូវក្នុងភូមិភាគភ្នំពេញ

*អត្ថបទ៖ សុខ កែវរតនា*

ក្នុងលិខិតចេញផ្សាយកាលពីថ្ងៃទី06 ខែមិថុនា ឆ្នាំ នៅថ្ងៃបុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមាតានៃព្រះសហគមន៍ លោកអភិបាល អូលីវីយេ៉ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រកាសចាត់តាំងមុខងាររបស់បូជាចារ្យតាមតំបន់សកម្មភាពទាំង៩។

ក្នុងលិខិតដដែលនោះបានឱ្យដឹងថា តំបន់សកម្មភាពព្រះសហគមន៍ ភ្នំពេញខាងជើង ទទួលខុសត្រូវដោយលោកបូជាចារ្យ រឿង ផ័ត្រសេរី ក្នុងរយៈពេល៣ឆ្នាំបន្ត ដោយមានលោកបូជាចារ្យ ដាវិឌ ហ្សូរណូ បន្តជួយព្រះសហគមន៍អរិយក្សត្រ ពោធិ ក្តីកណ្តាល រយៈពេល២ឆ្នាំបន្ត។ លោកបូជាចារ្យ អូកូស្ទីន ចុង យេអុន វ៉ុន នឹងនៅជួយព្រះសហគមន៍តំបន់ភ្នំពេញខាងជើង ១ឆ្នាំដើម្បីសិក្សាភាសាខ្មែរ។

តំបន់សកម្មភាពព្រះសហគមន៍ភ្នំពេញថ្មី ទទួលខុសត្រូវដោយ លោកបូជាចារ្យសួន ហង្សលី ដោយមាន លោកបូជាចារ្យ ស៊ីមន ប៊ូម ស៊ុកលី ជាបូជាចារ្យជំនួយ និងលោកបូជាចារ្យ ឆាលស៍ ណានី កាលេ ជាបូជាចារ្យទទួលខុសត្រូវអនុតំបន់កំពង់ស្ពឺ ត្រែងត្រយឹង និងអង្គស្នួល។ រីឯលោកបូជាចារ្យ អារ៉ូគីយ៉ាដូស្ស វណ្ណាថាយ៉ាន បន្តជួយព្រះសហគមន៍ភ្នំពេញថ្មី ភ្នំពេញខាងជើង និងភ្នំពេញខាងត្បូងផងដែរ។

តំបន់សកម្មភាពព្រះសហគមន៍ ភ្នំពេញខាងត្បូង ទទួលខុសត្រូវដោយលោកបូជាចារ្យ ដាមីញ៉ាំង ហ្សារនី ក្នុងរយៈពេល៣ឆ្នាំបន្ត។

តំបន់សកម្មភាព ព្រះសហគមន៍ កំពត- កែប ទទួលខុសត្រូវដោយលោកបូជាចារ្យ ជីអូវ៉ាន់នី ទូលីណូ រួមជាមួយលោកបូជាចារ្យ ប៉ូល ស៊ីហារ៉ាត់ ផ្រុមផុង (ប៊ីត) ដែលជាបូជាចារ្យជំនួយ។

តំបន់សកម្មភាពព្រះសហគមន៍ ទន្លេបាសាក់ ទទួលខុសត្រូវដោយលោកបូជាចារ្យ សុខ ណារួមជាមួយលោកបូជាចារ្យ យ៉ូហានបាទីស្ត ឌូ ទានឌុង(យុង) និងលោកបូជាចារ្យ នីកុន ប្រាស៊ូតសែងចាន់ ជាបូជាចារ្យជំនួយ។ រីឯលោកបូជាចារ្យ សិលាឡេ វ៉ាន់ទិន បានសុំលាលែងពីមុខងារដោយលោកចូលនិវត្តន៍ ហើយស្នាក់នៅនៅព្រះសហគមន៍ជ្រៃធំ។

តំបន់សកម្មភាពព្រះសហគមន៍ទន្លេមេគង្គ ទទួលខុសត្រូវដោយលោកបូជាចារ្យវីរៈជ័យ ស្រ៊ីប្រាម៉ុង និងលោកបូជាចារ្យ អាប្រាហាម ខុន បន្តទៀត។

តំបន់សកម្មភាពព្រះសហគមន៍ តាកែវ ទទួលខុសត្រូវដោយលោកបូជាចារ្យ ឆាលស៍ អេគូមវ៉ាម ឡិឈិប៉ាន រួមជាមួយបូជាចារ្យ ចន ប៉េងជាបូជាចារ្យជំនួយ ព្រមទាំងបូជាចារ្យ ពេត្រូ វ៉ាមូស ជួយពាក់កណ្តាលពេល ។

តំបន់សកម្មភាពព្រះសហគមន៍ សីហនុ ទទួលខុសត្រូវដោយលោកបូជាចារ្យ យ៉ាំង លូកាតាវ៉ូឡា និងតំបន់សកម្មភាពព្រះសហគមន៍ តាខ្មៅ ទទួលខុសត្រូវដោយលោកបូជាចារ្យ អ៊ុន ស៊ុន។

ការផ្លាស់ប្តូរនៅបន្តមុខងារតាមមណ្ឌលសកម្មភាពនេះ គឺចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដានេះតទៅ។

ក្នុងលិខិតដដែលនេះ លោកអភិបាល បានឱ្យដឹងថា ចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២២ នេះ លោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយ៉ា ឌីម៉ុង ដែលបច្ចុប្បន្នជាបូជាចារ្យទទួលខុសត្រូវ តំបន់សកម្មភាពព្រះសហគមន៍ តាខ្មៅ នឹងទៅបន្តការសិក្សានៅឯប្រទេសបារាំង មួយរយៈ។

ក្នុងឱកាសនោះលោកអភិបាល អូលីវីយេ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកបូជាចារ្យទាំងអស់ដែលបានខិតខំស្រលាញ់ និងបម្រើព្រះសហគមន៍ ប្រកបដោយជំនឿមាំមួន និងសេចក្តីសង្ឃឹមយ៉ាងបរិបូរណ៍ ព្រមទាំងលោកបានសូមឱ្យអស់លោកបូជាចារ្យ ត្រៀមខ្លួនជានិច្ចក្នុងបេសកកម្មថ្មី។ លោកអភិបាល អូលីវីយេ ក៏បានផ្ញើសារឱ្យគ្រីស្តបរិស័ទ ទទួលស្វាគមន៍ អស់លោកបូជាចារ្យយ៉ាងកក់ក្តៅក្នុងសេចក្តីស្រឡាញ់ អំណរសប្បាយ និងសូមអធិដ្ឋានសម្រាប់អស់លោកផងដែរ៕

# អគ្គសញ្ញាលាបថ្ងាសជំរុញឲ្យគ្រីស្តបរិស័ទប្រកាសដំណឹងល្អ

*អត្ថបទ៖ ដាលីស*

«អគ្គសញ្ញាលាបថ្ងាសថ្ងៃនេះ ខ្ញុំយល់ថាបានទទួលនូវជីវិតថ្មីបន្ថែមលើអគ្គសញ្ញាជ្រមុជទឹក»។ នេះជាការលើកឡើងរបស់យុវជន ម៉ៅ គីមសេង បេក្ខជនម្នាក់ក្នុងចំណោមបេក្ខជនអគ្គសញ្ញាលាបថ្ងាសចំនួន១៩នាក់។

ក្នុងសម្លៀកបំពាក់ចងក្បិននិងពានាកន្សែងក្រហមប្រាល ជារបៀបប្រពៃណីខ្មែរ គីមសេងបន្តថា អគ្គសញ្ញានេះ ធ្វើឱ្យជីវិតជាគ្រីស្តបរិស័ទរបស់គាត់ពេញលេញ ហើយផ្តល់កម្លាំងឱ្យគាត់អាចក្លាយជាគ្រីស្តបរិស័ទ មានភាពជឿជាក់ និងកាន់តែជិតស្និទ្ធនឹងព្រះជាម្ចាស់ ដោយទទួលបានព្រះវិញ្ញាណដ៏វិសុទ្ធ។

គីមសេងនិងបេក្ខជន១៨នាក់ផ្សេងទៀត បានទទួលអគ្គសញ្ញាលាបថ្ងាស នាព្រឹកថ្ងៃទី៥ ខែមិថុនានេះ នៅព្រះវិហារសន្តយ៉ូសែបផ្សារតូច នារាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ៉ ជ្មីតហាស្លេ និងមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

បេក្ខជនគីមសេងបញ្ជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្តល់កម្លាំង ភាពក្លាហាន ប្រាជ្ញាឈ្លាសវៃ ការកោតខ្លាចព្រះជាម្ចាស់កាន់តែខ្លាំងឡើងថែមទៀត។ លោកបញ្ជាក់ថា «ខ្ញុំនឹងបន្តប្រកាសដំណឹងល្អតាមរយៈស្ថានភាព តាមរយៈពាក្យសម្តី តាមរយៈអំពើល្អ ដែលព្រះជាម្ចាស់បានបង្ហាញមកដល់ខ្ញុំ។ ខ្ញុំនឹងបង្ហាញសេចក្តីស្រឡាញ់របស់ខ្ញុំដល់អ្នកដទៃដូចគ្នា។»

នៅក្នុងពិធីនេះដែរ លោកអភិបាលអូលីវីយេ៉ មានប្រសាន៍ថា ថ្ងៃនេះជាពេលវេលាដែលយើងទន្ទឹងរង់ចាំព្រះយេស៊ូប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឱ្យយើង ដើម្បីចេញទៅប្រកាសដំណឹងល្អ ដោយរស់នៅបង្ហាញវត្តមានរបស់ព្រះជាម្ចាស់។

មានប្រសាសន៍រំលឹកដល់បេក្ខជនទទួលអគ្គសញ្ញាលាបថ្ងាសនៅក្នុងថ្ងៃនេះ គង្វាលព្រះសហគមន៍ណែនាំថា « ថ្ងៃនេះបងប្អូនទាំង១៩នាក់ជាសញ្ញាសំគាល់មួយពិសេស ដើម្បីឲ្យយើងយល់ថា នៅពេលដែលយើងសុខចិត្តធ្វើដំណើរតាមព្រះយេស៊ូ យើងលេងនៅឯកោ។ ដូចព្រះយេស៊ូមានព្រះបន្ទូលសន្យា ខ្ញុំនឹងផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធដែលជាព្រះអង្គដែលជួយការពារនិង បង្រៀន ដឹកដៃអ្នករាល់គ្នានឹងរំលឹកអ្វីដែលខ្ញុំបានប្រាប់ឲ្យអ្នករាល់គ្នាផង។»

ក្នុងនោះដែរលោកអភិបាលបានរំលឹកអំពីដំណើររបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលរួមជាមួយគ្រីស្តបរិស័ទក្នុងពេលដែលរងទុក្ខលំបាកក្នុងសម័យប្រល័យពូជសាសន៍ប៉ុលពត និងជំងឺរាតត្បាតកន្លងមកថា ទោះនៅក្នុងកាលៈទេសៈបែបណាក៏ដោយ ទាំងពេលមានសេរីភាព ទាំងពេលមានភាពតឹងតែង «ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ធ្វើឱ្យយើងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ លែងភ័យខ្លាច ដើម្បីកសាងសន្តិភាពក្នុងដួងចិត្តរបស់យើង ដើម្បីរស់នៅក្នុងសេចក្តីសុខសាន្ត។»

លោកអភិបាលបន្តថា ព្រះវិញ្ញាណយាងមកដើម្បីរំដោះយើងឱ្យរួចពីបាប ដោយរំដោះយើងពីការឈឺចាប់ និង រស់នៅក្នុងជីវិតនិងព្រះជន្មរបស់ព្រះជាម្ចាស់ផ្ទាល់។

លោក រំឭកទៀតថា ទោះគ្រីស្តបរិស័ទបាត់បង់សេរីភាព ក្នុងសម័យខ្មែរក្រហមពិតមែន ក៏ប៉ុន្តែសក្ខីភាពរបស់ពួកគាត់បង្ហាញថា ពួកគាត់នៅទុកពេលវេលាមួយពិសេស ដើម្បីអធិដ្ឋាននៅក្នុងដួងចិត្តផ្ទាល់ខ្លួន។

ជីវិតរបស់យើងពោរពេញដោយកម្លាំងថ្មី ពោរពេញដោយសេរីភាពយ៉ាងប្លែកៗតាមរយៈអំណោយទានទាំង៧របស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនាំឲ្យយើងរស់នៅក្នុងរបៀបថ្មីនៅក្នុងធម៌មេត្តាករុណាក្នុងការអធិដ្ឋាន និងនៅក្នុងការបម្រើ ដែលនេះជាផលផ្លែ នាំឱ្យយើងឈ្នះឧបសគ្គទាំងអស់។ លោកអភិបាលអូលីវីយេ៉ សង្កត់ធ្ងន់ដូច្នេះ។

ក្នុងធម្មទេសនានាឱកាសនោះ លោកអភិបាលភូមិភាគភ្នំពេញបានរំលឹកអំពីការរួមដំណើរជាមួយគ្នារបស់គ្រីស្តបរិស័ទក្នុងសន្និបាត២០២១-២០២៣ ដែលកន្លងទៅនេះ ភូមិភាគភ្នំពេញបានសរុបចម្លើយខ្លះផ្ញើទៅទីក្រុងរ៉ូម ដែលក្នុងនោះមាន៦ចំណុចសំខាន់ៗរួមមាន៖

១.ធ្វើដំណើររួមគ្នានៅក្នុងព្រះសហគមន៍ដោយទុកឱ្យព្រះវិញ្ញាណដ៏វិសុទ្ធរីកចម្រើននៅក្នុងខ្លួនរបស់យើង ដោយយើងខិតខំកែប្រែចិត្តគំនិត

២. ធ្វើធម៌មេត្តាករុណាចេញជាសកម្មភាពជាក់ស្តែងគ្រប់ពេលវេលានៅក្នុងជីវិតរបស់យើង

៣.ឱ្យយើងចេះសហការគ្នា នៅក្នុងព្រះសហគមន៍

៤.ធ្វើដំណើររួមជាមួយគ្នាដោយរកឃើញរបៀបថ្មីក្នុងការប្រកាសដំណឹងល្អ កុំឱ្យយើងភ័យខ្លាច

៥. ឱ្យយើងទៅជាសាសនាទូតនៃសុខសន្តិភាព

៦. វិញ្ញាណដ៏វិសុទ្ធណែនាំយើងឲ្យយើងធ្វើដំណើររួមជាមួយគ្នា នៅក្នុងព្រះសហគមន៍នៅជាមួយ ព្រះនាងម៉ារី ដែលជាមាតាព្រះសហគមន៍ និងជាមាតាយើង។

លោកអភិបាលបានបញ្ជាក់ថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធបានណែនាំព្រះសហគមន៍ជាង២០០០ឆ្នាំ

# កុមារជួបជុំគ្នា បោះជំរំនិងរៀនពីការរស់នៅក្នុងព្រះសហគមន៍និងសង្គម





*អត្ថបទ៖ ដាលីស*

កុមារជាង៣០០នាក់ បានជួបជុំគ្នាបោះជំរំនៅមជ្ឈមណ្ឌលភ្នំពេញថ្មី រិះគិតនិងចូលរួមរៀនអំពីការអភិវឌ្ឍន៍ចំណេះដឹងផ្នែកសង្គមនិងកិច្ចការងាររស់នៅប្រចាំថ្ងៃ ក្រោមប្រធានបទ «អនាគតភ្លឺស្វាងសម្រាប់កុមារទាំងអស់» ដែលដឹកនាំដោយការិយាល័យ យុវជន ជំទង់ កុមារ និងគ្រួសារ នាថ្ងៃទី២៧-២៩ ខែឧសភា ឆ្នាំ២០២២។

កុមារីអាយុ ៨ឆ្នាំ លីន ដាណេ មកពីព្រះសហគមន៍ព្រែកតាទែន បាននិយាយថា នេះជាលើកទី១ដែលនាងបានចូលរួមបោះជំរំនេះ។ ដាណេបន្តថា «ខ្ញុំសប្បាយដោយបានជួបមិត្តភក្តិច្រើន ហើយបានកាដូរថែមទៀត។» កុមារី ដាណេ ប្រាប់ទៀតថា ក្រៅពីសប្បាយ នាងបានរៀនរាំ រៀនរើសសំរាម រៀនសំអាត រៀនសម្តែង «ហើយអ្វីដែលខ្ញុំបានរៀនជួយឱ្យខ្ញុំក្លាយជាកូនល្អ។»

កញ្ញា វ៉ាន់ សុផារី ជាមេកាយឫទ្ធិមកពីព្រះសហគមន៍ចំប៉ានៃមណ្ឌលសកម្មភាពទន្លេមេគង្គ ដែលជាតំបន់មួយមានកុមារវៀតណាមបាននិយាយថា នាងបានចូលរួមក្នុងការិយល័យយុវជន ជំទង់ កុមារនិងគ្រួសារបានរយៈពេលបីឆ្នាំមកហើយ។

សុផារី ឲ្យដឹងទៀតថា ឆ្លងតាមបទពិសោធនៃការដឹកនាំកុមារ និងតាមរយៈការណែនាំរបស់បងៗធ្វើឲ្យនាងស្គាល់សមត្ថភាពខ្លួនឯង។ យុវតីរូបនេះបន្ថែមថា៖«នៅកម្មវិធីនេះធ្វើឱ្យខ្ញុំមានបទពិសោធន៍ខាងល្បែងកម្សាន្តជាច្រើន ដើម្បីនាំយកទៅលេងជាមួយកុមារនៅព្រះសហគមន៍ខ្ញុំក្រោយពេលត្រលប់ទៅវិញ»។

លោក ស៊ាន់ សារឿន ប្រធានការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារបានឱ្យដឹងថា រយៈពេល៣ថ្ងៃនេះ គឺជាកម្មវិធីបោះជំរំរបស់កុមារកាយឫទ្ធិ ដែលមានកុមារមកពីព្រះសហគមន៍នានាក្នុងភូមិភាគភ្នំពេញ។

លោក សារឿន បន្ថែមថា កម្មវិធីនេះបង្កើតឡើងដើម្បីឱ្យកុមារទទួលបាននូវអំណរសប្បាយ ចេះបង្កើតមិត្តថ្មីតាមរយៈទំនាក់ទំនងរវាងកុមារនិងកុមារ និងឱ្យកុមារទទួលបាននូវការអប់រំមានសីលធម៌នៃការរស់នៅអនាម័យ ចេះស្រឡាញ់បរិស្ថាន ស្រឡាញ់ព្រះសហគមន៍ និងស្រឡាញ់គ្រួសាររបស់គេ។

ក្នុងពេលចាប់ផ្តើមនាល្ងាចថ្ងៃដំបូង កុមារនៃព្រះសហគមន៍ទាំងអស់បានចូលរួមរៀបចំ និងអធិដ្ឋានតេហ្សេជាមួយគ្នាផងដែរ។



លោកសារឿន បញ្ជាក់ទៀតថា៖«ខ្ញុំបានឃើញថា រយៈពេល៣ថ្ងៃមកនេះ(យើង)ទទួលបានជោគជ័យមែនទែន ដោយមានទាំងបរិយាកាសអំណរសប្បាយ»។ លោកបន្ថែមទៀតថា កុមារមានទំនាក់ទំនងជាមិត្តភក្តិ និងចូលរួមក្នុងសកម្មភាពជាក្រុមគឺ សម្តែង លេងកម្សាន្ត រស់នៅជាមួយគ្នា និងអធិដ្ឋានជាមួយគ្នា។

តាមរយៈសកម្មភាពរបស់កុមារក្នុងប៉ុន្មានថ្ងៃនេះ លោកសារឿន បញ្ជាក់ថា សកម្មភាពទាំងនេះជាកម្លាំងនាំឱ្យការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសាររបស់យើងមានកម្លាំងបន្ថែមទៀត ដោយមើលឃើញពីផលផ្លែទាំងនេះ។

ការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានបង្កើតឡើងក្នុងឆ្នាំ២០០៣ មានទិសដៅតម្រង់ទិសរបស់កុមារ ជំទង់ យុវជន និងគ្រួសារឲ្យចូលរួមក្នុងព្រះសហគមន៍និងសង្គម អប់រំផ្តល់ចំណេះដឹងបន្ថែមអំពីរបៀបរស់នៅផ្សារភ្ជាប់ជាមួយជំនឿ។

នៅថ្ងៃទី៣នៃកម្មវិធីបោះជំរំកាយឫទ្ធិ មានកុមារជាងមួយនាក់ផ្សេងទៀតដែលរស់នៅក្បែរតំបន់មជ្ឈមណ្ឌលភ្នំពេញថ្មី បាននាំគ្នាមកចូលរួមអបអរកម្មវិធីសិទ្ធិកុមារអន្តរជាតិផងដែរ ដែលធ្វើឲ្យចំនួនសរុបបានកើនឡើងជាង៥០០នាក់។

នៅក្នុងឱកាសនេះដែរ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា ៖ «ថ្ងៃនេះយើងនឹកដល់ថ្ងៃ១មិថុនា ដែលយើងគោរពសិទ្ធិកុមារអន្តរជាតិ និងមានប្រធានបទ អនាគតភ្លឺស្វាងសម្រាប់កុមារទាំងអស់ គឺមានន័យថាសម្រាប់កុមារនៅក្នុងពិភពលោកទាំងមូល»។

លោកអភិបាលអូលីវីយេ រំឭកដល់កុមារអំពីរបៀបដែលធ្វើឱ្យមានអនាគតភ្លឺស្វាង ដោយយកពេលស្ងៀមស្ងាត់ដើម្បីគិតពីកិច្ចការដែលកុមារម្នាក់ៗចង់ធ្វើនាពេលអនាគត និងដើម្បីឱ្យអនាគតជោគជ័យដោយត្រូវ យកចិត្តទុកដាក់លើសិក្សា លើបងប្អូន ឪពុកម្តាយទាំងក្នុងគ្រួសារនិងក្នុងសង្គម លើច្បាប់កាយឫទ្ធិ ស្រឡាញ់បរិស្ថាន និងយកចិត្តទុកដាក់អធិដ្ឋានជាមួយព្រះជាម្ចាស់ដែលប្រទានជីវិតជាប្រចាំ។

ជាមួយនឹងកម្មវិធីនោះដែរ ការិយាល័យយុវជន ជំទង់ កុមារនិងគ្រួសារ បានរៀបចំ អំណោយបន្តិចបន្តួចសម្រាប់កុមារទាំងអស់។ ក្រោយកម្មវិធីនេះ កុមារកាយឫទ្ធិបាននាំគ្នាចូលរួមអភិបូជារួមគ្នាដើម្បីបិទកម្មវិធី។

លោកអភិបាលអូលីវីយេ ក៏បានណែនាំនៅក្នុងធម្មទេសនាលោកបានរំឭកដល់កុមារ និងគ្រីស្តបរិស័ទទាំងអស់ដើម្បីយកឱកាសនេះចូលរួមជាមួយកូនក្មេងទាំងអស់ដែលកំពុងរងទុក្ខលំបាកគ្មានម្ហូបអាហារគ្រប់គ្រាន់ប្រមាណជា២០លាននាក់ និងរាប់លានដែលស្លាប់ដោយខ្វះម្ហូបនិងសេវាកម្មសុខភាពផងដែរ។

ឆ្លៀតក្នុងឱកាសនេះ លោកអភិបាល ស្នើសុំឲ្យលោកបូជាចារ្យ និងគណៈកម្មការនៅតាមព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទាំងអស់ក្នុងឆ្នាំនៃមហាសន្និបាត២០២១-២០២៣រិះគិតធ្វើយ៉ាងណាឱ្យកុមារមានឱកាស ចួបជុំគ្នា បង្កើតមិត្តថ្មី យល់អំពីជីវិត ស្រឡាញ់បរិស្ថាន ស្រឡាញ់ព្រះជាម្ចាស់និងអ្នកដទៃ ដើម្បីឱ្យព្រះសហគមន៍របស់យើងទៅជាមហាគ្រួសារមួយដែលប្រមូលក្មេងគ្រប់ទីកន្លែង។

លោកបន្ថែមថា បទពិសោធទាំងនេះរួមជាមួយកូនក្មេងមួយចំនួនដែលមិនមែនជាគ្រីស្តបរិស័ទ ជាឱកាសមួយដើម្បីធ្វើដំណើរជាមួយគ្នា ជាឱកាសមួយដើម្បីស្គាល់ព្រះសហគមន៍កាតូលិក និងរិះគិតពីដំណើរជីវិតជាកុមារនៅក្នុងសង្គមបច្ចុប្បន្ននេះ។

កម្មវិធីបោះជំរំកុមារកាយឫទ្ធិនេះ មានកុមារមកពីព្រះសហគមន៍មណ្ឌលសកម្មភាពចំនួន៦គឺ ភ្នំពេញខាងជើង ភ្នំពេញខាងត្បូង ភ្នំពេញថ្មី តាខ្មៅ បាសាក់ និងមេគង្គ។ ព្រះសហគមន៍ក៏បានបង្ហោះប៉េងប៉ោងចូលរួមអបអរសាទរកុមារទាំងអស់ទូទាំងពិភពលោកផងដែរ៕

# កម្មករ-ការិនីរោងចក្រ ឈ្វេងយល់អំពើបៀតបៀនកេរ្តិ៍ខ្មាស

*បន្តពីទំព័រ-១៤*

កញ្ញា ស្រីកែវ បានបន្ថែមថា ជាទូទៅគណៈកម្មការពលកររបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញតែងតែចុះសួរសុខទុក្ខបងប្អូនកម្មករ-ការិនី ជារៀងរាល់ខែ ដោយឈ្វេងយល់អំពីការងារនិងការរស់នៅរបស់ពួកគាត់ ដើម្បីលើកទឹកចិត្ត និងអប់រំសុខភាពដល់ពួកគាត់។

ចំណែក អ្នកស្រី អ៊ូ អន អាយុ៤១ឆ្នាំ ជាកម្មការនីមកពីរោងចក្រ ក្វាន តុង បានឲ្យដឹងថា កម្មវិធី ក្នុងថ្ងៃនេះ ផ្តល់ចំណេះដឹង និងជំរុញឲ្យមានភាពក្លាហានដោះស្រាយបញ្ហារំលោភបំពាន ឬបៀតបៀនកេរ្តិ៍ខ្មាសជាមួយថ្នាក់លើ និងហ៊ាននិយាយណែនាំដល់មិត្តរួមការងារដែលនឹងជួបបញ្ហានេះ។ អ្នកស្រីអន បន្ថែមថា គាត់ចង់ចូលរួមកម្មវិធីផ្តល់ចំណេះដឹងល្អៗបែបនេះបន្ថែមទៀត។ គាត់ក៏បានសូមឲ្យកម្មករ-ការិនី ដែលរងប៉ះពាល់រំលោភផ្លូវភេទ «សូមកុំខ្លាច យើង មានការតស៊ូ យើងកុំភ័យ យើងត្រូវតែហ៊ានប្រឈមមុខដើម្បីដោះស្រាយបញ្ហានេះទាំងអស់គ្នា។»

ទន្ទឹមនឹងនោះ លោក សេង សារិទ្ធ អាយុ២៨ឆ្នាំ ដែលជាបុគ្គលិកផ្នែកអគ្គិសនី បាននិយាយថា «ខ្ញុំគិតថាកម្មវីធីនេះ ជួយដល់កម្មករជាច្រើន ហើយខ្ញុំសង្ឃឹមថា នឹងមានកម្មវិធីបែបនេះបន្តរហូតដល់ឆ្នាំក្រោយៗទៀត។ ខ្ញុំក៏សំណូមពរដល់បុគ្គលិក កម្មករ កម្មការិនីទាំងអស់គ្នាចូលរួមក្នុងកម្មវិធីនេះអោយបានញឹកញាប់ ដើម្បីទទួលបានចំណេះដឹងថ្មីៗ និងល្អៗបន្ថែមទៀត ហើយកម្មវិធីនេះគឺជាថ្នាលបណ្តុះបណ្តាលផ្នត់គំនិតនឹងផ្លាស់ប្តូរការគិត របស់ពួកយើងផងដែរ»។

ឱកាសនោះដែរ កញ្ញា ម៉ៅ ស្រីកែវ ក៏បានបន្ថែមថា ក្រៅពីជំនួបកម្មករ គណៈកម្មការនេះក៏មានកម្មវិធីជាច្រើនទៀតជាមួយពួកគាត់ដែរ ដូចជា កិច្ចប្រជុំរៀងរាល់២ដងក្នុងមួយខែ បោះជំរំជាមួយគ្នា និងប្រារព្ធទិវាពលកម្មអន្តរជាតិជាដើម៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា




## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ










## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម













## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង








